

សម្ព័ន្ធខ្មែរជំរឿន
និងការពារសិទ្ធិមនុស្ស

លីកាដូ

LICADHO

CAMBODIAN LEAGUE FOR THE PROMOTION AND DEFENSE OF HUMAN RIGHTS

# ការវាយប្រហារ និងការគម្រាមកំហែង

## ប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ២០១៣-២០១៤

របាយការណ៍សង្ខេបចេញផ្សាយ
ខែធ្នូ ឆ្នាំ២០១៥

# ការវាយប្រហារ និងការគម្រាមកំហែង៖

## ប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្ស នៅកម្ពុជា ២០១៣-២០១៤

របាយការណ៍សង្ខេបចេញផ្សាយ ខែធ្នូ ឆ្នាំ២០១៥

**សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ**

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ)

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ មក អង្គការនេះ គឺជាអង្គការដែលស្ថិតនៅជួរមុខគេ ក្នុងកិច្ចការពារសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា និងលើកកម្ពស់ការគោរពសិទ្ធិទាំងនោះ ពីរាជរដ្ឋាភិបាលកម្ពុជា និងអង្គការនានា។ ដោយបានកសាងនូវសមិទ្ធិផលល្អក្នុងអតីតកាល លីកាដូ បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងធ្វើការឃ្លាំមើលរាជរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានា ពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង ១៣ ខេត្ត-រាជធានីផ្សេងទៀត។

## កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស

**ឃ្លាំមើលការរំលោភសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារៈ**

បុគ្គលិកលីកាដូ ធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តដោយអាជ្ញាធរ ការរំលោភបំពានលើស្ត្រី និងកុមារ។ ជនរងគ្រោះ ត្រូវបានផ្តល់សេវាជួយជ្រោមជ្រែងតាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីតុលាការ។

**ជំនួយផ្នែកវេជ្ជសាស្ត្រ និងសេវាកម្មសង្គមកិច្ចៈ**

ក្រុមគ្រូពេទ្យផ្តល់សេវាវេជ្ជសាស្ត្រដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារចំនួន១៤ កន្លែង ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស និងគ្រួសារដែលស្ថិតនៅតំបន់តាំងទីលំនៅថ្មី។ ក្រុមការងារសេវាសង្គមធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ហើយផ្តល់ជំនួយជាសម្ភារៈ និងម្ហូបអាហារសម្រាប់រយៈពេលខ្លី។

**ការឃ្លាំមើលពន្ធនាគារៈ**

អ្នកស្រាវជ្រាវពន្ធនាគារ ធ្វើការឃ្លាំមើលពន្ធនាគារចំនួន១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថាជនជាប់ឃុំទទួលបាននូវតំណាងផ្នែកច្បាប់។

**ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់ៈ**

ជនរងគ្រោះ ត្រូវបានផ្តល់ជូននូវការប្រឹក្សាផ្នែកច្បាប់ និងផ្តល់ជូនមេធាវីសិទ្ធិមនុស្សសម្រាប់ជាតំណាងផ្លូវច្បាប់លើករណីសំខាន់ៗមួយចំនួន។

## កម្មវិធីលើកកម្ពស់ និងការទាក់ទាញមតិគាំទ្រ

**គាំទ្រសហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងបណ្តាញនានាៈ**

ជួយដល់សហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងសហគមន៍ ដែលរងគ្រោះ ដោយផ្តល់នូវកិច្ចការពារ សេវាកម្មផ្នែកច្បាប់ ព្រមទាំងជួយពង្រឹងនូវសមត្ថភាពរបស់ពួកគេ ក្នុងការធ្វើយុទ្ធនាការ និងការតស៊ូមតិអំពីសិទ្ធិមនុស្ស។

**ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិៈ**

បុគ្គលិកតស៊ូមតិធ្វើការអប់រំដល់ក្រុមគោលដៅជាក់លាក់មួយចំនួន បណ្តាញគាំទ្រកិច្ចការពារសិទ្ធិមនុស្សនៅថ្នាក់មូលដ្ឋាន និងធ្វើការតស៊ូមតិដើម្បីជួយកែលំអសង្គមនិងច្បាប់ ជាមួយស្ត្រី យុវវ័យ និងកុមារ។

**គាំទ្រការតស៊ូមតិជាសាធារណៈ និងតាមសហគមន៍ៈ**

ករណីរំលោភសិទ្ធិមនុស្ស ដែលស៊ើបអង្កេតដោយអង្គការលីកាដូ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិតជារបាយការណ៍ជាប្រចាំ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍) និងសម្រាប់ធ្វើការតស៊ូមតិផ្សេងៗទៀត។


**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងៈ**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការសិទ្ធិមនុស្ស លីកាដូ
ផ្ទះលេខ ១៦ ផ្លូវ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខៈ (+៨៥៥)២៣ ៧២៧ ១០២/២១៦ ៦០២
ទូរសារៈ (+៨៥៥)២៣ ៧២៧ ១០២/២១៧ ៦២៦

អ៊ីមែលៈ contact@licadho-cambodia.org
គេហទំព័រៈ www.licadho-cambodia.org Facebook: www.facebook.com/licadho Twitter: www.twitter.com/licadho

# មាតិកា


អ្នកការពារសិទ្ធិមនុស្ស៖ និយមន័យ ទំព័រ១

ការការពារសិទ្ធិមនុស្ស៖ ពីខែមេសា ឆ្នាំ២០១៣ ដល់ ខែធ្នូ ឆ្នាំ២០១៤ ទំព័រ៣

និន្នាការ ទំព័រ៧

ការកើនឡើងនៅក្នុងអំពើហិង្សាដែលគាំទ្រដោយអាជ្ញាធររដ្ឋ ៧

បំបិទសំឡេងដោយតុលាការ ៩

ការតស៊ូ ១៤

អនុសាសន៍នានា ទំព័រ១៥

ឧបសម្ព័ន្ធ ១៖ អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា (២០១៣ និង ២០១៤) ទំព័រ១៧





អ្នកការពារសិទ្ធិមនុស្សអបអរទិវាសិទ្ធិមនុស្សអន្តរជាតិ ឆ្នាំ២០១៣



ព្រះសង្ឃ និងសមាជិកសហគមន៍អបអរទិវាសិទ្ធិមនុស្សអន្តរជាតិ ឆ្នាំ២០១៣

# អ្នកការពារសិទ្ធិមនុស្ស៖ និយមន័យ

អ្នកការពារសិទ្ធិមនុស្ស គឺជាអ្នកដែលធ្វើការជាលក្ខណៈបុគ្គល ឬធ្វើការជាក្រុម ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្សជាមូលដ្ឋាន តាមរយៈមធ្យោបាយអហិង្សា នៅក្នុងសង្គម។

អ្នកការពារសិទ្ធិមនុស្សអាចជា៖

- សិស្ស
- បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល
- គ្រូបង្រៀន
- មេធាវី
- សកម្មជនថ្នាក់មូលដ្ឋាន
- មេដឹកនាំសហជីព
- ព្រះសង្ឃ
- អ្នកតំណាងសហគមន៍
- អ្នកកាសែត
- សកម្មជន ដែលជាស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស បុគ្គលស្រឡាញ់ទាំងពីរភេទ បុគ្គលកែភេទ (LGBT)
- សមាជិកនៃក្រុមជនជាតិដើមភាគតិច
- អ្នកជំនាញផ្នែកវេជ្ជសាស្ត្រ

ក្នុងអត្ថបទសង្ខេបនេះ អ្នកការពារសិទ្ធិមនុស្សត្រូវបានគេឲ្យនិយមន័យដែលទាក់ទងទៅនឹងសិទ្ធិ ដែលមានចែងក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌ (ICESCR) ។ ក្នុងការកំណត់ថាតើករណីណាមួយដែលបង្កឲ្យមានការរំលោភបំពាន ឬ ការគម្រាមកំហែងទៅលើអ្នកការពារសិទ្ធិមនុស្ស អង្គការលីកាដូ បានពិចារណាថាតើជនរងគ្រោះបានធ្វើសកម្មភាព ដែលមានគោលបំណងពិតប្រាកដដើម្បីធ្វើការការពារ ឬលើកកម្ពស់សិទ្ធិមនុស្ស ដូចដែលមានចែងក្នុងកតិកាសញ្ញាអន្តរជាតិទាំងនេះដែរឬទេ និងថាតើសកម្មភាពបែបនេះត្រូវបានអនុវត្តក្នុងនាមជំនួសឲ្យអ្នកដទៃទៀតដែរឬទេ។

* អ្នកនយោបាយក៏អាចដើរតួជាអ្នកការពារសិទ្ធិមនុស្សផងដែរ។ ប៉ុន្តែទោះជាយ៉ាងណា រាជរដ្ឋាភិបាលកម្ពុជាតាំងពីអតីតកាលបានភ្ជាប់ការរិះគន់នានាទៅនឹងគណបក្សជំទាស់ ដោយបានព្យាយាមច្រានចោលការរិះគន់ដោយស្របច្បាប់ និងសារទុក្ខជាច្រើន និងចាត់ទុកថាជាសកម្មភាព "នយោបាយ"។ ដើម្បីជៀសវាងការចោទប្រកាន់ថាជាការលំអៀង អង្គការ លីកាដូ មិនបានរួមបញ្ចូលការវាយប្រហារ និងការគំរាមកំហែងទៅលើអ្នកនយោបាយនៅក្នុងអត្ថបទសង្ខេបនេះទេ។

| ជនរងគ្រោះ | ២០១៣ | ២០១៤ | សរុប |
|---|---|---|---|
| អ្នកដឹកនាំសហគមន៍មូលដ្ឋាន | ៣ | ៦ | ៩ |
| សមាជិកសហគមន៍មូលដ្ឋាន | ១០ | ១៥ | ២៥ |
| ប្រព័ន្ធផ្សព្វផ្សាយ | ៣ | ៣ | ៦ |
| ព្រះសង្ឃ | ១ | ៤ | ៥ |
| ក្រុមចម្រុះ | ២ | ៤ | ៦ |
| ប្រធានអង្គការ | | ២ | ២ |
| បុគ្គលិកអង្គការ | ២ | ៦ | ៨ |
| មេដឹកនាំសហជីព | | ៧ | ៧ |
| សមាជិកសហជីព | ៣ | ៦ | ៩ |
| **សរុប** | **២៤** | **៥៣** | **៧៧** |




យុវជនចូលរួមអបអរក្នុងទិវាសិទ្ធិលំនៅឋានអន្តរជាតិ


សហគមន៍ និងសហជីព ដាក់ញត្តិជូនស្ថានទូតនានា ទាមទារឲ្យដោះលែងអ្នកការពារសិទ្ធិមនុស្ស និងវិកម្មករ ទាំង ២៣នាក់

# ការការពារសិទ្ធិមនុស្ស៖ ពីខែមករា ឆ្នាំ២០១៣ ដល់ ខែធ្នូ ឆ្នាំ២០១៤

ដោយសារតែអ្នកការពារសិទ្ធិមនុស្ស នៅតែបន្តដើរតួនាទីសំខាន់ នៅក្នុងការទប់ស្កាត់ការរំលោភបំពានរបស់អាជ្ញាធររដ្ឋ អាជ្ញាធរកម្ពុជាបានបន្តប្រើអំពើហិង្សា ការបំភិតបំភ័យ និងប្រព័ន្ធតុលាការព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជា ដែលតែងតែទទួលសំណូកដើម្បីបញ្ឈប់សកម្មភាព និងបំបិទសំឡេងរបស់អ្នកទាំងនោះ។ ឆ្នាំ២០១៣ និងឆ្នាំ២០១៤ នៅក្នុងប្រទេសកម្ពុជា ត្រូវបានគ្របដណ្តប់ដោយព្រឹត្តិការណ៍ នៃការរៀបចំសម្រាប់ការប្រកួតប្រជែងក្នុងការបោះឆ្នោតថ្នាក់ជាតិ ឆ្នាំ ២០១៣ និងផលវិបាកក្រោយពេលមានព្រឹត្តិការណ៍នេះ។ ប្រជាពលរដ្ឋកម្ពុជារាប់សែននាក់ បានចេញធ្វើបាតុកម្មតាមដងផ្លូវ ដើម្បីទាមទារឲ្យមានការផ្លាស់ប្តូរ ប៉ុន្តែនៅចុងឆ្នាំ ២០១៣ អាជ្ញាធរបានប្រើអំពើហិង្សាកាន់តែខ្លាំងឡើងៗ ដើម្បីឆ្លើយតបទៅនឹងការធ្វើបាតុកម្មទាំងនោះ។ លំនាំអំពើហិង្សានេះបានបន្តរហូតដល់ក្នុងឆ្នាំ ២០១៤។

ពីរបីថ្ងៃដើមឆ្នាំ ២០១៤ អាជ្ញាធរកម្ពុជាបានចាប់ផ្តើមការរំលោភបំពានលើសិទ្ធិសេរីភាពនៃការជួបជុំគ្នា ដែលរួមបញ្ចូលទាំងការហាមឃាត់ស្តីពីការជួបជុំជាសាធារណៈនៅក្នុងប្រាំមួយខែដើមឆ្នាំ ២០១៤។ អំពើហិង្សាដែលបង្កឡើងដោយអាជ្ញាធររដ្ឋទៅលើអ្នកការពារសិទ្ធិមនុស្សក្នុងអំឡុងការតវ៉ា កូដកម្ម និងបាតុកម្មជាសាធារណៈដទៃទៀត ត្រូវបានប្រព្រឹត្តឡើងជាបន្តបន្ទាប់ក្នុងអំឡុងពេលពេញមួយឆ្នាំ ២០១៤។ ករណីមួយចំនួន គេឃើញមានកម្លាំងចម្រុះនៃកងរាជអាវុធហត្ថ នគរបាលបង្ក្រាបបាតុកម្ម និងកងសន្តិសុខខណ្ឌដែលពាក់មួកសុវត្ថិភាពជាញឹកញាប់ប្រដាប់ដោយដំបងឆក់ ត្រូវបានបញ្ជាឲ្យប្រើប្រាស់អំពើហិង្សាបំបែកបាតុកម្មរួមជាមួយនឹងនគរបាល ដោយធ្វើការតម្រង់ទិសដៅទៅរកសកម្មជនសិទ្ធិមនុស្ស ក្រុមអ្នកគាំទ្រសហជីព អ្នកកាសែត និងអ្នកសង្កេតការណ៍សិទ្ធិមនុស្ស។

លើសពីនេះទៀត ក្នុងអំឡុងពេលពីរឆ្នាំនេះ អ្នកការពារសិទ្ធិមនុស្ស ត្រូវបានទទួលការរំលោភបំពានកាន់តែខ្លាំងឡើងៗដោយប្រព័ន្ធតុលាការព្រហ្មទណ្ឌ ដែលរួមបញ្ចូលទាំងការឃុំខ្លួន ការគម្រាមកំហែងផ្លូវច្បាប់ និងការចោទប្រកាន់ដែលមិនត្រឹមត្រូវ។

ក៏ប៉ុន្តែ បើទោះបីជាមានការរីករាលដាលនៃការរំលោភ-បំពានទៅលើសកម្មជនការពារសិទ្ធិមនុស្ស ក្នុងអំឡុងពេលពីរឆ្នាំនេះក៏ដោយ ក៏លំនាំមួយទៀតបានលេចចេញឡើង (ជាការកើនឡើងនៃភាពរឹងមាំរបស់ប្រជាពលរដ្ឋកម្ពុជា ក្នុងការប្រឈមមុខនឹងការគាបសង្កត់)។ ម្តងហើយម្តងទៀត ប្រជាពលរដ្ឋបានវិលត្រឡប់មកតាមដងផ្លូវវិញ ដោយជំនះនឹងការគម្រាមកំហែងសម្លាប់ និងម្តងហើយម្តងទៀតបានប្រថុយប្រថាន (ឬបានស៊ូទ្រាំ) នឹងការទទួលទោសពន្ធ-នាគារដើម្បីទាមទារសិទ្ធិរបស់អ្នកទាំងនោះ និងក្រោកឈរឡើងដើម្បីសហគមន៍ និងសហជីពរបស់ពួកគេ។



ការប៉ះទង្គិចនៅមុខព្រះបរមរាជវាំងអ្នកតំណាងម្នាក់ត្រូវចាប់ខ្លួន

## មេដឹកនាំសហជីព និងកម្មកររោងចក្រកាត់ដេរ បានជាប់ពន្ធនាគារ បន្ទាប់ពីការតវ៉ា

នៅក្នុងថ្ងៃទី២ និងថ្ងៃទី ៣ ខែ មករា ឆ្នាំ ២០១៤ អាជ្ញាធរកម្ពុជា ក្នុងនោះរួមមានអង្គភាពយោធាពិសេសលេខ ៩១១ ត្រូវបានបញ្ជូនឲ្យទៅបំបែកដោយហិង្សាលើបាតុកម្មរបស់កម្មកររោងចក្រកាត់ដេរ បន្ទាប់ពីការរីករាលដាលនៃការធ្វើបាតុកម្មជាច្រើនថ្ងៃអំពីប្រាក់ឈ្នួលអប្បបរមា។ ក្នុងអំឡុងពេលការបង្ក្រាបយ៉ាងអាក្រក់នេះ កងកម្លាំងចម្រុះបានបាញ់ និងសម្លាប់យ៉ាងតិចមនុស្សបួននាក់ និងយ៉ាងតិចមនុស្ស ៣៨ នាក់ផ្សេងទៀតត្រូវបានបញ្ជូនទៅមន្ទីរពេទ្យដែលភាគច្រើនរងរបួសដោយគ្រាប់កាំភ្លើង។ រហូតមកដល់សព្វថ្ងៃនេះ ពុំមានការសើបអង្កេតគួរឲ្យទុកចិត្តណាមួយអំពីអំពើហិង្សានេះនៅឡើយទេ ហើយគ្មាននរណាម្នាក់ត្រូវបានដាក់ឲ្យទទួលខុសត្រូវចំពោះការស្លាប់ និងការរងរបួសទាំងនេះនោះដែរ។

ប៉ុន្តែនៅថ្ងៃទី ២ ខែមករា អាជ្ញាធរបានចាប់ខ្លួនអ្នកការពារសិទ្ធិមនុស្សយ៉ាងតិចណាស់បួននាក់ (លោកវន់ ពៅ ប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) លោក ថេង សាវឿន ប្រធានសម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC) លោក ច័ន្ទ ពុទ្ធិស័ក តំណាងសហគមន៍បឹងកក់ និងលោក សុគន្ធ សម្បត្តិ ពិសិដ្ឋ បុគ្គលិក របស់ CLaRi-Cambodia) នៅពេលដែលអ្នកទាំងនោះបានព្យាយាមចរចារជាមួយកងកម្លាំងសន្តិសុខដើម្បីបញ្ឈប់អំពើហិង្សា និងធ្វើការដោះលែងកម្មករដែលត្រូវបានឃាត់ខ្លួន។ បាតុករចំនួនប្រាំមួយនាក់ ដែលជាកម្មករ និងសកម្មជន ត្រូវបានចាប់ខ្លួននៅក្នុងពេលជាមួយគ្នានេះ។ មនុស្សដប់បីនាក់ផ្សេងទៀតត្រូវបានចាប់ខ្លួន ក្នុងអំឡុងពេលមានអំពើហិង្សានៅថ្ងៃបន្ទាប់។

មនុស្សទាំង ២៣ នាក់ ត្រូវបានបញ្ជូនទៅតុលាការនៅថ្ងៃបន្ទាប់ក្រោយពីការចាប់ខ្លួនអ្នកទាំងនោះ និងត្រូវបាន ចោទប្រកាន់ពីបទប្រើប្រាស់អំពើហិង្សាដោយចេតនា និងការបំផ្លិចបំផ្លាញដោយចេតនា ដែលការចោទប្រកាន់ទាំងពីរមានស្ថានទម្ងន់ទោស។ មនុស្សបីនាក់ក៏ត្រូវបានចោទប្រកាន់ផងដែរជាមួយនឹងការប្រមាថមន្ត្រីសាធារណៈ និងរាំងស្ទះចរាចរណ៍សាធារណៈ។

បន្ទាប់ពីសវនាការ ទីតាំងស្ថិតនៅរបស់មនុស្សទាំង ២៣ នាក់ នៅតែបន្តត្រូវបានលាក់បំបាំងពីក្រុមគ្រួសារ និងមេធាវីរបស់អ្នកទាំងនោះ (ដែលផ្ទុយនឹងច្បាប់កម្ពុជា) រហូតដល់ថ្ងៃទី ៨ ខែ មករា។ មន្ត្រីរាជរដ្ឋាភិបាលបាននិយាយថា មនុស្សទាំង ២៣ នាក់ កំពុងជាប់ឃុំឃាំងនៅក្នុងពន្ធនាគារ ម៣ នៅខេត្តកំពង់ចាមដែលត្រូវបានប្រើប្រាស់ភាគច្រើនលើសលប់ ដើម្បីដាក់ឃុំឃាំងទណ្ឌិតដែលជាប់ទោសធ្ងន់ធ្ងរ។ មនុស្សម្នាក់ៗ ត្រូវបានរងរបួសក្នុងអំឡុងពេលនៃការចាប់ខ្លួន និងមួយចំនួនទៀតត្រូវការការព្យាបាលជាបន្ទាន់។

នៅក្នុងខែ កុម្ភៈ មនុស្ស ពីរនាក់ក្នុងចំណោម ២៣ នាក់ (ដែលម្នាក់ គឺជាអនីតិជនដែលបានទទួលរងរបួសបាក់ដៃម្ខាង ដោយសារទទួលការវាយដំក្នុងអំឡុងពេលការចាប់ខ្លួន) ត្រូវបានដោះលែងឲ្យនៅក្រៅឃុំ។

បន្ទាប់ពីមានការតវ៉ាជាច្រើនខែដើម្បីអំពាវនាវឲ្យមានការដោះលែងអ្នកទាំងនោះ មនុស្សទាំង ២៣ នាក់ ត្រូវបានជំនុំជម្រះក្តីរយៈពេលប្រាំថ្ងៃដាច់ៗពីគ្នាដោយចាប់ផ្តើមនៅថ្ងៃទី ២៥ ខែមេសា និងបញ្ចប់នៅថ្ងៃទី ២២ ខែឧសភា។ នៅពេលជាមួយគ្នានេះដែរ ក៏មានការធ្វើការជំនុំជម្រះក្តីរបស់អ្នកជាប់ឃុំឃាំងពីរនាក់ផ្សេងទៀត ដែលត្រូវបានចាប់ខ្លួនអំឡុងពេលការតវ៉ារបស់កម្មកររោងចក្រកាត់ដេរ នៅថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០១៣ ផងដែរ។

នៅថ្ងៃទី ៣០ ខែឧសភា ចៅក្រមបានបានប្រកាសសាលក្រម។ មនុស្សទាំង ២៣ នាក់ ត្រូវបានតុលាការរកឃើញថាមានទោស ប៉ុន្តែទោសពន្ធនាគារត្រូវបានព្យួររហូតដល់ទៅបួនឆ្នាំ និងពិន័យឲ្យបង់ប្រាក់យ៉ាងច្រើន។ ទីបំផុតមនុស្សទាំង ២៣ នាក់ ត្រូវបានគេដោះលែង ប៉ុន្តែការគំរាមកំហែងក្នុងការជាប់ពន្ធនាគារ នៅតែបន្តជាការព្រួយបារម្ភរបស់អ្នកទាំងនោះដដែល។ លោក វន់ ពៅ លោក ថេង សាវឿន លោក ច័ន្ទ ពុទ្ធិស័ក លោក សុគន្ធ សម្បត្តិពិសិដ្ឋ ទទួលទោសយ៉ាងធ្ងន់ធ្ងរចន្លោះពីបួន ទៅបួនឆ្នាំកន្លះ។ អ្នកទាំងនោះប្រឈមមុខនឹងគ្រោះថ្នាក់ក្នុងការបំពេញទោសចំពោះរយៈពេលជាប់ពន្ធនាគារដែលនៅសល់នៅពេលក្រោយទៀត ប្រសិនបើត្រូវ

បានរកឃើញថាមានទោសពីបទចោទប្រកាន់ផ្សេងទៀត ហើយការផ្តន្ទាទោសអាចដកហូតអ្នកទាំងនោះចេញពីតួនាទីដឹកនាំសហជីពរបស់ពួកគេ។

ករណីនេះមិនត្រឹមតែបង្ហាញឲ្យឃើញនូវការប្រើប្រាស់ប្រព័ន្ធតុលាការទៅលើអ្នកការពារសិទ្ធិមនុស្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្ហាញនូវនិទណ្ឌភាពចំពោះការធ្វើបាប និងការបំពានលើរាងកាយ ដែលប្រព្រឹត្តឡើងដោយអាជ្ញាធរ។ មិនមានការស៊ើបអង្កេតលើការឃុំខ្លួនដោយខុសច្បាប់ ក៏ដូចជាលើការទទួលរងរបួសដោយស្នាដៃរបស់កងកម្លាំងសន្តិសុខក្នុងអំឡុងពេលនៃការចាប់ខ្លួន ត្រូវបានធ្វើឡើងនៅឡើយនោះទេ។

ការដោះលែងអ្នកទាំងនោះ ក៏បានបង្ហាញផងដែរអំពីអំណាចនៃការតស៊ូតវ៉ាម្តងហើយម្តងទៀត។ ទោះបីជាមានករណីម្តងហើយម្តងទៀតនៃការរំលោភបំពាន អំពើហិង្សាលើរាងកាយ និងការចាប់ខ្លួនក៏ដោយ ក៏សហគមន៍និងសហជីពមិនបានបញ្ឈប់ការអំពាវនាវរបស់ពួកគេឲ្យមានការដោះលែងអ្នកការពារសិទ្ធិមនុស្ស និងកម្មករនោះទេ។ ឧទាហរណ៍៖

- នៅថ្ងៃទី ១៩ ខែមករា មនុស្សមួយក្រុមដែលបានប្រមូលផ្តុំគ្នានៅខាងមុខព្រះបរមរាជវាំងដើម្បីតវ៉ាជំទាស់នឹងការចាប់ខ្លួននេះ ត្រូវបានបំភិតបំភ័យ និងរំលោភបំពានលើរាងកាយដោយកងសន្តិសុខ និងប្រជាពលរដ្ឋស្លៀកពាក់ស៊ីវិល ប្រហែលជា ៥០ នាក់ ដែលមានពាក់មួកសុវត្ថិភាពពណ៌ខ្មៅ។ សុខ ឈុនអឿង អនុប្រធានសមាគម IDEA ត្រូវបានចាប់ខ្លួននៅពេលល្ងាចថ្ងៃដដែល និងត្រូវបានឃាត់ខ្លួនពេញមួយយប់នៅក្នុងស្នងការនគរបាលរាជធានីភ្នំពេញ។

- នៅថ្ងៃទី ២១ ខែ មករា សកម្មជនសិទ្ធិមនុស្សចំនួន ១១ នាក់ ត្រូវបានចាប់ខ្លួន និងឃុំខ្លួន ដោយកងកម្លាំងសន្តិសុខខណ្ឌដូនពេញ ចំនួន ៤០នាក់ ខណៈពេលដែលអ្នកទាំងនោះកំពុងនាំមុខការហែក្បួនទៅកាន់ស្ថានទូតអាមេរិក។ ក្នុងចំណោមមនុស្សទាំង ១១ នាក់ ដែលត្រូវបានចាប់ខ្លួន គឺមាន លោក រ៉ុង ឈុន ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ (CITA) អ្នកស្រី ទេពវន្នី និងអ្នកស្រី យ៉ោម បុប្ផា រួមជាមួយសកម្មជនបឹងកក់ប្រាំពីរនាក់ទៀត បុគ្គលិកម្នាក់នៃក្រុមការងារសិទ្ធិលំនៅឋាន (HRTF) និងសកម្មជនម្នាក់មកពីសម្ព័ន្ធសហជីពកម្ពុជា (CATU)។ ក្រោយមកមនុស្សទាំង ១១ នាក់ ត្រូវបានដោះលែង នៅពេលរសៀល បន្ទាប់ពីអ្នកទាំងនោះបានយល់ព្រមចុះហត្ថលេខាលើលិខិតមួយច្បាប់សន្យាថា ពួកគេនឹងមិនញុះញង់ ឬចូលរួមក្នុងសកម្មភាព ឬបាតុកម្មខុសច្បាប់បន្តទៀតឡើយ។



កងកម្លាំងចម្រុះក្នុងថ្ងៃបង្ក្រាបដោយហិង្សា
នៅផ្លូវវេងស្រេង ថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤



កងកម្លាំងចម្រុះ និងក្រុមមនុស្សស្លៀកពាក់ស៊ីវិល បណ្តេញក្រុមអ្នកគាំទ្រគណបក្សជំទាស់ពីទីលានប្រជាធិបតេយ្យ

| **ការរំលោភបំពាន** | **២០១៣** | **២០១៤** | **សរុប** |
|---|---|---|---|
| **រំលោភបំពានពីអាជ្ញាធរ** | **២** | **២៤** | **២៦** |
| ផ្តន្ទាទោសព្រហ្មទណ្ឌ | | ២ | ២ |
| ការឃាត់ខ្លួន និងចាប់ខ្លួន | ១ | ១៩ | ២០ |
| ផ្សេងៗ | ១ | ៣ | ៤ |
| **បំពានលើសេរីភាពក្នុងការជួបជុំ** | **១១** | **៩** | **២០** |
| អហិង្សា | ១ | | ១ |
| ហិង្សា និងការចាប់ខ្លួន | ១០ | ៩ | ១៩ |
| **ការគម្រាមកំហែង** | **៨** | **១១** | **១៩** |
| គម្រាមកំហែងសម្លាប់ | ២ | ២ | ៤ |
| ផ្លូវច្បាប់ | ៦ | ៧ | ១៣ |
| ហិង្សា | | ២ | ២ |
| **បាត់បង់ការចិញ្ចឹមជីវិត** | | **២** | **២** |
| ការដកដំណែង | | ២ | ២ |
| **ហិង្សា** | **៣** | **៧** | **១០** |
| ការរំលោភបំពាន | ៣ | ៦ | ៩ |
| ការសម្លាប់ | | ១ | ១ |
| **សរុប** | **២៤** | **៥៣** | **៧៧** |



ព្រះសង្ឃ និងសហគមន៍ ចូលរួមដើរក្បួនទាមទារឲ្យមានការដោះលែងអ្នកការពារសិទ្ធិមនុស្ស និងរិកម្មករទាំង២៣នាក់

# និន្នាការ

## ការកើនឡើងនៅក្នុងអំពើហិង្សាដែលគាំទ្រដោយអាជ្ញាធររដ្ឋ

នៅក្នុងឆ្នាំ ២០១៣ យើងឃើញមានប្រជាពលរដ្ឋកម្ពុជាពាសពេញដងផ្លូវ បានធ្វើបាតុកម្មដើម្បីទាមទារសិទ្ធិរបស់អ្នកទាំងនោះ ជាពិសេសបន្ទាប់ពីមានការប្រកាសពីលទ្ធផលនៃការបោះឆ្នោតជាតិ។ ការតវ៉ារបស់អ្នកទាំងនោះ ម្តងហើយម្តងទៀត បានទទួលមកវិញដោយអំពើហិង្សាពីអាជ្ញាធរ ដែលបានព្យាយាមបំបិទសំឡេងអ្នកការពារសិទ្ធិមនុស្សដោយប្រើប្រាស់កម្លាំង។

ជាច្រើនលើក អ្នកការពារសិទ្ធិមនុស្សដែលនៅឈរដឹកនាំនៅខាងមុខក្នុងការអំពាវនាវឲ្យមានការផ្លាស់ប្តូរ បានប្រថុយជីវិតរបស់អ្នកទាំងនោះដើម្បីធ្វើការងាររបស់ពួកគេ។ អ្នកការពារសិទ្ធិមនុស្សបួននាក់ ត្រូវបានចាប់ខ្លួននៅលើផ្លូវវែងស្រែងនៅក្នុងព្រឹត្តិការណ៍អំពើហិង្សារយៈពេលពីរថ្ងៃ ដែលបណ្តាលឲ្យមនុស្សបួននាក់ត្រូវបានបាញ់សម្លាប់។ អ្នកទាំងបួន ដែលរួមជាមួយកម្មករ ១៩ នាក់ដែលត្រូវបានចាប់ខ្លួនជាមួយគ្នា ត្រូវបានវាយដំយ៉ាងធ្ងន់ធ្ងរដោយកងកម្លាំងរបស់រដ្ឋក្នុងអំឡុងពេលចាប់ខ្លួន។

សរុបរយៈពេលពីរឆ្នាំនេះ យ៉ាងតិចណាស់មាន ១៩ ករណីដែលកងកំលាំងរបស់រដ្ឋបានប្រើប្រាស់អំពើហិង្សាដើម្បីបំបែកការតវ៉ា និងការកំណត់គោលដៅដោយចេតនា សំដៅទៅរកប្រធានសហជីព ឬអ្នកដឹកនាំថ្នាក់មូលដ្ឋាន បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងអ្នកកាសែត។

លក្ខណៈមួយនៃអំពើហិង្សា ទៅលើអ្នកការពារសិទ្ធិមនុស្សនៅក្នុងឆ្នាំ ២០១៣ និង ឆ្នាំ ២០១៤ គឺការកើនឡើងនៃការប្រើប្រាស់កងសន្តិសុខ ដែលធ្វើការជាមួយក្រុមនគរបាល និងនៅក្នុងករណីមួយចំនួន ធ្វើការជាមួយនឹងក្រុមហ៊ុនឯកជនដើម្បីបំភិតបំភ័យ និងគ្រប់គ្រងការតវ៉ា ហើយក៏ដូចជាការកើតឡើងវិញនៃក្រុមមនុស្សដែលស្លៀកពាក់ស៊ីវិល និងប្រដាប់ដោយដំបង និងដុំថ្ម។ កងសន្តិសុខប្រដាប់ដោយអាវុធត្រូវបានប្រើប្រាស់កាន់តែខ្លាំងឡើង ដើម្បីបំបែកការតវ៉ាដោយហិង្សា និងកំណត់ទិសដៅជាពិសេសទៅលើអ្នកដឹកនាំសហជីព ឬអ្នកដឹកនាំក្រុមប្រជាជនថ្នាក់មូលដ្ឋាន។ រហូតមកដល់ពេលនេះនៅតែមិនទាន់ច្បាស់ថា តើមានមូលដ្ឋានច្បាប់ណាមួយសម្រាប់ការប្រើប្រាស់កងសន្តិសុខនៅក្នុងការប្រើកម្លាំង ដើម្បីបំបែកបាតុកម្មអហិង្សា។

ការកំណត់គោលដៅជាក់លាក់ទៅលើអ្នកឃ្លាំមើលការតវ៉ា និងអ្នកកាសែតដោយកងសន្តិសុខ និងមនុស្សស្លៀកពាក់ស៊ីវិលប្រដាប់ដោយអាវុធ បានបង្ហាញឲ្យឃើញពីនិន្នាការថ្មីមួយផ្សេងទៀតដែលបានឈានដល់កំពូលនៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៣ នៅពេលដែលមានការធ្វើការតវ៉ាដោយអត់អាហារ និងអហិង្សាដោយសកម្មជនបឹងកក់ និងបុរីកីឡានៅវត្តភ្នំ ត្រូវបានវាយដំដោយកងកម្លាំងមួយចំនួន នៅអំឡុងពេលឈានចូលពាក់កណ្តាលអធ្រាត្រ។ មន្ត្រីកងរាជអាវុធហត្ថ កងសន្តិសុខ និងមនុស្សស្លៀកពាក់ស៊ីវិលប្រមាណជា ៣០ ទៅ ៥០ នាក់ បានចូលទៅរកក្រុមតវ៉ាដែលមានចំនួនធ្លាក់ចុះ ដោយប្រើដំបងឆក់ កាំភ្លើង និងដំពាម ដែលបានធ្វើឲ្យរបួសតំណាងសហគមន៍ចំនួនដប់នាក់។ ខណៈពេលដែលអ្នកឃ្លាំ-

## ក្រុមអ្នកតវ៉ាទទួលរងការវាយដំ

កាលពីខែតុលា ឆ្នាំ២០១៤ សន្តិសុខនៅក្នុងរាជធានីភ្នំពេញបានប្រើអំពើហិង្សា បំបែកអ្នកភូមិ និងអ្នកគាំទ្រ ៨០នាក់ មកពីខេត្តព្រះវិហារ ដែលបានមករាជធានីភ្នំពេញ ដើម្បីសុំជំនួយពីរាជរដ្ឋាភិបាល ក្នុងការដោះស្រាយជម្លោះដីធ្លីរបស់អ្នកទាំងនោះ ខណៈពេលដែលនគរបាល និងមន្ត្រីនគរបាល បានឈរនៅក្បែរលំនៅស្ថានឯកជនរបស់នាយករដ្ឋមន្ត្រី។

អំពើហិង្សានេះបានធ្វើឲ្យប្រជាពលរដ្ឋសរុបចំនួន ១៨ នាក់រងរបួស ដែលក្នុងនោះជាច្រើននាក់បានរងរបួសក្បាល។ ក្នុងចំណោមអ្នកដែលរងរបួស គឺលោក អ៊ុក ពេជ្រ សំណាង ដែលត្រូវបានចាប់ខ្លួន និងត្រូវបានចោទប្រកាន់ទាក់ទងនឹងការតវ៉ានេះផងដែរ។



តំណាងសហជីព និងសហគមន៍ប៉ះទង្គិចជាមួយក្រុមសន្តិសុខ នៅទីលានប្រជាធិបតេយ្យ

មើលសិទ្ធិមនុស្ស និងអ្នកកាសែតបានប្រញាប់ប្រញាល់ទៅកន្លែងកើតហេតុ កងកម្លាំងសន្តិសុខ និងមនុស្សស្លៀកពាក់ស៊ីវិលបានបែរអាវុធតម្រង់ទៅរកអ្នកទាំងនោះ៖ អ្នកឃ្លាំមើលម្នាក់បានរងរបួសទ្រូង អ្នកកាសែតជាច្រើននាក់ត្រូវបានឆក់ដោយដំបង និងកាមេរ៉ារបស់អ្នកថតរូបម្នាក់ត្រូវបានកម្ទេចដោយចេតនា។

មនុស្សស្លៀកពាក់ស៊ីវិល ក៏បានប្រព្រឹត្តអំពើរំលោភបំពានទៅលើអ្នកការពារសិទ្ធិមនុស្ស ដោយគ្មានការដាក់ទោស។ នៅក្នុងករណីយ៉ាងតិចណាស់ចំនួន ១៣ ករណី អ្នកការពារសិទ្ធិមនុស្ស ត្រូវទទួលរងនូវការបំពានរាងកាយ និងការគម្រាមកំហែង ដែលប្រព្រឹត្តដោយបុគ្គលឯកជន។ នៅក្នុងករណីយ៉ាងតិចណាស់ពីរករណីនៃករណីទាំងនោះ អ្នកតំណាងសហជីពត្រូវបានវាយដំរហូតដល់សន្លប់ ដោយសមាជិកសហជីពដែលគាំទ្ររាជរដ្ឋាភិបាល។ ជនដៃដល់ជាញឹកញាប់នៅតែមិនស្គាល់អត្តសញ្ញាណ ហើយដូច្នេះមិនដែលត្រូវបាននាំទៅផ្តន្ទាទោសនោះទេ។




អវត្តមាន នៃការទទួលខុសត្រូវចំពោះការប្រើប្រាស់កងកម្លាំងហួសកម្រិត បានបង្ហាញបន្ថែមទៀតថានិទណ្ឌភាពទាំងអស់ក្នុងប្រទេសកម្ពុជាគឺសម្រាប់តែអ្នកដែលកាន់អំណាចប៉ុណ្ណោះ។ នេះក៏បង្ហាញផងដែរ អំពីការឃុបឃិតគ្នាយ៉ាងជិតស្និទ្ធរវាងផលប្រយោជន៍របស់រដ្ឋ និងឯកជន។ នៅក្នុងករណីមួយចំនួនអំពើហិង្សាត្រូវបានប្រព្រឹត្តឡើងដោយកងសន្តិសុខក្នុងនាមឲ្យក្រុមហ៊ុនឯកជន។

## បំបិទសំឡេងដោយតុលាការ

កងកម្លាំងសន្តិសុខ ទទួលបាននិទណ្ឌភាពចំពោះការប្រើប្រាស់អំពើហិង្សារបស់អ្នកទាំងនោះ ចំណែកឯប្រព័ន្ធតុលាការនៅតែជាអាវុធដើម្បីប្រើប្រាស់ក្នុងការបន្តការវាយប្រហារ និងបំបិទសំលេងអ្នកការពារសិទ្ធិមនុស្សបន្ថែមទៀត តាមរយៈការចាប់ខ្លួន និងការផ្តន្ទាទោសគ្មានមូលដ្ឋានគ្រប់គ្រាន់។ នៅឆ្នាំ ២០១៤ ចំនួននៃអ្នកការពារសិទ្ធិមនុស្សដែលត្រូវបានចាប់ខ្លួន និងឃុំខ្លួនបានកើនឡើងពី ១ ទៅដល់ ២១ នាក់ ដែលនេះបង្ហាញជាថ្មីម្តងទៀតនៃចរិកលក្ខណៈនយោបាយរបស់ប្រព័ន្ធតុលាការកម្ពុជានៅគ្រប់ជាន់ថ្នាក់។

ក្នុងករណីមួយចំនួន អ្នកការពារសិទ្ធិមនុស្សត្រូវបានឃាត់ខ្លួនដោយគ្មានមូលដ្ឋានគ្រប់គ្រាន់ ដើម្បីធ្វើការសាកសួរ ហើយអ្នកទាំងនោះមិនអាចរួចខ្លួនបានទេ រហូតដល់ពួកគេបានប្រគល់សម្ភារៈរបស់អ្នកទាំងនោះ និងបានចុះហត្ថលេខាលើលិខិតសន្យាថានឹងមិនចូលរួមនៅក្នុងការតវ៉ាទៀតឡើយ។ ក្នុងករណីផ្សេងទៀត អ្នកការពារសិទ្ធិមនុស្សត្រូវបានឃុំខ្លួន ដោយមិនបានដឹងពីការចោទប្រកាន់ទៅលើអ្នកទាំងនោះ។ ចំពោះករណីដែលបានទៅដល់តុលាការ ច្បាប់ និងនីតិវិធីដែលជាទម្លាប់ត្រូវបានច្រានចោល ហើយជាញឹកញាប់ការខ្វះខាតភស្តុតាងទាំងស្រុង ដើម្បីគាំទ្រការចោទប្រកាន់នៃបទល្មើសបានបង្ហាញឲ្យឃើញថា គ្មានរបាំងណាមួយចំពោះការសម្រេចរបស់តុលាការឲ្យមានទោសនោះទេ។

## អំណាចអង្គនីតិបញ្ញត្តិ អំណាចស្ថាប័នប្រតិបត្តិ និងអំណាចស្ថាប័នតុលាការ ត្រូវបានបែងចែកដាច់ពីគ្នា។

## មាត្រា ៥១

## អំណាចតុលាការជាអំណាចឯករាជ្យ។ អំណាចតុលាការធានារក្សាអនាគតិ និង ការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។

## មាត្រា ១២៨

## រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

ការចោទប្រកាន់ ដែលត្រូវបានប្រើប្រាស់ទៅលើអ្នកការពារសិទ្ធិមនុស្ស តែងមានការប្រែប្រួល ប៉ុន្តែលំនាំទូទៅ គឺការប្រើប្រាស់ការចោទប្រកាន់ដែលមានអំណោយផលជាពិសេស សម្រាប់ការរំលោភបំពានដោយការពិន័យ គ្មានភាពច្បាស់លាស់ គ្មានដែនកំណត់ និងមានភាពធ្ងន់ធ្ងរ។ ស្រដៀងទៅនឹងឆ្នាំមុន ការចោទប្រកាន់ដែលទាក់ទងទៅនឹងបទបរិហារកេរ្តិ៍ ញុះញង់ និងជ្រៀតជ្រែក នៅក្នុងការបំពេញមុខងារសាធារណៈ បានបង្ហាញថាការចោទប្រកាន់បែបនេះមានការពេញនិយមជាពិសេស នៅក្នុងការប្រើប្រាស់ទៅលើអ្នកការពារសិទ្ធិមនុស្ស។[៩]

| ការវាយប្រហារ និងគម្រាមកំហែងតាមខេត្ត | ២០១៣ | ២០១៤ | សរុប |
|---|---|---|---|
| បន្ទាយមានជ័យ | ២ | ២ | ៤ |
| បាត់ដំបង | ១ | ១ | ២ |
| កំពង់ចាម | | ២ | ២ |
| កំពង់ឆ្នាំង | ១ | ៤ | ៥ |
| កំពង់ធំ | ១ | ២ | ៣ |
| កណ្ដាល | ៤ | ២ | ៦ |
| កោះកុង | ១ | | ១ |
| កំពង់ស្ពឺ | | ១ | ១ |
| ក្រចេះ | | ២ | ២ |
| មណ្ឌលគីរី | | ២ | ២ |
| ឧត្តរមានជ័យ | | ៣ | ៣ |
| ប៉ៃលិន | | ១ | ១ |
| ភ្នំពេញ | ១២ | ២២ | ៣៤ |
| ព្រះវិហារ | | ៣ | ៣ |
| ព្រៃវែង | | ១ | ១ |
| ពោធិ៍សាត់ | ១ | | ១ |
| រតនគីរី | ១ | ១ | ២ |
| ស្វាយរៀង | | ២ | ២ |
| តាកែវ | | ២ | ២ |
| **សរុប** | **២៤** | **៥៣** | **៧៧** |

៩ ការយល់ខុសនៃការវិវឌ្ឍន៍៖ ច្បាប់កម្ពុជាមួយចំនួនរំលោភសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ, លីកាដូ, ខែ តុលា ឆ្នាំ ២០១១, មាននូវ៖ http://www.licadho-cambodia.org/reports.php?perm=162




សហគមន៍ដីខលើ តវ៉ាប្រឆាំងការរំលោភដីធ្លី នៅស្រុកស្រែអំបិល ខេត្តកោះកុង

## ការចាប់ខ្លួនសកម្មជនដីធ្លី

នៅខែ មីនា ឆ្នាំ ២០១៤ អ្នកតំណាងបួននាក់នៃជនរងគ្រោះដោយការរំលោភយកដីធ្លី (លោក អោម សំអាត លោក អោម សំអី លោក ពេជ្រ សុធា និងលោក ទូន ម៉ក់) ត្រូវបានគេចាប់ខ្លួន និងចោទប្រកាន់ពីបទទន្ទ្រានយកដីរដ្ឋដោយខុសច្បាប់ និងត្រូវបានឃុំខ្លួននៅពន្ធនាគារខេត្តប៉ៃលិន។

ការចាប់ខ្លួននេះបានធ្វើឡើងបន្ទាប់ពីអ្នកតំណាងទាំងបួននាក់បានរៀបចំពលរដ្ឋក្នុងភូមិចំនួនបួនផ្សេងគ្នា (ភូមិ តមណុប ភូម អ៊ូ កន្ទៀង វៀ ភូមិ អន្លង់រក្សា និងភូមិ ភ្នំ គៀន ប៉ាផុល) ដើម្បីសរសេរលិខិតមួយទៅសម្តេចនាយករដ្ឋមន្ត្រី ដើម្បីប្តឹងអំពីការបំផ្លិចបំផ្លាញផ្ទះរបស់ពួកគេ ក្នុងការប៉ុនប៉ងរំលោភយកដីធ្លី។ សកម្មភាពនេះមិននាំមកនូវដំណោះស្រាយនោះទេ ហើយអភិបាលខណ្ឌបានបន្តចោទប្រកាន់ប្រឆាំងនឹងអ្នកតំណាងទាំងបួនពីបទទន្ទ្រានយកដីធ្លីដោយខុសច្បាប់។ ពួកគេត្រូវបានដោះលែងឲ្យនៅក្រៅឃុំនៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤។

| ប្រភេទការរំលោភបំពាន | ២០១៣ | ២០១៤ | សរុប |
|---|---|---|---|
| **អ្នកដឹកនាំសហគមន៍មូលដ្ឋាន** | **៣** | **៦** | **៩** |
| រំលោភបំពានពីអាជ្ញាធរ - ការឃាត់ខ្លួន និងចាប់ខ្លួន | | ៣ | ៣ |
| បំពានលើសេរីភាពក្នុងការជួបជុំ - ហិង្សា និងការចាប់ខ្លួន | | ១ | ១ |
| ការគម្រាមកំហែង - គម្រាមកំហែងសម្លាប់ | ២ | ១ | ៣ |
| ការគម្រាមកំហែង - ផ្លូវច្បាប់ | ១ | ១ | ២ |
| **សមាជិកសហគមន៍មូលដ្ឋាន** | **១០** | **១៥** | **២៥** |
| រំលោភបំពានពីអាជ្ញាធរ- ផ្តន្ទាទោសព្រហ្មទណ្ឌ | | ២ | ២ |
| រំលោភបំពានពីអាជ្ញាធរ - ការឃាត់ខ្លួន និងចាប់ខ្លួន | | ៣ | ៣ |
| បំពានលើសេរីភាពក្នុងការជួបជុំ - ហិង្សា និងការចាប់ខ្លួន | ៧ | ៦ | ១៣ |
| ការគម្រាមកំហែង - គម្រាមកំហែងសម្លាប់ | | ១ | ១ |
| ការគម្រាមកំហែង - ផ្លូវច្បាប់ | ២ | ១ | ៣ |
| ហិង្សា - ការរំលោភបំពាន | ១ | ១ | ២ |
| ហិង្សា - ការសម្លាប់ | | ១ | ១ |
| **ប្រព័ន្ធផ្សព្វផ្សាយ** | **៣** | **៣** | **៦** |
| ការគម្រាមកំហែង - ផ្លូវច្បាប់ | ២ | ១ | ៣ |
| ហិង្សា - ការរំលោភបំពាន | ១ | ២ | ៣ |
| **ព្រះសង្ឃ** | **១** | **៤** | **៥** |
| រំលោភបំពានពីអាជ្ញាធរ - ផ្សេងៗ | ១ | ១ | ២ |
| ការគម្រាមកំហែង - ផ្លូវច្បាប់ | | ១ | ១ |
| បាត់បង់ការចិញ្ចឹមជីវិត - ការដកតំណែង | | ២ | ២ |
| **ក្រុមច្រមុះ** | **២** | **៤** | **៦** |
| រំលោភបំពានពីអាជ្ញាធរ - ការឃាត់ខ្លួន និងចាប់ខ្លួន | | ២ | ២ |
| រំលោភបំពានពីអាជ្ញាធរ - ផ្សេងៗ | | ១ | ១ |
| បំពានលើសេរីភាពក្នុងការជួបជុំ - ហិង្សា និងការចាប់ខ្លួន | ២ | ១ | ៣ |
| **ប្រធានអង្គការ** | | **២** | **២** |
| រំលោភបំពានពីអាជ្ញាធរ - ផ្សេងៗ | | ១ | ១ |
| ការគម្រាមកំហែង - ហិង្សា | | ១ | ១ |

| | | | |
|---|---|---|---|
| **បុគ្គលិកអង្គការ** | **២** | **៦** | **៨** |
| រំលោភបំពានពីអាជ្ញាធរ - ការឃាត់ខ្លួន និងចាប់ខ្លួន | ១ | ២ | ៣ |
| ការគម្រាមកំហែង - ផ្លូវច្បាប់ | ១ | ១ | ២ |
| ហិង្សា - ការរំលោភបំពាន | | ៣ | ៣ |
| **មេដឹកនាំសហជីព** | | **៧** | **៧** |
| រំលោភបំពានពីអាជ្ញាធរ - ការឃាត់ខ្លួន និងចាប់ខ្លួន | | ៤ | ៤ |
| បំពានលើសេរីភាពក្នុងការជួបជុំ - ហិង្សា និងការចាប់ខ្លួន | | ១ | ១ |
| ការគម្រាមកំហែង - ផ្លូវច្បាប់ | | ១ | ១ |
| ការគម្រាមកំហែង - ហិង្សា | | ១ | ១ |
| **សមាជិកសហជីព** | **៣** | **៦** | **៩** |
| រំលោភបំពានពីអាជ្ញាធរ - ការឃាត់ខ្លួន និងចាប់ខ្លួន | | ៥ | ៥ |
| បំពានលើសេរីភាពក្នុងការជួបជុំ - អហិង្សា | ១ | | ១ |
| បំពានលើសេរីភាពក្នុងការជួបជុំ - ហិង្សា និងការចាប់ខ្លួន | ១ | | ១ |
| ការគម្រាមកំហែង - ផ្លូវច្បាប់ | | ១ | ១ |
| ហិង្សា - ការរំលោភបំពាន | ១ | | ១ |
| **សរុប** | **២៤** | **៥៣** | **៧៧** |



កម្មកររោងចក្រកាត់ដេរតវ៉ាតម្លើងប្រាក់សឈ្នួលសមរម្យ ខែធ្នូ ឆ្នាំ២០១៣

## ការតស៊ូ

ទោះបីជាមានការបង្ក្រាបដ៏ខ្លាំងក្លារហូតដល់អាយុជីវិត ទៅលើការធ្វើបាតុកម្ម អំពើហិង្សាលើរាងកាយ និងការគម្រាមកំហែងដោយប្រព័ន្ធតុលាការព្រហ្មទណ្ឌ អ្នកការពារសិទ្ធិមនុស្សបានបន្ត និងថែមទាំងធ្វើការអំពាវនាវរបស់អ្នកទាំងនោះកាន់តែខ្លាំងឡើង នៅក្នុងអំឡុងឆ្នាំ ២០១៣ និងឆ្នាំ ២០១៤ ដើម្បីឲ្យកម្ពុជាកាន់តែទទួលបានយុត្តិធម៌ ។

សកម្មជនដីធ្លី និងបរិស្ថាននៅទូទាំងប្រទេសកម្ពុជាបានបន្តការប្រយុទ្ធប្រឆាំងដើម្បីការពារភូមិរបស់អ្នកទាំងនោះ ពីក្រុមអ្នកអភិវឌ្ឍន៍ ដែលមានបំណងឈូសឆាយដីធ្លី និងធ្វើការបណ្ដេញប្រជាពលរដ្ឋ ដែលសកម្មភាពរបស់សកម្មជនទាំងនេះជាញឹកញាប់គឺភ្ជាប់ជាមួយក្រុមនិងបណ្ដាញផ្សេងទៀត។ការរីករាលដាលនៃកូដកម្មរោងចក្រកាត់ដេរ នៅឆ្នាំ ២០១៣ និងឆ្នាំ ២០១៤ បាននាំមកនូវក្រុមសកម្មជនការពារសិទ្ធិមនុស្សមួយផ្សេងទៀត ដែលត្រូវបានកំណត់គោលដៅដោយអាជ្ញាធររដ្ឋ៖ មេដឹកនាំសហជីព។ យ៉ាងតិចណាស់សមាជិកសហជីព ១៦ នាក់ ត្រូវបានទទួលរងគ្រោះដោយអំពើហិង្សាការឃុំឃាំង ឬការចាប់ខ្លួន ក្នុងអំឡុងរយៈពេលពីរឆ្នាំដើម្បីព្យាយាមបញ្ឈប់អ្នកទាំងនោះ មិនឲ្យរៀបចំការអំពាវនាវឲ្យមានលក្ខខណ្ឌការងារប្រសើរជាងមុន និងប្រាក់ឈ្នួលកាន់តែប្រសើរនោះទេ។ មេដឹកនាំសហព័ន្ធសហជីពជាច្រើន នៅតែមិនទាន់រួចខ្លួនពីការចោទប្រកាន់ព្រហ្មទណ្ឌរបស់អ្នកទាំងនោះ បន្ទាប់ពីព្រឹត្តិការណ៍នៅលើផ្លូវវេងស្រេង។

ទោះយ៉ាងណា សហជីពនៅតែមានការប្ដេជ្ញាចិត្តចំពោះការតស៊ូរបស់អ្នកទាំងនោះ និងបន្តទាមទារឲ្យមានការអនុវត្តស្មើភាពសម្រាប់កម្មករកម្ពុជា។ បន្ទាប់ពីការចាប់ខ្លួនអ្នកការពារសិទ្ធិមនុស្ស និងកម្មករ ២៣ នាក់ ក្នុងអំឡុងពេលនៃការបង្ក្រាបហិង្សាលើ ការធ្វើកូដកម្មរបស់កម្មកររោងចក្រកាត់ដេរ នៅខែ មករា ឆ្នាំ ២០១៤ អ្នកការពារសិទ្ធិមនុស្សមកពីសហគមន៍ និងសហជីពរបស់អ្នកទាំងនោះរួមគ្នានៅក្នុងការអំពាវនាវឲ្យមានការដោះលែងពួកគេម្ដងហើយ ម្ដងទៀតដោយធ្វើការទប់ទល់នឹងការបង្ក្រាបដោយហិង្សាក៏ដូចជាការឃុំខ្លួនដោយមិនត្រឹមត្រូវអ្នកតវ៉ាទាំងនោះ។



ព្រះសង្ឃ និងសកម្មជនចូលរួមអបអរទិវាបរិស្ថានអន្តរជាតិ

## អនុសាសន៍នានា

អង្គការលីកាដូសំណូមពរឲ្យរាជរដ្ឋាភិបាលកម្ពុជា សូមមេត្តាទទួលយកជំហានដូចខាងក្រោម ដើម្បីធ្វើឲ្យស្ថានភាពអ្នកការពារសិទ្ធិមនុស្សកាន់តែប្រសើរឡើង៖

►►► ធ្វើការស៊ើបអង្កេតជាបន្ទាន់ ដោយហ្មត់ចត់ និងមិនលំអៀង ទៅលើការគម្រាមកំហែង និងការវាយប្រហារទៅលើអ្នកការពារសិទ្ធិមនុស្ស និងអនុញ្ញាតឲ្យមានការកាត់ទោសជនល្មើសឲ្យបានពេញលេញស្របទៅតាមច្បាប់។

►►►បញ្ឈប់ការបង្រ្កាបដោយគ្មានដីកាត្រឹមត្រូវទៅលើប្រជាពលរដ្ឋដែលកំពុងអនុវត្តសិទ្ធិសេរីភាពនៃការជួបប្រជុំ និងការបញ្ចេញមតិដោយអហិង្សា។ បញ្ឈប់ការប្រើប្រាស់កម្លាំងរបស់កងកម្លាំងសន្តិសុខ ប្រឆាំងនឹងការធ្វើបាតុកម្ម និងកូដកម្មអហិង្សា។

►►►ធានាការពារឲ្យបានត្រឹមត្រូវសម្រាប់ការងារអ្នកកាសែត។ ធានាឲ្យបានថាច្បាប់ស្តីពីសារព័ត៌មាន ត្រូវបានយកមកប្រើប្រាស់នៅក្នុងរឿងក្តីតុលាការដែលពាក់ព័ន្ធនឹងអ្នកកាសែត នៅក្នុងគោលបំណងដើម្បីលើកកម្ពស់ការធានារដ្ឋធម្មនុញ្ញកម្ពុជាស្តីពីសេរីភាពនៃការបញ្ចេញមតិ។

►►►ធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌដើម្បីធានាថាច្បាប់នេះគោរពរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជានិងកាតព្វកិច្ចពាក់ព័ន្ធទៅនិងសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស ដែលកម្ពុជាបានផ្តល់សច្ចាប័ន។ ជាពិសេស បទប្បញ្ញត្តិទូលំទូលាយនិងមិនច្បាស់លាស់ ដូចជាបទប្បញ្ញត្តិស្តីពីការញុះញង់ និងបទប្បញ្ញត្តិទាំងអស់ ដែលប៉ះពាល់ដល់សេរីភាពនៃការបញ្ចេញមតិ ដូចជាការបរិហាកេរ្តិ៍ និងការប្រមាថ គួរតែត្រូវបានកែសម្រួល ដើម្បីធានាថាបទបញ្ញត្តិនេះមិនបានធ្វើឲ្យរំខានដល់សិទ្ធិសេរីភាពនៃការបញ្ចេញមតិ និងមិនអនុញ្ញាតឲ្យមានការចាប់ខ្លួនមិនត្រឹមត្រូវលើអ្នកការពារសិទ្ធិមនុស្ស។

►►►កែសម្រួលច្បាប់ស្តីពីការធ្វើបាតុកម្មអហិង្សា ដើម្បីធានាថាមាត្រារបស់ច្បាប់នោះលើកកម្ពស់រដ្ឋធម្មនុញ្ញកម្ពុជា នៅក្នុងលក្ខខណ្ឌនៃសេរីភាពការជួបប្រជុំគ្នា ជាពិសេសគឺមាត្រាទាំងឡាយដែលតម្រូវឲ្យស្ទើរតែរៀងរាល់ការជួបជុំជាសាធារណៈត្រូវការទទួលការអនុញ្ញាតជាមុនពីអាជ្ញាធរ។ ផ្តល់គោលការណ៍ណែនាំច្បាស់លាស់ ដែលអនុញ្ញាតឲ្យមានសេរីភាពក្នុងការជួបជុំ និងការបញ្ចេញមតិ។

►►►អនុវត្តអនុសាសន៍ដែលធ្វើឡើងដោយ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្សនៅកម្ពុជា ដែលទាក់ទងទៅនឹងការពង្រឹងនីតិរដ្ឋ និងស្ថាប័នតុលាការ។ ទាំងនេះគួរតែរួមបញ្ចូលទាំងការចាត់វិធានការដែលមានប្រសិទ្ធិភាពក្នុងការពង្រឹងឯករាជ្យភាព និងភាពមិនលម្អៀងនៃប្រព័ន្ធតុលាការ។ អំពាវនាវឲ្យប្រព័ន្ធតុលាការធ្វើការលើកកម្ពស់ឯករាជ្យភាពរបស់ខ្លួននៅក្នុងករណីទាំងអស់ ជាពិសេសនៅក្នុងករណីទាំងឡាយដែលពាក់ព័ន្ធនឹងអ្នកការពារសិទ្ធិមនុស្ស។

ថ្ងៃទី៤ ខែមករា ឆ្នាំ២០១៣
ករណីទី១
(សូមមើលករណីទី២)

អ្នកកាសែតត្រូវបានគម្រាមកំហែងនៅពេលរាយការណ៍អំពីអំពើពុករលួយ[១]
ឃុំ អូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ
ការគម្រាមកំហែង/ច្បាប់

- លោក ស៊ឹម ហៀម ដែលជាអ្នកកាសែតនៃសារព័ត៌មានមាតុភូមិ បានទទួលរងការគម្រាមកំហែងតាមរយៈទូរស័ព្ទថានឹងសម្លាប់លោក ហើយត្រូវបានគម្រាមកំហែងដោយស្នងការរងនគរបាលខេត្តបន្ទាយមានជ័យ លោក អ៊ុក កែវរតនៈ ថានឹងប្តឹងលោកពីបទបរិហាកេរ្តិ៍។ ការគម្រាមកំហែងនេះ បានកើតឡើងបន្ទាប់ពីលោកបានចេញផ្សាយនូវអត្ថបទមួយដែលបានលើកឡើងៈថាតុលាការខេត្ត បានទាមទារសំណូកចំនួន ២.០០០ ដុល្លារពីអ្នកភូមិអូរបីជាន់ជាច្រើននាក់ ដើម្បីធ្វើការវាស់ដីរបស់អ្នកទាំងនោះ។

ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៣
ករណីទី២
(សូមមើលករណីទី១)

អ្នកភូមិត្រូវបានគម្រាមកំហែងនៅពេលដែលបានរាយការណ៍ប្រាប់អ្នកកាសែតអំពីអំពើពុករលួយរបស់តុលាការ[២]
ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ
ការគម្រាមកំហែង/ច្បាប់

- លោក ញឿក សុធា ជាអ្នកភូមិម្នាក់ដែលបានរាយការណ៍ជូនទៅកាន់អ្នកកាសែតមាតុភូមិអំពីការទាមទារសំណូកប្រាក់ចំនួន ២.០០០ ដុល្លារ របស់តុលាការខេត្តបន្ទាយមានជ័យ ក៏ត្រូវបានគម្រាមកំហែងដោយស្នងការរងនគរបាលខេត្ត បន្ទាយមានជ័យ លោក អ៊ុក កែវរតនៈ ថានឹងប្តឹងលោកពីបទបរិហាកេរ្តិ៍ផងដែរ។

ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣
ករណីទី ៣
(សូមមើលករណីទី៦,៨)

សមាជិកសហជីពជាច្រើននាក់ ត្រូវបានរំលោភបំពាន[៣]
ស្រុកស្អាង ខេត្តកណ្តាល
អំពើហិង្សា/ការរំលោភបំពាន

- កម្មករចំនួនប្រាំពីនាក់ ដែលជាសមាជិកសហជីព CCAWDU ត្រូវបានវាយដំដោយដំបងបំពង់ទីប និងដុំថ្ម ដោយមនុស្សចំនួន ២០នាក់ ដែលត្រូវបាន ជួលដោយរោងចក្រអ៊ីហ្គាមែន។ហេតុការណ៍បានកើតឡើងនៅពេលដែលកម្មករទាំងនោះកំពុងធ្វើដំណើរត្រឡប់មកផ្ទះ បន្ទាប់ពីបានធ្វើបាតុកម្មទាមទារឲ្យ ទទួលយក កម្មករទាំង ៤១នាក់ ដែលត្រូវបានបញ្ឈប់ពីការងារនៅពេលព្យា-យាមបង្កើតជាសហជីពក្នុងឆ្នាំ២០០៧ មកធ្វើការងារវិញ។

ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣
ករណីទី៤

អ្នកកាសែតត្រូវបានគម្រាមកំហែងនៅពេលចេញផ្សាយអត្ថបទអំពីការកូដកម្ម[៤]
សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
អំពើហិង្សា/ការរំលោភបំពាន

- អ្នកកាសែតសារព័ត៌មានវិទ្យុសម្លេងប្រជាធិបតេយ្យ លោក តាត ឧត្តម ត្រូវបានមនុស្សមិនស្គាល់អត្តសញ្ញាណពីរនាក់រំលោភបំពាន នៅពេលដែលអ្នកទាំងពីរបានបុកម៉ូតូរបស់លោកដោយចេតនា។ ការរំលោភបំពាននេះ មានទាក់ទងនឹង អត្ថបទសារព័ត៌មានមួយដែលលោកបានចេញផ្សាយអំពីការធ្វើកូដកម្មរោងចក្រយីងស្លែន។

[១] របាយការណ៍ស៊ើបអង្កេតរបស់អង្គការលីកាដូ ដែលមិនត្រូវបានចេញផ្សាយ៖ BM006THI13។

[២] របាយការណ៍ស៊ើបអង្កេរបស់អង្គការលីកាដូ ដែលមិនត្រូវបានចេញផ្សាយ៖ BM007THI13។

[៣] ម៉ម គន្ធា, "សហជីព ពបាន និយាយថាសមាជិករបស់ខ្លួនត្រូវបានគេវាយដំជាលើកទីពីរ", ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៣, 25 February 2013, http://www.phnompenhpost.com/national/union-says-members-beaten-second-time

[៤] របាយការណ៍ស៊ើបអង្កេរបស់អង្គការលីកាដូ ដែលមិនត្រូវបានចេញផ្សាយ៖ PP023THI13។

**ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣**
**ករណីទី៥**

**អ្នកកាសែតត្រូវបានកោះហៅចូលក្នុងតុលាការ[៥]**
**ឃុំកំពង់ព្រះគគីរ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង**
ការគម្រាមកំហែង/ច្បាប់

- លោក នូ ច័ន្ទ ជាអ្នកកាសែតសារព័ត៌មានខ្មែរស្តាបនាសុភ័ណ្ឌ ត្រូវបានសាលាដំបូងខេត្តកំពង់ឆ្នាំងកោះហៅសាកសួរពាក់ព័ន្ធនឹងពាក្យបណ្តឹងពីបទបរិហាកេរ្តិ៍ ដែលត្រូវបានប្តឹងដោយប្រធាននគរបា លឃុំកំពង់គគីរ លោក ប៉ាង ភូមិសែន បន្ទាប់ពី លោ ក នូ ច័ន្ទ បា នរាយការណ៍អំពីការពាក់ព័ន្ធរបស់ប្រធាននគរបាលនោះជាមួយនឹងការរំលោភយកដីធ្លី។

**ថ្ងៃទី៥ ខែមិនា ឆ្នាំ២០១៣**
**ករណីទី៦**
**(សូមមើលករណីទី ៣,៨)**

**អ្នកកាសែតត្រូវបានកោះហៅចូលក្នុងតុលាការ[៦]**
**ខេត្តកណ្តាល**
ការរំលោភបំពានដោយប្រើអំណាច/ ការឃាត់ខ្លួន និងចាប់ខ្លួន

- សកម្មជនបរទេសចំនួន ៥នាក់ មកពីក្រុមសិទ្ធិកម្មករនៃយុទ្ធនាការសំលៀកបំពាក់ស្អាត (Clean Clothes Campaign) ត្រូវបានចាប់ខ្លួននៅក្រៅរោងចក្រ អ៊ីហ្គាមែន បន្ទាប់ពីអ្នកទាំងនោះបាននិយាយទៅកាន់កម្មករជាច្រើនដែលកំពុងធ្វើកូដកម្ម។
- នគរបាលបានអះអាងថាសកម្មជនទាំងនោះ ត្រូវបានឃាត់ខ្លួនដោយសារមិនបាន បង្ហាញលិខិតឆ្លងដែន ដែលនេះជាហេតុផលមួយដែលតែងតែលើកមកនៅពេលឃាត់ខ្លួនសកម្មជនបរទេស។ អ្នកទាំងនោះត្រូវបានដោះលែងវិញបន្ទាប់ពីបានឃាត់ខ្លួនអស់រយៈពេល ៦ម៉ោង។

**ថ្ងៃទី១១ ខែមិនា ឆ្នាំ២០១៣**
**ករណីទី៧**

**អ្នកតំណាងអ្នកភូមិបានទទួលរងការគម្រាមកំហែងថានឹងត្រូវគេសម្លាប់[៧]**
**ឃុំតាសាញ់ ស្រុកសំឡូត ខេត្តបាត់ដំបង**
ការគម្រាមកំហែង/គម្រាមកំហែងថានឹងត្រូវគេសម្លាប់

- លោក ហេង សុមាលី អ្នកតំណាងភូមិអូរស្គូត បានទទួលការគម្រាមកំហែងថានឹង សម្លាប់ពីមេនគរបាលស្រុកលោក ឈន ផេង និងមេនគរបាលឃុំ លោក ហែម សារុំ ហើយ និងមនុស្សពីរនាក់ផ្សេងទៀត។ ហេតុការណ៍នេះ បានកើតឡើងបន្ទាប់ពីលោក សុមាលី បាន និយាយទៅកាន់វិទ្យុអាស៊ីសេរីអំពីរបៀបដែលអាជ្ញាធរក្នុងតំបន់ឲ្យអ្នកភូមិ បង់ប្រាក់សម្រាប់ការវាស់វែងដីដែលត្រូវបានធ្វើឡើងដោយសិស្សិតស្ម័គ្រចិត្ត។

**ថ្ងៃទី១១ ខែមិនា ឆ្នាំ២០១៣**
**ករណីទី៨**
**(សូមមើលករណីទី ៣,៦)**

**សមាជិកសហជីព CCAWDAU ចំនួនបួននាក់ ត្រូវបានគេវាយដំយ៉ាងធ្ងន់ធ្ងរ[៨]**
**ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល**
អំពើហិង្សា/ការរំលោភបំពាន

- សមាជិកសហជីព CCAWDAU ចំនួនបួននាក់ ត្រូវបានគេវាយដំរហូតដល់សន្លប់ដោយដំបងឈើ បន្ទាប់ពីអ្នកទាំងនោះចាកចេញពីការតវ៉ាមួយដែលត្រូវបានធ្វើ ឡើងដោយកម្មករចំនួន២០០នាក់នៃរោងចក្រអ៊ីហ្គាមែន។
- អ្នកទាំងបួន បានមកឃ្លាំមើលការតវ៉ា និងផ្តល់ព័ត៌មានដល់កម្មករទាំងនោះនូវសិទ្ធិរបស់អ្នកទាំងនោះដោយយោងតាមច្បាប់ការងាររបស់កម្ពុជា។ អ្នកវាយប្រហារ មានចំនួន ១0នាក់ មកពីសហជីពផ្សេងទៀតដែលគាំទ្ររាជរដ្ឋាភិបាល និងត្រូវបានដឹកនាំដោយជំនួយការអ្នកគ្រប់គ្រងរោងចក្រអ៊ីហ្គាមែន។

[៥] របាយការណ៍ស៊ើបអង្កេតរបស់អង្គការលីកាដូ ដែលមិនត្រូវបានចេញផ្សាយ៖ KN008THI13។ សូមមើលផងដែរនូវរបាយការណ៍អង្គការលីកាដូ "ការវាយប្រហារ និងការគម្រាមកំហែងមកលើអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា៖២០១០-២០១២" ចេញផ្សាយខែធ្នូ ឆ្នាំ២០១២, ករណីទី៧៣។
[៦] Shane Worrell និង ឈៀង សុខា "សកម្មជនបរទេសត្រូវបានឃុំខ្លួន", កាសែតភ្នំពេញប៉ុស្តិ៍, ថ្ងៃទី៦ ខែមិនា ឆ្នាំ២០១៣, http://www.phnompenhpost.com/national/foreign-activists-detained
[៧] របាយការណ៍ស៊ើបអង្កេតរបស់អង្គការលីកាដូ ដែលមិនត្រូវបានចេញផ្សាយ៖ BB020DT13។
[៨] របាយការណ៍ស៊ើបអង្កេតរបស់អង្គការលីកាដូ ដែលមិនត្រូវបានចេញផ្សាយ៖ PP031AK13។

**ថ្ងៃទី១៣ ខែមិនា ឆ្នាំ២០១៣**
**ករណីទី៩**

### សកម្មជនតំបន់ព្រៃឡង់ជាច្រើននាក់ ត្រូវបានតុលាការកោះហៅ[៩]
### ឃុំអូរស្លឹកគ្រែ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ

ការគម្រាមកំហែង/ច្បាប់

- សកម្មជនព្រៃឈើចំនួន ៩នាក់ លោក ឈាង វុទ្ធី លោកព្រំ សុយ លោកហៀន ហៃ លោកសៅ ខន លោកមាស វន លោកមាស គៀង លោកម៉ោ ធា លោកនួន កេន និងលោកដួង ឆាយ ត្រូវបានសាលាដំបូងខេត្តកំពង់ធំកោះហៅសាកសួរ។ ដីកាកោះនោះ ពាក់ព័ន្ធនឹងពាក្យបណ្ដឹងដែលត្រូវបានធ្វើឡើងដោយអ្នកស្រី អុល រដ្ឋា ជាម្ចាស់ដីម្នាក់ដែលមានទំនាក់ទំនងល្អជាមួយអាជ្ញាធរ បន្ទាប់ពីអ្នកទាំងនោះបានព្យាយាមរារាំងអ្នកស្រីពីការឈូសឆាយដីព្រៃកាលពីឆ្នាំ ២០១១។

**ថ្ងៃទី១៣ ខែមិនា ឆ្នាំ២០១៣**
**ករណីទី១០**

### សកម្មជនតំបន់បឹងកក់ ត្រូវបានវាយដំដោយកងរាជអាវុធហត្ថ[១០]
### សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ការរំលោភបំពានលើសេរីភាពក្នុងការជួបជុំ/ អំពើហិង្សា និងការចាប់ខ្លួន

- កាលពីថ្ងៃទី១៣ ខែមិនា ឆ្នាំ២០១៣ ក្រុមអ្នកតវ៉ាអហិង្សាមួយក្រុមមកពីតំបន់បឹងកក់ ត្រូវបានបំបែកដោយហិង្សាដោយកងសន្តិសុខចម្រុះមួយក្រុម នៅចម្ងាយតែ ១00 ម៉ែត្រ ពី គេហដ្ឋានសម្ដេច នាយករដ្ឋមន្ត្រី នៅកណ្ដាលរាជធានីភ្នំពេញ។ ជាលទ្ធផលនៃការបង្ក្រាប អ្នកតវ៉ាចំនួន ៦ នាក់ ត្រូវបានរងរបួសយ៉ាងធ្ងន់ធ្ងរ រួមមានលោក លួស សាខន ស្វាមីរបស់សកម្មជនបឹងកក់ដែលត្រូ វ បានជាប់ឃុំអ្នកស្រី យ៉ោម បុប្ផា ដោយធ្មេញរបស់លោកមួយចំនួន បានបាក់នៅពេលលោកត្រូ វបានកងសន្តិសុខចំនួន ១0នាក់ ចាប់លោក។ ស្ត្រីម្នាក់ឈ្មោះ ញឹក សុផាត បានបាក់ដៃ រីឯលោកយាយ ង៉ែត យុន អាយុ៧0ឆ្នាំ បានសន្លប់បាត់ស្មារតី។

**ថ្ងៃទី២ ខែមេសា ឆ្នាំ២០១៣**
**ករណីទី១១**

### សកម្មជនដីធ្លីទទួលការគម្រាមកំហែងថានឹងត្រូវគេសម្លាប់[១១]
### ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់

ការគម្រាមកំហែង/គម្រាមកំហែងថានឹងត្រូវគេសម្លាប់

- លោក ជឿម ស្រី ជាសកម្មជនដីធ្លី បានទទួលការគម្រាមកំហែងថានឹងសម្លាប់ពីមនុស្សដែលមានអាវុធពីរនាក់មិនស្គាល់អត្តសញ្ញាណ។ នៅពេលដែលលោកត្រឡប់មកពីសិក្ខា សាលារបស់អង្គការអាដហុកស្ដីពីការរំលោភដីធ្លី មានមនុស្សពីរនា ក់ដើរមករកលោក ហើយបានបាញ់ទៅលើមេឃ និងប្រាប់លោកថាលោក និងគ្រួសាររបស់លោក នឹងត្រូវបានគេសម្លាប់ ប្រសិនបើលោកចូលរួមក្នុងការតវ៉ាណាមួយ។
- មេភូមិរបស់លោក បានបដិសេធដោយមេភូមិនោះមិនបានដឹងអំពីករណីនេះទេ ប៉ុន្តែនគរបាលស្រុកយល់ព្រមធ្វើការសើបអង្កេតបន្ថែម។

**ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៣**
**ករណីទី១២**

### បុគ្គលិកអង្គការអាដហុក ត្រូវបានអាជ្ញាធរធ្វើការសើបអង្កេតដោយមិនត្រឹមត្រូវ[១២]
### ខេត្តកណ្ដាល

ការគម្រាមកំហែង/ច្បាប់

- អ្នកសម្របសម្រួលអង្គការអាដហុកប្រចាំខេត្តរតនគិរី លោក ឆាយ ធី ត្រូវបានអាជ្ញាធរខេត្តស៊ើបអង្កេតពាក់ព័ន្ធនឹងករណីញុះញង់ឲ្យមានចលនាប្រឆាំងរាជរដ្ឋាភិបាល បន្ទាប់ពីលោកបានស្នើទៅអ្នកភូមិជនជាតិដើមភាគតិចថារាយថា អ្នកទាំងនោះអាចប្រើប្រាស់ការតវ៉ាអហិង្សា ជាមធ្យោបាយឲ្យរាជរដ្ឋាភិបាលដោះស្រាយជម្លោះដីធ្លីរបស់អ្នកទាំងនោះ។
- ការស៊ើបអង្កេត ត្រូវបានបើកទោះបីជាការពិតការតវ៉ាអហិង្សា ត្រូវបានចែងនៅក្នុងមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញប្រទេសកម្ពុជាក៏ដោយ។ អាជ្ញាធរបានបិទការស៊ើបអង្កេតនៅមួយសប្តាហ៍ក្រោយ។

[៩] សេចក្ដីប្រកាសព័ត៌មានរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "សាលាដំបូងខេត្តកំពង់ធំកោះហៅសកម្មជនសហគមន៍តំបន់ព្រៃឡង់ចំនួន ៩នាក់ មកពីស្រុកសណ្ដាន់ មកសាកសួរនៅថ្ងៃទី១៤ ខែមិនា ឆ្នាំ២០១៣", , http://www.cchrcambodia.org/index_old.php?url=media/media.php&p=alert_detail.php&alid=35&id=5

[១០] សេចក្ដីថ្លែងការណ៍របស់អង្គការ លីកាដូ៖ "អំពើហិង្សានៅតែកើតមានកាន់តែខ្លាំង ចាំបាច់ត្រូវរកដំណោះស្រាយ ចំពោះជម្លោះដីធ្លីក្នុងរាជធានីភ្នំពេញ" ចេញផ្សាយថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៣, http://www.licadho-cambodia.org/pressrelease.php?perm=316

[១១] របាយការណ៍ស៊ើបអង្កេរបស់អង្គការលីកាដូ ដែលមិនត្រូវបានចេញផ្សាយ៖ PS016THI13។

ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣
ករណីទី១៣

## ការតវ៉ារបស់សកម្មជនដីធ្លីត្រូវបានរារាំង[១៣]

រាជធានីភ្នំពេញ

ការបំពានលើសេរីភាពក្នុងការជួបជុំ/ អំពើហិង្សា និងការចាប់ខ្លួន

- សកម្មជនដីធ្លីជាច្រើន ត្រូវបានរារាំង និងបៀតបៀនដោយមន្ត្រីនគរបាលចំនួន ២០០នាក់ នៅពេលដែលអ្នកទាំងនោះតវ៉ានៅមុខទីស្នាក់ការគណបក្សប្រជាជនកម្ពុជា។ នៅ ពេលដែលនគរបាលព្យាយាមប្រាប់ទៅអ្នកតវ៉ាឲ្យបំបែកគ្នា មន្ត្រីម្នាក់បានព្យាយាមស្ទាបស្ត្រីជាសកម្មជនដីធ្លីតំបន់បឹងកក់ម្នាក់អ្នកនាង បូ ឆវី។

ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣
ករណីទី១៤

## កងរាជអាវុធហត្ថបង្ខំឲ្យព្រះសង្ឃសកម្មជនចេញពីវត្ត[១៤]

ឃុំល្វាស ស្រុកល្វាឯម ខេត្តកណ្តាល

ការរំលោភបំពានដោយប្រើអំណាច/ផ្សេងៗ

- ព្រះតេជគុណ ស៊ិន មុន ព្រះសង្ឃមួយអង្គដែលត្រូវបានគេដឹងថាព្រះអង្គចូលរួមក្នុងការលើកឡើងពីបញ្ហាសង្គម ត្រូវបានកងរាជអាវុធហត្ថប្រមាណ ៥០នាក់ បង្ខំឲ្យចាកចេញពីវត្តល្វាស។ មេគណសង្ឃស្រុក បានរារាំងព្រះអង្គ ដោយមិនឲ្យត្រឡប់មកវត្តព្រះអង្គវិញទេ។

ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣
ករណីទី១៥

## ការដើរក្បួនរបស់សកម្មជនដីធ្លី ត្រូវបានរារាំងដោយហិង្សា[១៥]

រាជធានីភ្នំពេញ

ការបំពានលើសេរីភាពក្នុងការជួបជុំ/ អំពើហិង្សា និងការចាប់ខ្លួន

- អ្នកតំណាងសហគមន៍បុរីកីឡា អ្នកស្រី អៀម លៀងសេង និងពលរដ្ឋរស់នៅតំបន់បឹងកក់ និងបុរីកីឡា ត្រូវបានរារាំងដោយហិង្សាពីក្រុមនគរបាល និងកងរាជអាវុធហត្ថប្រមាណ ២០០នាក់ ដែលប្រដាប់ដោយដំបង និងខែលបង្ក្រាបបាតុកម្ម ដោយមិនឲ្យដាក់ញត្តិទៅកាន់ទីស្នាក់ការគណបក្សប្រជាជនកម្ពុជានោះទេ។

ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៣
ករណីទី១៦

## មេបញ្ជាការកងទ័ព បានគម្រាមកំហែងមេភូមិ[១៦]

ឃុំតាងួន ស្រុកបូទុមសាគរ ខេត្តកោះកុង

ការគម្រាមកំហែង/ច្បាប់

- លោក ផាន់ អេង អតីតមេភូមិតាងួន ត្រូវបានគម្រាមកំហែងថានឹងចាប់ខ្លួន និងឃុំខ្លួន នៅពេលដែលលោកបានរារាំងការវាស់វែងដីដែលត្រូវបានធ្វើឡើងដោយបុគ្គលិករបស់ក្រុមហ៊ុន Union Development Group (UDG)។ ការគម្រាមកំហែង ត្រូវបានធ្វើឡើងដោយអ្នកឈរកាងឲ្យក្រុមហ៊ុន ដែលត្រូវបានអមដំណើរដោយទាហានពាក់ស័ក្តផ្កាយមួយ ម្នាក់ និងមនុស្សចំនួន ៦នាក់ផ្សេងទៀតដែលប្រដាប់ដោយអាវុធ។

ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣
ករណីទី១៧

## សកម្មជនដីធ្លីតំបន់បឹងកក់ ៤នាក់ ត្រូវបានវាយឲ្យសន្លប់[១៧]

សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ការបំពានលើសេរីភាពក្នុងការជួបជុំ/ អំពើហិង្សា និងការចាប់ខ្លួន

- ក្រុមអ្នកតវ៉ាមួយក្រុមដែលមានសមាជិក ៦០នាក់ មកពីតំបន់បឹងកក់ ត្រូវបានវាយដំយ៉ាងធ្ងន់ធ្ងរដោយកងសន្តិសុខមួយក្រុម នៅពេលដែលអ្នកទាំងនោះប្រមូលផ្តុំគ្នានៅសួនច្បារសាធារណៈនៅមុខគេហដ្ឋានរបស់សម្តេចនាយករដ្ឋមន្ត្រី។ អ្នកតវ៉ាទាំងនោះ បានប្រមូលផ្តុំគ្នាដើម្បីទាមទារឲ្យដោះលែងអ្នកស្រី យ៉ោម បុប្ផា អ្នកដឹកនាំម្នាក់ក្នុងសហគមន៍ ដើម្បីប្រឆាំងនឹងការរំលោភយកដីធ្លី ហើយជាអ្នកត្រូវបានតុលាការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារចំនួនបីឆ្នាំកាលពីខែធ្នូ ឆ្នាំ២០១២។

---

[១២] ផាក សេងលី "ករណីប្រឆាំងនឹងបុគ្គលិកអង្គ ការមិនមែនរដ្ឋាភិបាល ត្រូវបានលើកចោល", ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៤, http://www.phnompenhpost.com/national/case-against-ngo-worker-dropped

[១៣] យូត សុភ័ក្រ្តចរិយា, "ស្ត្រី និងនគរបាលប៉ះទង្គិចគ្នាពាក់ព័ន្ធនឹងការតវ៉ារឿងដីធ្លី", ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣, http://www.phnompenhpost.com/national/women-cops-clash-land-protest

[១៤] របាយការណ៍ស៊ើបអង្កេតរបស់អង្គការលីកាដូ ដែលមិនត្រូវបានចេញផ្សាយ៖ PP049THI13។

- កងនគរបាល នគរបាលបង្ក្រាបបាតុកម្ម និងសន្តិសុខខណ្ឌប្រមាណពី ៦០ ទៅ៨០នាក់ បានប្រើប្រាស់ខែល និងកម្លាំងបាយដើម្បីរុញអ្នកតវ៉ាថយក្រោយរហូតដល់អគារមជ្ឈមណ្ឌលហុងកុងប្រមាណ៥០០ម៉ែត្រ។
- ជាលទ្ធផលនៃការបង្ក្រាបនេះ អ្នកតវ៉ាចំនួន ៦នាក់ បានរងរបួសយ៉ាងធ្ងន់ធ្ងរ រួមមានលោក លួស សាខន ស្វាមីរបស់អ្នកស្រី យ៉ោម បុប្ផា ដែលលោកបានបាក់ធ្មេញនៅពេលដែលលោកត្រូវបានកងសន្តិសុខប្រមាណ ១០នាក់ ចាប់រូបលោក។ ស្ត្រីម្នាក់ឈ្មោះ ញឹក សុផាត បានបាក់ដៃ ហើយលោកយាយ ង៉ែត យុន ដែលមានអាយុ ៧០ឆ្នាំ បានសន្លប់បាត់ស្មារតី។
- យ៉ាងតិចណាស់មានមនុស្សចំនួន ៣នាក់ ត្រូវបានឃាត់ខ្លួនបណ្ដោះអាសន្នដោយអាជ្ញាធរ។

ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣
**ករណីទី១៨**

### កងសន្តិសុខឯកជន ឃាត់ខ្លួនអ្នកធ្វើកូដកម្ម[១៨]

រាជធានីភ្នំពេញ

ការបំពានលើសេរីភាពក្នុងការជួបជុំ/ អំពើហិង្សា និងការចាប់ខ្លួន

- កងសន្តិសុខឯកជន ដែលមានកងរាជអាវុធហត្ថ និងនគរបាលបង្ក្រាបបាតុកម្មនៅខាងក្រោយ បានបំបែកដោយហិង្សាលើការធ្វើកូដកម្មអហិង្សារបស់បុគ្គលិកកាស៊ីណូណាហ្គាវើល។
- កងសន្តិសុខបានឃាត់ខ្លួនមនុស្សចំនួន ១៩នាក់ ដែលរួមទាំងមេដឹកនាំសហជីព និងបុគ្គលិកដែលមិនគោរពតាមបទបញ្ជាឲ្យបំបែក។ បុគ្គលិកជាច្រើន បានតវ៉ាដើម្បីទាមទារតំឡើងប្រាក់ឈ្នួលអប្បបរមាចំនួន ១៥០ ដុល្លារអាមេរិកក្នុងមួយខែ។

ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៣
**ករណីទី១៩**

### ការតវ៉ារបស់សហគមន៍បឹងកក់ ត្រូវបានរំលោភបំពានដោយនគរបាល[១៩]

រាជធានីភ្នំពេញ

ការបំពានលើសេរីភាពក្នុងការជួបជុំ/ អំពើហិង្សា និងការចាប់ខ្លួន

- ពលរដ្ឋនៅក្នុងសហគមន៍បឹងកក់ចំនួន ៣០នាក់ ត្រូវបានរំលោភបំពានដោយនគរបាល នៅពេលដែលអ្នកទាំងនោះកំពុងតវ៉ានៅមុខព្រះបរមរាជវាំង ដោយព្យាយាមដាក់ញត្តិថ្វាយសម្ដេចម៉ែ ដើម្បីធ្វើព្រះរាជអន្តរាគមន៍នៅក្នុងករណីរបស់អ្នកស្រីយ៉ោម បុប្ផា។
- នៅពេលដែលអ្នកតវ៉ាបានមកដល់មុខព្រះបរមរាជវាំង នគរបាល និងនគរបាលបង្ក្រាបបាតុកម្មប្រមាណ ៦០នាក់ បានព្យាយាមទាញយកបដារូបអ្នកស្រី យ៉ោម បុប្ផា ដែលអ្នកតវ៉ាកំពុងកាន់ ដែលនេះធ្វើឲ្យអ្នកតវ៉ាមួយចំនួនយកសារុងរបស់អ្នកទាំងនោះ តវ៉ាជំទាស់នឹងនគរបាលទាំងនោះដើម្បីព្យាយាមឲ្យនគរបាលទាំងនោះថយ។
- កាលពីពេលព្រឹក នគរបាលបានរារាំងអ្នកតវ៉ាប្រមាណ ១០០នាក់ ដោយមិនឲ្យចេញពីសហគមន៍របស់អ្នកទាំងនោះដើម្បីចូលរួមការតវ៉ានោះទេ។
- យ៉ាងតិចណាស់មានអ្នកតវ៉ាចំនួន ២នាក់ បានសន្លប់ ហើយមួយភាគបីបានរងរបួស។

ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៣
**ករណីទី២០**

### កងសន្តិសុខ បានវាយដំទៅលើអ្នកតវ៉ាអហិង្សា[២០]

រាជធានីភ្នំពេញ

ការបំពានទៅលើសេរីភាពក្នុងការជួបជុំ/ អំពើហិង្សា និងការចាប់ខ្លួន

- កងនគរបាល និងកងសន្តិសុខខណ្ឌ បានវាយដំទៅលើការតវ៉ាដោយអហិង្សាដែលត្រូវបានធ្វើឡើងដោយសកម្មជនសិទ្ធិដីធ្លីមួយចំនួននៅមុខសាលារាជធានី ភ្នំពេញ។ អ្នកតវ៉ា ទាមទារឲ្យលោក ប៉ា សុជាតិវង្ស គោរពពាក្យសន្យារបស់លោក ក្នុង កា រដោះស្រាយករណីជ ម្លោះដីធ្លីរបស់អ្នកទាំងនោះ។
- អ្នកតវ៉ាចំនួន ៣នាក់ រួមទាំងក្មេងស្រីម្នាក់អាយុ ១៤ឆ្នាំ បានរងរបួសពីការវាយដំនោះ។

---

[១៥] របាយការណ៍ស៊ើបអង្កេតរបស់អង្គការលីកាដូ ដែលមិនត្រូវបានចេញផ្សាយ៖ PP048OFEA13។

[១៦] របាយការណ៍ស៊ើបអង្កេតរបស់អង្គការលីកាដូ ដែលមិនត្រូវបានចេញផ្សាយ៖ KK019THI13។

[១៧] របាយការណ៍ស៊ើបអង្កេតរបស់អង្គការលីកាដូ ដែលមិនត្រូវបានចេញផ្សាយ៖ PP075PA13។

[១៨] Shane Worrell និងឃួត សុភ័ក្ត្រចរិយា, "ការតវ៉ារបស់បុគ្គលិកក្រុមហ៊ុនណាហ្គាវើលបានបញ្ចប់ដោយហិង្សា", ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣, http://www.phnompenhpost.com/national/nagaworld-strike-ends-force។

**ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៣**
**ករណីទី២១**

### ការតវ៉ាដោយអត់អាហារអហិង្សា ត្រូវបានបំបែកនៅរម្យណីយដ្ឋានវត្តភ្នំ[២១]
### សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ការបំពានទៅលើសេរីភាពក្នុងការជួបជុំ/ អំពើហិង្សា និងការចាប់ខ្លួន

- សកម្មជនតំបន់បឹងកក់ និងបុរីកីឡាមួយក្រុម ត្រូវបានវាយដំ បន្ទាប់ពីធ្វើការតវ៉ាដោយអហិង្សា ដោយការបង្អត់អាហារខ្លួនឯង ដើម្បីតវ៉ាជំទាស់នឹងការបើកសម័យប្រជុំដំបូងនៃរដ្ឋសភាជាតិអណត្តិថ្មីទោះជាមិនមានវត្តមានរបស់សមាជិកសភាមកពីគណបក្សជំទាស់ក៏ដោយ។
- ការវាយដំ បានកើតឡើងនៅពេលល្ងាច នៅពេលការតវ៉ាបានថយចុះត្រឹមប្រមាណ ២០នាក់។ កងរាជអាវុធហត្ថ និងកងសន្តិសុខស្លៀកពាក់ស៊ីវិលប្រមាណ ៣០ ទៅ៥០នាក់ បានវាយដំទៅលើអ្នកតវ៉ាដោយដំបង កាំភ្លើង និងជំពាមកៅស៊ូ។
- យ៉ាងតិចណាស់ អ្នកតំណាងសហគមន៍ចំនួន ១០នាក់ បានរងរបួស រួមលោកយាយអាយុ ៧២ឆ្នាំម្នាក់ និងមនុស្សបីនាក់ផ្សេងទៀត ត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យ។ លើសពីនេះ អ្នកឃ្លាំមើលសិទ្ធិមនុស្សម្នាក់ ក៏ត្រូវបានរងរបួសលើទ្រូង ហើយអ្នកកាសែតមួយចំនួន ត្រូវបានគេឆក់ រីឯអ្នកកាសែតម្នាក់ កាមេរ៉ារបស់លោក ត្រូវបានគេកំទេច។

**ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៣**
**ករណីទី២២**

### ការដើរក្បួនក្នុងទិវាគ្រូបង្រៀនអន្តរជាតិ ត្រូវបានរារាំងដោយកងរាជអាវុធហត្ថ[22]
### សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ការបំពានលើសេរីភាពក្នុងការជួបជុំ/ អហិង្សា

- ការប្រមូលផ្តុំមួយ ដែលត្រូវបានរៀបចំឡើងដោយសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ (CITA) និងដែលមានការចូលរួមពីសមាជិកប្រមាណ ២០០នាក់ និងប្រធានសមាគមលោក រ៉ុង ឈុន ត្រូវបានរារាំងដោយនគរបាលប្រមាណ ៣០នាក់។ គ្រូបង្រៀន មានគម្រោងនឹងប្រមូលផ្តុំគ្នានៅថ្ងៃទិវាគ្រូបង្រៀនពិភពលោក ដើម្បីដាក់ញត្តិអំពាវនាវឲ្យមានការតំឡើងប្រាក់ខែគ្រូដល់ ១លានរៀល (២៣៧ ដុល្លារ) ក្នុងមួយខែ។

**ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣**
**ករណីទី២៣**

### នគរបាលវាយដំទៅលើសកម្មជនដីធ្លី[២៣]
### រាជធានីភ្នំពេញ

ការបំពានលើសេរីភាពក្នុងការជួបជុំ/ អំពើហិង្សា និងការចាប់ខ្លួន

- នគរបាល បានដាល់លើអ្នកតវ៉ា និងវាយដំអ្នកទាំងនោះនឹងដំបង នៅពេលដែលនគរបាលទាំងនោះកំពុងបំបែកសកម្មជនដីធ្លីចំនួន ២៥០ នាក់ យ៉ាងហិង្សា ដែលអ្នកទាំងនោះអំពាវនាវដល់អភិបាលរាជធានីភ្នំពេញ លោក ប៉ាសុជាតិវង្ស ឲ្យគោរពពាក្យសន្យារបស់លោក ក្នុងការដោះស្រាយករណីជម្លោះដីធ្លីរបស់អ្នកទាំងនោះ។ ស្ត្រីចំនួនបីនាក់ បានសន្លប់នៅក្នុងអំពើហឹង្សានោះ។

**ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣**
**ករណីទី២៤**

### កងសន្តិសុខ វាយដំលើព្រះសង្ឃ និងអ្នកតវ៉ា[២៤]
### រាជធានីភ្នំពេញ

ការបំពានលើសេរីភាពនៃការជួបជុំ/ អំពើហិង្សា និងការចាប់ខ្លួន

- កងសន្តិសុខខណ្ឌដូនពេញ បានវាយដំលើព្រះសង្ឃ និងអ្នកតវ៉ាពីរនាក់ នៅពេលដែលអាជ្ញាធរព្យាយាមបំបែកយ៉ាងហិង្សាទៅលើការតវ៉ាដែលត្រូវបានធ្វើឡើងដោយពលរដ្ឋតំបន់បឹងកក់ និងអ្នកគាំទ្រ។
- អំពើហិង្សា បានកើតឡើងនៅពេលដែលកងសន្តិសុខជាច្រើន ចាប់ផ្តើមសែងស្ត្រីមួយក្រុមដែលបិទមហាវិថីព្រះមុនីវង្ស ដែលធ្វើឲ្យព្រះតេជគុណ ដើម ឈន ស្តីបន្ទោសដល់សន្តិសុខទាំងនោះ ដែលក្រោយមកធ្វើឲ្យកងសន្តិសុខទាំងនោះតបតទៅវិញដោយហិង្សា។

---

[១៩] ឃួត សុភ័ក្រ្តចរិយា, "សកម្មជន និងនគរបាលប៉ះទង្គិចគ្នានៅមុខព្រះបរមរាជវាំង", ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣, http://www.phnompenhpost.com/national/activists-cops-clash-palace

[២០] Shane Worrell, "អ្នកតវ៉ាត្រូវបានវាយដំដោយកងសន្តិសុខ", ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣, http://www.phnompenhpost.com/national/protesters-beaten-guards

[២១] សេចក្តីប្រកាសព័ត៌មានរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, "ការបង្រ្កាបយ៉ាងធ្ងន់ធ្ងរទៅលើការជួបជុំដោយអហិង្សានៅរម្យណីយដ្ឋានវត្តភ្នំ ធ្វើឲ្យមនុស្ស ៥នាក់រងរបួស", ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣, http://www.cchrcambodia.org/index_old.php?url=media/media.php&p=alert_detail.php&alid=44&id=5 September 23rd, 2014; Simon Marks និង Kevin Doyle, "អំពើហិង្សា ការវាយដំរបស់នគរបាលទៅលើអ្នកតវ៉ាដោយអហិង្សា", ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៤, https://www.cambodiadaily.com/archives/violent-mob-police-attack-peaceful-protesters-42892/

[២២] ទេព និមល, "ការប្រមូលផ្តុំថ្ងៃគ្រូបង្រៀនពិភពលោក ត្រូវខកខាន" ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៣, http://www.phnompenhpost.com/national/teachers%E2%80%99-rally-thwarted

- អ្នកតវ៉ាម្នាក់ បានរងរបួស នៅពេលដែលលោកព្យាយាមជួយព្រះតេជគុណអង្គនោះ ហើយមនុស្សដទៃទៀតត្រូវបានគេវាយចំថ្ពាមនៅពេលដែលអ្នកទាំងនោះព្យាយាមថតនូវអំពើហិង្សានោះ។

ថ្ងៃទី២ ខែមករា ឆ្នាំ២០១៤

ករណីទី២៥

## ព្រះសង្ឃ និងបុគ្គលិកមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ ត្រូវបានចាប់ខ្លួនដោយខុសច្បាប់[២៥]

ត្បែងមានជ័យ ខេត្តព្រះវិហារ

ការរំលោភបំពានដោយប្រើអំណាច/ ការឃាត់ខ្លួន និងចាប់ខ្លួន

- ព្រះសង្ឃពីរអង្គ ប៊ុត ប៊ុនតេញ និងប៊ុន ថេង ជាមួយនឹងបុគ្គលិកមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍បីនាក់លោក បូ ពៅ ឯម សារុំ និងលោក ឈីន សំបូរ ត្រូវបានចាប់ខ្លួនខណៈពេលចេញពីការតវ៉ាអហិង្សារបស់អ្នកភូមិជនជាតិដើមភាគតិចគួយពាក់ព័ន្ធនឹងការបាត់បង់ដីធ្លីរបស់អ្នកទាំងនោះ។
- ការចាប់ខ្លួន បានកើតឡើងនៅពេលដែលកងរាជអាវុធហត្ថប្រមាណ ២០នាក់ ព័ទ្ធក្រុមអ្នកទាំងនោះ និងនាំអ្នកទាំងនោះទៅកាន់ស្នងការនគរបាលដោយមិនមានការពន្យល់មូលហេតុ។ អភិបាលស្រុក លោក ប៉ាង យាត់ បានអះអាងថាអ្នកទាំងនោះមិនត្រូវបានចាប់ខ្លួនទេ ប៉ុន្តែជាការ "អញ្ជើញ" អ្នកទាំងនោះមកសាកសួរ។
- ព្រះតេជគុណ ប៊ុត ប៊ុនតេញ មានសង្ឃដីកាថានគរបាលបានគម្រាមកំហែងព្រះអង្គ និងបង្ខំព្រះអង្គបន្ទោបង់នៅមុខអ្នកទាំងនោះ ជាជាងអនុញ្ញាតឲ្យព្រះអង្គចូលបន្ទប់ទឹក។ ព្រះអង្គ មានសង្ឃដីកាថា ព្រះអង្គត្រូវបានគេប្រាប់ថានគរបាលបានទទួលបញ្ជាឲ្យផ្សឹកព្រះអង្គ និងព្រះតេជគុណ ប៊ុន ថេង ប៉ុន្តែអ្នកទាំងនោះខកខានទៅវិញព្រោះអ្នកភូមិ ១០០នាក់ បាននៅជុំវិញវត្តដែលជាកន្លែងឃាត់ខ្លួនព្រះអង្គ។
- បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងព្រះសង្ឃទាំងនោះ ត្រូវបានដោះលែងនៅព្រឹកថ្ងៃបន្ទាប់។

ថ្ងៃទី២ ខែមករា ឆ្នាំ២០១៤

ករណីទី២៦

## អ្នកការពារសិទ្ធិមនុស្សបីនាក់ ត្រូវបានចាប់ខ្លួននៅក្នុងការបង្ក្រាបយ៉ាងហិង្សា[២៦]

រាជធានីភ្នំពេញ

ការបំពានលើសេរីភាពនៃការជួបជុំ/ អំពើហិង្សា និងការចាប់ខ្លួន

- នៅថ្ងៃទី២ និងទី៣ ខែមករា កងកម្លាំងបានចាប់ខ្លួនមនុស្សចំនួន ២៣នាក់ ដែលរួមមានកម្មកររោងចក្រ និងអ្នកការពារសិទ្ធិមនុស្ស អំឡុងពេលនៃការបង្ក្រាបយ៉ាងហិង្សាមកលើកម្មកររោងចក្រដែលតវ៉ានៅទីតាំងចំនួនពីរខុសគ្នានៅក្នុងរាជធានីភ្នំពេញ។ យ៉ាងតិចណាស់មានមនុស្សចំនួន ៤នាក់ ត្រូវបានសម្លាប់ ហើយជាង ២០នាក់ បានរងរបួសដោយគ្រាប់កាំភ្លើងនៅពេលមានការបង្ក្រាបថ្ងៃទី៣ ខែមករា។
- មនុស្សបីនាក់ក្នុងចំណោមអ្នកដែលត្រូវបានគេចាប់ខ្លួននៅក្នុងការបង្ក្រាប គឺជាអ្នកការពារសិទ្ធិមនុស្ស៖ លោក វន់ ពៅ ប្រធានសមាគម IDEA លោក ច័ន្ទ ពុទ្ធិស័ក អ្នកការពារសិទ្ធិមនុស្សមកពីសហគមន៍បឹងកក់ និងលោក ថេង សាវឿន អ្នកសម្របសម្រួលសមាគមកសិករ (CCFC) និងលោក សុគន្ធ សម្បត្តិពិសិដ្ឋ បុគ្គលិករបស់សហជីព CLaRi-Cambodia (មជ្ឈមណ្ឌលសម្រាប់សិទ្ធិការងារកម្ពុជា)។
- ទីកន្លែងដែលអ្នកទាំង ២៣ ត្រូវបានឃាត់ខ្លួន ត្រូវបានលាក់បាំងអស់រយៈពេល ៥ថ្ងៃ រហូតដល់មន្ត្រីបានបញ្ជាក់ថាអ្នកទាំងនោះ ត្រូវបានបញ្ជូនទៅកាន់ពន្ធនាគារ ម៣ ដែលជាពន្ធនាគារនៅតំបន់ដាច់ស្រយាលនៅក្នុងខេត្តកំពង់ចាម។

[២៣] យូត សុភ័ក្រ្តចរិយា, "នគរបាលវាយដំសកម្មជនបុរីកីឡាដែលបានបិទផ្លូវ", ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣, http://www.phnompenhpost.com/national/police-beat-borei-keila-activists-blocking-road

[២៤] យូន សុភ័ក្រ្តចរិយា, "អ្នកតវ៉ា ត្រូវបានវាយដំនៅមុខសាលារាជធានី", ភ្នំពេញប៉ុស្តិ៍, http://www.phnompenhpost.com/national/protesters-beaten-city-hall

[២៥] Julia Wallace និង ឃី សុវុទ្ធី, "ព្រះសង្ឃសកម្មជន អ្នកធ្វើការសិទ្ធិមនុស្ស ត្រូវបានឃាត់ខ្លួនបន្ទាប់ពីមានការតវ៉ានៅខេត្តព្រះវិហារ", The Cambodia Daily, ថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤, https://www.cambodiadaily.com/archives/activist-monks-ngo-workers-held-after-preah-vihear-protest-49962/; "នគរបាលដោះលែងព្រះសង្ឃ និងអ្នកធ្វើការសិទ្ធិមនុស្សដែលត្រូវបានឃាត់ខ្លួន", The Cambodia Daily, ថ្ងៃទី៤ ៥ ខែមករា ឆ្នាំ២០១៤, https://www.cambodiadaily.com/archives/police-free-detained-monks-rights-workers-50064/

- អ្នកការពារសិទ្ធិមនុស្សចំនួន ៣នាក់ ត្រូវបានផ្តន្ទាទោសជាមួយជនជាប់ចោទចំនួន ២០នាក់ផ្សេងទៀត និងព្យួរទោស បន្ទាប់ពីមានសវនាការដែលមិនមែនជាការជំនុំជម្រះប្រកបដោយយុត្តិធម៌នោះទេ។ អ្នកទាំងនោះ ត្រូវបានផ្តន្ទាទោសពន្ធនាគារចំនួន ៤ និង ៤ឆ្នាំកន្លះ និងពិន័យជាប្រាក់ ២០០០ ដុល្លារ។ ទោះបីជាទោសត្រូវបានព្យួរ ប្រសិនបើអ្នកទាំងនោះត្រូវបានផ្តន្ទាទោសពីបទល្មើសផ្សេង នោះទោសនោះនឹងត្រូវបានអនុវត្តទៅលើអ្នកទាំងនោះវិញ។

ថ្ងៃទី៦ ខែមករា ឆ្នាំ២០១៤
**ករណីទី២៧**

**មេដឹកនាំ និងលេខាធិការនៃសហជីព ត្រូវបានគេគម្រាមកំហែង[២៧]**
ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម

ការគម្រាមកំហែង/ អំពើហិង្សា

- ឈន ធៀង ប្រធានសម្ព័ន្ធសហជីពកម្ពុជា (CATU) និងយៀម ស្រីអូន លេខាធិការសហជីព ត្រូវបានគម្រាមកំហែងដោយនគរបាលមួយក្រុមដែលមិនស្គាល់អត្តសញ្ញាណ បន្ទាប់ពីអ្នកទាំងនោះបានរៀបចំកម្មករជាច្រើនធ្វើការតវ៉ាទាមទារតំឡើងប្រាក់ខែ។

ថ្ងៃទី៦ ខែមករា ឆ្នាំ២០១៤
**ករណីទី២៨**

**សកម្មជនបឹងកក់ ៥នាក់ ត្រូវបានចាប់ខ្លួន និងឃុំខ្លួន ដោយសារដឹកនាំការដើរក្បួនអហិង្សា[២៨]**
រាជធានីភ្នំពេញ

ការបំពានរបស់អាជ្ញាធរ/ ការឃាត់ខ្លួន និងចាប់ខ្លួន

- សកម្មជនដីធ្លីមកពីតំបន់បឹងកក់ចំនួន ៥នាក់ អ្នកស្រី ទេព វន្នី យ៉ោម បុប្ផា បូ ឆវី ផាន់ ឈុនរ៉េត និងសុង ស្រីលាភ ត្រូវបានចាប់ខ្លួន និងឃាត់ខ្លួនដោយនគរបាល បន្ទាប់ពីដឹកនាំការដើរក្បួនទៅកាន់ស្ថានទូតបារាំង ដើម្បីទាមទារឲ្យមានការដោះលែងអ្នកតវ៉ាចំនួន ៥នាក់ ដែលត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី២ ខែមករា ឆ្នាំ២០១៤។
- អ្នកទាំងនោះ ត្រូវបានដោះលែងក្នុងរយៈពេល ៨ម៉ោងក្រោយ បន្ទាប់ពីអ្នកទាំងនោះយល់ព្រមចុះហត្ថលេខាលើលិខិតដែលថាអ្នកទាំងនោះនឹងបញ្ឈប់ការតវ៉ាផ្សេងទៀតជាបណ្តោះអាសន្ន។

ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤
**ករណីទី២៩**

**ប្រធាន និងបុគ្គលិកអង្គការមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ត្រូវបានគម្រាមកំហែង**

**ដោយសារការរិះគន់គណបក្សជំទាស់[២៩]**
រាជធានីភ្នំពេញ

ការគម្រាមកំហែង/ អំពើហិង្សា

- បុគ្គលិក និងប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានទទួលរងការគម្រាមកំហែងថានឹងប្រើហិង្សា និងសម្លាប់ បន្ទាប់ពីប្រធានមជ្ឈមណ្ឌល លោក អ៊ូ វិរៈ បានរិះគន់ការប្រើប្រាស់វោហាសាស្ត្រប្រឆាំងជនជាតិវៀតណាមរបស់គណបក្សសង្គ្រោះជាតិ។ ការគម្រាមកំហែងជាច្រើន ត្រូវបានផ្ញើតាមរយៈបណ្តាញទំនាក់ទំនងសង្គម ហ្វេសប៊ុក។

ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤
**ករណីទី៣០**

**បុគ្គលិកអង្គការ អាដហុក ត្រូវបានវាយដំនៅពេលស៊ើបអង្កេតលើក្រុមហ៊ុនអភិវឌ្ឍន៍[៣០]**
ឃុំសុខុម ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគិរី

អំពើហិង្សា/ ការរំលោភបំពាន

- លោក សុខ រដ្ឋា អ្នកសម្របសម្រួលអង្គការអាដហុកប្រចាំខេត្តមណ្ឌលគិរី បានអះអាងថាអ្នកតំណាងម្នាក់របស់ក្រុមហ៊ុនដែលលោកកំពុងស៊ើបអង្កេត បានព្យាយាមបើកបុកលោក និងសហការីពីរនាក់ទៀត។

[២៦] សេចក្តីថ្លែងការណ៍អង្គការ លីកាដូ, "ប្រជាពលរដ្ឋបានស្លាប់ និងរងរបួស ដោយសារកងកម្លាំងរបស់អាជ្ញាធរ ក្នុងអំឡុងមានភាពវឹកវរនៅក្នុងរាជធានីភ្នំពេញ" ចេញផ្សាយថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤ http://www.licadho-cambodia.org/pressrelease.php?perm=334

[២៧] របាយការណ៍ស៊ើបអង្កេតរបស់អង្គការលីកាដូ ដែលមិនត្រូវបានចេញផ្សាយ៖ KC002THI14។

- ព្រឹត្តិការណ៍នេះ បានកើតឡើងនៅពេលដែលលោក និងសហការីរបស់លោកពីរនាក់គឺ លោក ប៊ុន ចន្ថា និងលៀ កៅ កំពុងស៊ើបអង្កេតលើពាក្យបណ្តឹងទៅលើក្រុមហ៊ុនវីឡាអភិវឌ្ឍន៍ ពាក់ព័ន្ធនឹងការឈូសឆាយដីរបស់អ្នកភូមិ។ នៅពេលដែលអ្នកទាំងនោះជិតដល់តំបន់នោះ មានរថយន្តមួយបានបើកមកយ៉ាងលឿនឆ្ពោះទៅរកអ្នកទាំងនោះ និងព្យាយាមបុកអ្នកទាំងនោះ។
- មេដឹកនាំសហគមន៍មកពីឃុំចំណាំបានអ្នកបើករថយន្ត គឺជាកម្មករក្រុមហ៊ុនវីឡាអភិវឌ្ឍន៍។

ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៤
ករណីទី៣១

មេដឹកនាំសហជីពគ្រូបង្រៀន ត្រូវបាននគរបាលគម្រាមកំហែង[៣១]
ឃុំកំពង់ឆ្នាំង ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង

ការគម្រាមកំហែង/ច្បាប់

- បន្ទាប់ពីរៀបចំការធ្វើកូដកម្មទាមទារតំឡើងប្រាក់ខែ លោក ជួន ចាំ អ្នកដឹកនាំសហជីពគ្រូបង្រៀនខេត្តកំពង់ឆ្នាំង ត្រូវបានប្រធានការិយាល័យនគរបាលព្រហ្មទណ្ឌ និងប្រធាននគរបាលបង្ក្រាបបាតុកម្មខេត្តកោះហៅសាកសួរ។

ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៤
ករណីទី៣២

មេដឹកនាំសមាគម IDEA ត្រូវបានចាប់ខ្លួនអំឡុងពេលពិធីបួងសួង[៣២]
រាជធានីភ្នំពេញ

ការរំលោភបំពានរបស់អាជ្ញាធរ/ ការឃាត់ខ្លួន និងចាប់ខ្លួន

- ការប្រមូលផ្តុំមួយ ដែលត្រូវបានធ្វើឡើងដោយអំពាវនាវឲ្យមានការដោះលែងកម្មករទាំង ២០ នាក់ និងអ្នកការពារសិទ្ធិមនុស្ស ៣នាក់ ដែលត្រូវបានចាប់ខ្លួនកាលពីដើមខែមករា និងទាមទារឲ្យតំឡើងប្រាក់ឈ្នួលអប្បបរមា ត្រូវបានបញ្ចប់ដោយការចាប់ខ្លួនលោក សុខ ឈុនអឿន អនុប្រធានសមាគម IDEA។ ប្រធានសមាគម លោក វ៉ន់ ពៅ គឺស្ថិតក្នុងចំណោមមនុស្សទាំង ២៣នាក់ ដែលត្រូវបានចាប់ខ្លួនកាលពីដើមខែមករា។
- នៅម៉ោង ៤ល្ងាច មុនពេលមានការប្រមូលផ្តុំ អ្នកសារព័ត៌មាន និងអ្នកឃ្លាំមើលសិទ្ធិមនុស្ស ដែលកំពុងរង់ចាំក្រុមធំដែលនឹងមកដល់នៅវត្តឧណ្ណាលោម ត្រូវបានបង្ខំឲ្យចាកចេញដោយកងសន្តិសុខ និងមនុស្សស្លៀកពាក់ស៊ីវិលប្រមាណ ៥០នាក់ ដែលមានពាក់មួកសុវត្ថិភាព ក្រុមមនុស្សនោះបានផ្លាស់ទៅប្រមូលផ្តុំគ្នានៅមុខព្រះអង្គដងកើ មុខព្រះបរមរាជវាំង ហើយត្រូវបានតាមយ៉ាងជិតដោយកងសន្តិសុខ និងមនុស្សស្លៀកពាក់ស៊ីវិលទាំងនោះ។
- នៅម៉ោងប្រមាណ ៥ល្ងាច ដោយមិនមានការស្រុះស្រួលគ្នា កងសន្តិសុខបានបំភិតបំភ័យ និងរុញអ្នកតវ៉ាអស់ជាងមួយម៉ោង។ អ្នករៀបចំ និងអ្នកឃ្លាំមើលសិទ្ធិមនុស្ស បានឆ្លើយតបដោយការគៀកដៃគ្នា ច្រៀងចម្រៀងជាតិ និងបទចម្រៀងការតស៊ូអហិង្សាជាច្រើន។ អំឡុងពេលនោះ យ៉ាងតិចមានរថយន្តនគរបាលចំនួន ២ បានមកដល់។
- នៅម៉ោង ៥កន្លះល្ងាច នគរបាលបានចាប់ខ្លួនលោក សុខ ឈុនអឿន អ្នកដែលឈរនៅក្រោយការតវ៉ានេះ។ លោក ត្រូវបាននាំខ្លួនទៅកាន់ស្នងការនគរបាលរាជធានីភ្នំពេញ។

[២៨] សេចក្តីថ្លែងការណ៍អង្គការ លីកាដូ, "កម្ពុជា៖ ការរំខាន ការឃាត់ខ្លួន និងការឃុំខ្លួនអ្នកការពារសិទ្ធិមនុស្សនៅតែបន្តកើតមានឡើង" ចេញផ្សាយថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤, http://www.licadho-cambodia.org/pressrelease.php?perm=339។ សូមមើលផងដែរនូវសេចក្តីប្រកាសព័ត៌មានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, "ការចាប់ខ្លួនសកម្មជនដីធ្លី និងហាមឃាត់បាតុកម្មបណ្តោះអាសន្ន" ថ្ងៃទី៦ ខែមករា ឆ្នាំ២០១៤, http://www.cchrcambodia.org/index_old.php?url=media/media.php&p=alert_detail.php&alid=47&id=5

[២៩] Simon Henderson, "ក្រុមសង្គមស៊ីវិលថ្កោលទោសការគម្រាមកំហែងទៅលើអ្នកដឹកនាំអង្គការមិនមែនរដ្ឋាភិបាល", The Cambodia Daily, ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤, https://www.cambodiadaily.com/archives/group-condemns-threats-against-leader-of-ngo-50405/

ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤
ករណីទី៣៣

### មនុស្សចំនួន ១១នាក់ ត្រូវបានឃាត់ខ្លួនអំឡុងពេលតវ៉ាទាមទារដោះលែងអ្នកទាំង២៣នាក់[៣៣]
### សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ការបំពានលើសេរីភាពក្នុងការជួបជុំ/ អំពើហិង្សា និងការចាប់ខ្លួន

- សកម្មជនសិទ្ធិមនុស្សចំនួន ១១នាក់ ត្រូវបានចាប់ខ្លួន និងឃាត់ខ្លួនដោយកងសន្តិសុខខណ្ឌដូនពេញប្រមាណ ៤០នាក់ នៅពេលដែលអ្នកទាំងនោះបានដឹកនាំការដើរក្បួនទៅកាន់ស្ថានទូតសហរដ្ឋអាមេរិក ដើម្បីអំពាវនាវឲ្យមានការដោះលែងកម្មករ និងសកម្មជនទាំង ២៣នាក់ ដែលបានជាប់ឃុំអំឡុងពេលតវ៉ារបស់កម្មកររោងចក្រ។
- ក្នុងចំណោមអ្នកទាំង ១១នាក់ ដែលត្រូវបានចាប់ខ្លួន គឺមានលោក រ៉ុង ឈុន ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ(CITA) អ្នកស្រី ទេព វន្នី និងអ្នកស្រី យ៉ោម បុប្ផា ជាមួយនឹងសកម្មជនដីធ្លីតំបន់បឹងកក់ ៧នាក់ផ្សេងទៀត បុគ្គលិកអង្គការក្រុមការងារពិសេសសិទ្ធិលំនៅឋាន (HRTF) និងសកម្មជនមកពីសម្ព័ន្ធសហជីពកម្ពុជា (CATU)។
- អ្នកទាំង ១១នាក់ ត្រូវបានដោះលែងវិញនៅពេលរសៀល បន្ទាប់ពីអ្នកទាំងនោះយល់ព្រមចុះហត្ថលេខាលើលិខិតដោយសន្យាថាអ្នកទាំងនោះនឹងមិនញុះញង់ ឬចូលរួមនៅក្នុងសកម្មភាពខុសច្បាប់បន្តទៀត ឬការតវ៉ាទៀតនោះទេ។

ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៤
ករណីទី៣៤

### អ្នករៀបចំការបញ្ចាំងខ្សែវីដេអូ ត្រូវបានគម្រាមកំហែងចាប់ដាក់ពន្ធនាគារ និងនិរទេសខ្លួន[៣៤]
### រាជធានីភ្នំពេញ

ការគម្រាមកំហែង/ច្បាប់

- បន្ទាប់ពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា គ្រោងនឹងចាក់បញ្ចាំងខ្សែវីដេអូដែលមានចំណងជើងថា៖ "អ្នកណាសម្លាប់ជាវិជ្ជា?" ដែលជាវីដេអូឯកសារឆ្នាំ២០០៧ ពាក់ព័ន្ធនឹងការធ្វើឃាតសកម្មជនសហជីពលោក ជា វិជ្ជា អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រី បានគម្រាមកំហែងថានរណាដែលចូលរួមនៅក្នុងការមើលខ្សែវីដេអូនេះ អាចនឹងប្រឈមមុខនឹងការជាប់ពន្ធនាគារ ឬនិរទេសខ្លួន។ក្រោយមកការចាក់បញ្ចាំងនេះ ត្រូវបានលុបចោល។

ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៤
ករណីទី៣៥

### អ្នកតំណាងសហជីព ត្រូវបានឃាត់ខ្លួននៅពេលចែកខិតប័ណ្ណ[៣៥]
### សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ការរំលោភបំពានដោយប្រើអំណាច/ ការឃាត់ខ្លួន និងចាប់ខ្លួន

- អ្នកតំណាងសហជីពពីរនាក់ ត្រូវបានឃាត់ខ្លួនដោយនគរបាលនៅពេលចែកខិតប័ណ្ណពីការធ្វើបាតុកម្ម នៅខាងក្រៅរោងចក្រអេវើហ្គ្រីន។ អ្នកទាំងនោះ ត្រូវបានឃាត់ខ្លួនអស់ពីរម៉ោង និងត្រូវបាននគរបាលគម្រាមរឹបអូសទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់អ្នកទាំងនោះ ប្រសិនបើអ្នកទាំងនោះមិនអនុវត្តតាមនគរបាលទាំងនោះ។
- អ្នកទាំងពីរ ត្រូវបានដោះលែងវិញ បន្ទាប់ពីអ្នកទាំងនោះផ្តិតមេដៃអះអាងថាអ្នកទាំងនោះនឹងមិនចែកខិតប័ណ្ណតទៀតនោះទេ។

ថ្ងៃទី២ ខែមករា ឆ្នាំ២០១៤
ករណីទី៣៦

### សមាជិកសហជីព ត្រូវបានឃាត់ខ្លួនដោយខុសច្បាប់នៅពេលចែកខិតប័ណ្ណ[៣៦]
### សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ការរំលោភបំពានដោយប្រើអំណាច/ ការឃាត់ខ្លួន និងចាប់ខ្លួន

- សមាជិកសហជីពពីរនាក់ លោក យិន សារឿន និងជួប និត ត្រូវបានឃាត់ខ្លួនដោយខុសច្បាប់ដោយមេនគរបាលសង្កាត់ឫស្សីកែវ លោក ឃ្លាំង ហួត បន្ទាប់ពីអ្នកទាំងនោះបានចែកចាយខិតប័ណ្ណអំពាវនាវដល់កម្មករធ្វើបាតុកម្ម។

[៣០] អេង ម៉េងឡេង, "បុគ្គលិកអាដហុកនិយាយថាអ្នកទាំងនោះត្រូវបានគេដាក់គោលដៅដោយអ្នកបើកបរ", The Cambodia Daily, ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤, https://www.cambodiadaily.com/archives/adhoc-workers-say-they-were-targeted-by-driver-50407/

[៣១] របាយការណ៍ស៊ើបអង្កេតរបស់អង្គការលីកាដូ ដែលមិនត្រូវបានចេញផ្សាយ៖ KN004THI14។

[៣២] អត្ថបទខ្លីអង្គការ លីកាដូ៖ មេដឹកនាំសមាគមម្នាក់ទៀត ត្រូវបានចាប់ខ្លួនអំឡុងពេលនៃការជួបជុំគ្នាដើម្បីអំពាវនាវឲ្យមានការដោះលែងមេដឹកនាំសមាគម និងកម្មកររោងចក្រទាំង ២៣ នាក់" ចេញផ្សាយថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៤ http://www.licadho-cambodia.org/flashnews.php?perm=26

- អ្នកទាំងពីរ ត្រូវបានឃាត់ខ្លួនអស់មួយម៉ោង មុនពេលត្រូវបានដោះលែង។ នៅពេលដែលអ្នកទាំងពីរព្យាយាមចែកខិតប័ណ្ណ អ្នកទាំងនោះត្រូវបានឃ្លាំមើលដោយមន្ត្រីនគរបាលស្លៀកពាក់ស៊ីវិល។

ថ្ងៃទី៣ ខែមិនា ឆ្នាំ២០១៤
ករណីទី៣៧

"អ្នកតវ៉ាឲ្យ "ដោះលែងអ្នកទាំង ២៣" ត្រូវបានគេរំលោភបំពាន[៣៧]
សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ការបំពានលើសេរីភាពក្នុងការជួបជុំ/ អំពើហិង្សា និងការចាប់ខ្លួន

- សកម្មជនប្រមាណ ១០០នាក់ មកពីសហគមន៍បឹងកក់ បុរីកីឡា និងថ្មគោល ត្រូវបានរំលោភបំពានដោយកងសន្តិសុខខណ្ឌដូនពេញ នៅពេលដែលអ្នកទាំងនោះតវ៉ាសុំឲ្យមានការដោះលែងអ្នកទាំង ២១ ដែលជាប់ពន្ធនាគារអំឡុងពេលកូដកម្មកម្មកររោងចក្រកាលពីខែមករា។
- អំពើហិង្សា បានកើតឡើងនៅពេលដែលអ្នកតវ៉ាជាច្រើន ព្យាយាមយកស្គរដែលកងសន្តិសុខរឹបអូសពីពេលមុនត្រឡប់មកវិញ។
- សកម្មជនពីរនាក់ ត្រូវបានគេរាយការណ៍ថាបានរងរបួស មាន៖ អ្នកស្រី ភួង សុភាព អាយុ៤០ឆ្នាំ ជាសកម្មជនសិទ្ធិលំនៅឋាន ត្រូវបានគេវាយចំច្រមុះដោយប្រើវិទ្យុទាក់ទង និងអ្នកស្រី ឃ្លាំង យ៉ាន អាយុ៥០ឆ្នាំ ត្រូវគេទាត់ចំភ្លៅ។

ថ្ងៃទី៣ ខែមិនា ឆ្នាំ២០១៤
ករណីទី៣៨

កម្មកររោងចក្រនៅភ្នំពេញ ត្រូវបានឃុំនៅក្នុងរោងចក្រ[៣៨]
ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ការរំលោភបំពានដោយប្រើអំណាច/ ការឃាត់ខ្លួន និងចាប់ខ្លួន

- កម្មកររោងចក្រ និងអ្នកតំណាងសហជីពនៅរោងចក្រ ដាយ យី ត្រូវបានគេឃុំខ្លួនដោយខុសច្បាប់នៅក្នុងរោងចក្ររបស់អ្នកទាំងនោះ និងត្រូវបានគេគម្រាមកំហែង ថានឹងចាប់ខ្លួនដោយនគរបាលក្នុងតំបន់ នៅពេលអ្នកទាំងនោះព្យាយាមបដិសេធធ្វើការថែមម៉ោង។

ថ្ងៃទី៣ ខែមិនា ឆ្នាំ២០១៤
ករណីទី៣៩

កម្មកររោងចក្រនៅកំពង់ស្ពឺ ត្រូវបានឃុំខ្លួនក្នុងរោងចក្រ[៣៩]
ខេត្តកំពង់ស្ពឺ

ការរំលោភបំពានដោយប្រើអំណាច/ ការឃាត់ខ្លួន និងចាប់ខ្លួន

- កម្មកររោងចក្រ និងអ្នកតំណាងសហជីពនៅរោងចក្រស្បែកជើង Complete Honour ត្រូវបានឃុំខ្លួនដោយខុសច្បាប់នៅក្នុងរោងចក្ររបស់អ្នកទាំងនោះ និងត្រូវបានគម្រាមកំហែងថានឹងចាប់ខ្លួនដោយនគរបាលក្នុងតំបន់ ប្រសិនបើអ្នកទាំងនោះបដិសេធធ្វើការថែមម៉ោង។

ថ្ងៃទី៥ ខែមិនា ឆ្នាំ២០១៤
ករណីទី៤០

សកម្មជនបឹងកក់ ត្រូវបានឃាត់ខ្លួនដោយខុសច្បាប់[៤០]
រាជធានីភ្នំពេញ

ការរំលោភបំពានដោយប្រើអំណាច/ ការឃាត់ខ្លួន និងចាប់ខ្លួន

- អ្នកតវ៉ាមកពីតំបន់បឹងកក់បីនាក់មាន អ្នកស្រី អ៊ឹម ស្រីទូច សៀ ណារិទ្ធិ និងសាត់ ផាស ត្រូវបានឃាត់ខ្លួនដោយកងសន្តិសុខខណ្ឌដូនពេញ នៅពេលដែលអ្នកទាំងនោះកំពុងប្រមូលផ្តុំគ្នាជាមួយអ្នកភូមិបឹងកក់ ១០នាក់ទៀត ដើម្បីទាមទារសំណងបន្ថែមពីការបណ្តេញអ្នកទាំងនោះចេញពីលំនៅឋាន។ អ្នកស្រី ស្រីទូច ត្រូវបានចាប់ខ្លួន នៅពេលអ្នកស្រីកំពុងចុះពីលើរ៉ឺម៉កកង់បី។
- អ្នកទាំងបី ត្រូវបានឃាត់ខ្លួនដោយមិនមានការចោទប្រកាន់ រហូតដល់អ្នកទាំងនោះយល់ព្រមផ្តិតមេដៃលើឯកសារដែលមានព័ត៌មានលំអិតនៃការសាកសួរចម្លើយអ្នកទាំងនោះ។

[៣៣] សេចក្តីថ្លែងការណ៍អង្គការ លីកាដូ "កម្ពុជា៖ ការរំខាន ការឃាត់ខ្លួន និងការឃុំខ្លួនអ្នកការពារសិទ្ធិមនុស្សនៅតែបន្តកើតមានឡើង" ចេញផ្សាយថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤, http://www.licadho-cambodia.org/pressrelease.php?perm=339

[៣៤] Denise Hruby, "Deportation, Jail Threatened if Film Screened" The Cambodia Daily, 24 January 2014; Denise Hruby, "Film Screening Canceled After Government Threatens Jail" The Cambodia Daily, 25-26 January 2014.

**ថ្ងៃទី៦ ខែមិនា ឆ្នាំ២០១៤**
**ករណីទី៤១**

### អ្នកកាសែត ត្រូវបានគេគម្រាមកំហែងនៅពេលធ្វើការស៊ើបអង្កេតលើករណីរំលោភដីធ្លី[៤១]
### សង្កាត់ប៉ោយប៉ែត ខណ្ឌប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

ការគម្រាមកំហែង/ ច្បាប់

- អ្នកកាសែតពីរនាក់មកពីសារព័ត៌មានពីរខុសគ្នា លោកភូ ប៊ុនធឿន និងលោក ពេជ្រ សុវណ្ណារ៉ា ត្រូវបានចោទប្រកាន់ពីបទបរិហាកេរ្តិ៍ដោយលោក ហួង ម៉ៅ ទាហានម្នាក់នៅក្នុងកងពលលេខ ៧០ បន្ទាប់ពីអ្នកទាំងនោះបានរាយការណ៍ពីការពាក់ព័ន្ធរបស់ទាហាននោះនៅក្នុងការរំលោភដីធ្លី។
- អ្នកទាំងពីរ ត្រូវបានកោះហៅសាកសួរនៅមុខចៅក្រមស៊ើបសួរនៅក្នុងសាលាដំបូងខេត្តបន្ទាយមានជ័យកាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤។

**ថ្ងៃទី១០ ខែមិនា ឆ្នាំ២០១៤**
**ករណីទី៤២**

### អ្នកកាសែតដែលស៊ើបអង្កេតករណីកាប់ឈើខុសច្បាប់ ត្រូវបានគេបាញ់[៤២]
### ឃុំពីរធ្នូ ស្រុកស្នួល ខេត្តក្រចេះ

អំពើហិង្សា/ការរំលោភបំពាន

- អ្នកកាសែតបីនាក់នៅខេត្តក្រចេះ លោក សិទ្ធិ រស្មី លី ចំរើន និងគង់ ដុង ត្រូវបានគេរាយការណ៍ថាត្រូវបានកងរាជអាវុធហត្ថបាញ់គម្រាម បន្ទាប់ពីអ្នកទាំងនោះបានថតរូបអាជ្ញាធរនោះកំពុងដឹកឈើប្រណិត។
- អ្នកទាំងនោះអះអាងថាត្រឹមតែប្រាំនាទីបន្ទាប់ពីថតរូបរួច បុរសម្នាក់ប្រដាប់ដោយអាវុធខ្លី និង AK-47 មួយដើម មកដល់ ហើយចាប់ផ្ដើមបាញ់ទៅអ្នកទាំងនោះ។
- នគរបាល បានបញ្ជាក់ពីសំបកគ្រាប់នៅទីតាំងនោះ និងនិយាយថានគរបាលនឹងធ្វើការស៊ើបអង្កេត។

**ថ្ងៃទី១២ ខែមិនា ឆ្នាំ២០១៤**
**ករណីទី៤៣**

### សកម្មជនដីធ្លី ត្រូវបានគេគម្រាមនឹងសម្លាប់[៤៣]
### ឃុំត្រពាំងព្រីង ស្រុកតំបែរ ខេត្តកំពង់ចាម

ការគម្រាមកំហែង/ ការគម្រាមកំហែងនឹងត្រូវគេសម្លាប់

- មេភូមិចំបក់ លោក ហាក់ សឿង បានទទួលរងការគម្រាមសម្លាប់ពីមនុស្សមិនស្គាល់អត្តសញ្ញាណម្នាក់ ក្នុងគោលបំណងបំភិតបំភ័យលោកឲ្យឈប់ជួយអ្នកភូមិដាក់ញត្តិពាក់ព័ន្ធនឹងជម្លោះដីធ្លី។

**ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៤**
**ករណីទី៤៤**

### អ្នកកាប់ឈើខុសច្បាប់ និងអាជ្ញាធរ គម្រាមកំហែងសកម្មជនព្រៃឈើ[៤៤]
### ខេត្តក្រចេះ

ការគម្រាមកំហែង/ ការគម្រាមកំហែងនឹងត្រូវគេសម្លាប់

- លោក ស៊ន ស៊ីយាន និងអ្នកស្រី មុំ សាគីន សកម្មជនសហគមន៍ បានទទួលរងការគម្រាមសម្លាប់ពីអ្នកកាប់ឈើខុសច្បាប់ និងមន្ត្រី បន្ទាប់ពីអ្នកទាំងនោះដឹកនាំការល្បាតព្រៃរបស់សហគមន៍ក្នុងការរឹបអូសម៉ាស៊ីនកាប់ឈើដែលត្រូវបានប្រើប្រាស់ក្នុងការកាប់ឈើខុសច្បាប់នៅក្នុងព្រៃការពារ។
- ការគម្រាមកំហែង កាន់តែកើតមានច្រើនឡើងនៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៣ នៅពេលលោក ស៊ន ស៊ីយា អតីតមន្ត្រីជាន់ខ្ពស់មកពីស្រុកស្នួល និងបច្ចុប្បន្នប្រធាននគរបាលនៅក្នុងស្រុកចិត្របុរី បានព្រមានថាទ្រព្យដែលរឹបអូសបានអាចជំនួសបាន ប៉ុន្តែជីវិតសកម្មជនមិនអាចជំនួសបានទេ។
- បន្ទាប់មកអ្នកទាំងពីរទាំងអ្នកស្រី មុំ សាគីន និងលោក ស៊ន ស៊ីយាន ទទួលរងការគម្រាមសម្លាប់ពីអ្នកកាប់ឈើខុសច្បាប់។

---

៣៥ Meach Dara, "Union Reps Detained for Distributing Strike Leaflets", The Cambodia Daily, 28 February 2014.

៣៦ របាយការណ៍ស៊ើបអង្កេតរបស់អង្គការលីកាដូ ដែលមិនត្រូវបានចេញផ្សាយ៖ PP035IAD14។

៣៧ Khoun Narim, "Daun Penh Guards Seize Protest Drum, Scuffle with Activists" The Cambodia Daily,4 March 2014;

៣៨ Mom Kunthear & Sean Teehan, "Workers 'locked inside' during overtime strike", Phnom Penh Post, 4 March 2014.

៣៩ Mom Kunthear & Sean Teehan, "Workers 'locked inside' during overtime strike", Phnom Penh Post, 4 March 2014.

៤០ Khouth Sophak Chakrya, "B Kak protestor trio detained, realeased", Phnom Penh Post, 6 March 2014.

ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៤
ករណីទី៤៥

អង្គការមិនមែនរដ្ឋាភិបាលខេត្តព្រះវិហាររងការគម្រាមកំហែងឲ្យបិទ[៤៥]
ឃុំប្រមេ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ

ការរំលោភបំពានដោយប្រើអំណាច/ ផ្សេងៗ

- ពន្លកខ្មែរ ជាអង្គការមិនមែនរដ្ឋាភិបាលតូចមួយធ្វើការរឿងសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច ត្រូវបានគេគម្រាមកំហែងឲ្យបិទ នៅពេលដែលអភិបាលខេត្តព្រះវិហារ បានសរសេរលិខិតមួយទៅកាន់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអះអាង ពីគោលបំណងរបស់លោកអភិបាលក្នុងការបិទអង្គការនេះ។ លោកអភិបាលខេត្ត បានប្រកាសថាការបិទត្រូវបានអនុវត្តតាមដីកា ព្រោះដំណាំស្វាយអំពៅត្រូវបានគេដក បំផ្លាញអំឡុងពេលមានការតវ៉ាមួយជំទាស់នឹងក្រុមហ៊ុនស្ករសចិនមួយ ដែលអង្គការពន្លកខ្មែរបានឃ្លាំមើល។
- ក្រោយមកលោកលុតសាងបុគ្គលិកម្នាក់នៃអង្គការពន្លកខ្មែរនិងអ្នកដឹកនាំសហគមន៍ពីរនាក់ទៀត អ្នកស្រី នួន មន និងអ្នកស្រី រឿង ខាន់ ត្រូវបាននគរបាលកោះហៅសាកសួរនៅស្នងការនគរបាលខេត្ត។ កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ អ្នកទាំងនោះត្រូវបានសាលាដំបូងខេត្តព្រះវិហារកោះហៅចូលសាកសួរ។

ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៤
ករណីទី៤៦

អាជ្ញាធរបានបិទផ្លូវអ្នកកាសែត និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល[៤៦]
ឃុំស្រែព្រះ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី

ការរំលោភបំពានដោយប្រើអំណាច/ ផ្សេងៗ

- បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងអ្នកកាសែតមួយក្រុមមានសមាជិក ១៦នាក់ ត្រូវបានមេឃុំក្នុងតំបន់ដែលអមដំណើរដោយមន្ត្រីនគរបាលប្រដាប់អាវុធ៦នាក់រារាំងដោយមិនឲ្យធ្វើដំណើរទៅកាន់ដីដែលមានជម្លោះនៅខេត្តមណ្ឌលគិរី។ អ្នកកាសែត និងបុគ្គលិកអង្គការទាំងនោះ គ្រោងចុះទៅយកព័ត៌មានពីការកាប់ឈើខុសច្បាប់នៅក្នុងព្រៃលើដីសម្បទានសេដ្ឋកិច្ចដែលមានជម្លោះ។

ថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៤
ករណីទី៤៧

អ្នកតវ៉ាអហិង្សាលើសិទ្ធិការងារ ត្រូវបានគេវាយដំ[៤៧]
រាជធានីភ្នំពេញ

ការបំពានលើសេរីភាពក្នុងការជួបជុំ/ អំពើហិង្សា និងការចាប់ខ្លួន

- កងសន្តិសុខខណ្ឌដូនពេញ បានវាយដំទៅលើអ្នកតវ៉ាអហិង្សា អ្នកកាសែត និងអ្នកឈរមើល នៅពេលសន្តិសុខទាំងនោះបំបែកដោយហិង្សាទៅលើការប្រមូលផ្តុំគ្នានៅថ្ងៃទិវាពលកម្មអន្តរជាតិ។ កងសន្តិសុខ បានដេញវាយ និងវាយពលរដ្ឋដោយដំបងមិនរើសមុខ នៅក្នុងបរិវេណកន្លែងតវ៉ា។
- មនុស្សប្រាំនាក់ បានរងរបួសយ៉ាងធ្ងន់ធ្ងរ ហើយមនុស្សជាច្រើនទៀតរួមទាំងអ្នកកាសែតបានរងរបួសស្រាល។ មេសន្តិសុខខណ្ឌដូនពេញ បានហៅការវាយដំនេះជា "រឿងតូចតាច"។

ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៤
ករណីទី៤៨

សកម្មជនសហជីពរថយន្តក្រុង ត្រូវបានគេប្តឹង[៤៨]
រាជធានីភ្នំពេញ

ការបំភិតបំភ័យ/ ច្បាប់

- ក្រុមហ៊ុនរថយន្តក្រុងភ្នំពេញសូរិយា បានប្តឹងអតីតបុគ្គលិកចំនួន ២០នាក់ ដែលត្រូវបានបញ្ឈប់ពីការងារ ទាក់ទងនឹងការធ្វើបាតុកម្ម។ ការប្តឹងនោះ ត្រូវបានធ្វើឡើងពីបទញុះញង់ គម្រាមកំហែង និង ប្រើប្រាស់ដោយមិនមានការអនុញ្ញាតនូវឯកសណ្ឋានរបស់អ្នកទាំងនោះ ប៉ុន្តែមានតែអនុប្រធាន សហជីពរថយន្តក្រុង និងជាសកម្មជនសិទ្ធិកម្មករលោក ធន់ វិសាលប៉ុណ្ណោះ ដែលត្រូវបានកោះហៅឲ្យចូលខ្លួនក្នុងតុលាការ។

[៤១] Kuch Naren, "Journalists Questioned Over Soldier's Complaint", The Cambodia Daily, February 18, 2014.

[៤២] Vong Sokheng, "Police 'fired on reporters'", Phnom Penh Post, 10 March 2014.

[៤៣] របាយការណ៍ស៊ើបអង្កេតរបស់អង្គការលីកាដូ ដែលមិនត្រូវបានចេញផ្សាយ៖ KC012THI14។

[៤៤] សេចក្តីប្រកាសព័ត៌មានរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, "សកម្មជនព្រៃឈើពីរនាក់មកពីខេត្តក្រចេះ ទទួលរងការគម្រាមសម្លាប់ពីអាជ្ញាធរ", ចេញផ្សាយថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៤, http://www.cchrcambodia.org/index_old.php?url=media/media.php&p=alert_detail.php&alid=37&id=5

ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៤
ករណីទី៤៩

បុគ្គលិកមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា រងការគម្រាមកំហែងនៅពេលស៊ើបអង្កេតជម្លោះដីធ្លី[៤៩]
សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

អំពើហិង្សា/ ការរំលោភបំពាន

- លោក វណ្ណ សុផាត អ្នកសម្របសម្រួលគម្រោងកំណែទម្រង់ដីធ្លីនៅមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ត្រូវបានរុញច្រាន និងគម្រាមដោយផ្ទាល់មាត់ដោយមនុស្សស្លៀកពាក់ស៊ីវិល ដែលត្រូវបានដឹងថាជាកងសន្តិសុខ នៅពេលលោកចុះទៅទីតាំងដែលជាដីមានជម្លោះរវាងពលរដ្ឋ ៣គ្រួសារ និងក្រុមហ៊ុន យុន សៀ។
- នៅពេលព្យាយាមត្រឡប់ទៅតំបន់នោះម្តងទៀត លោកបានប្រឈមមុខនឹងកងសន្តិសុខក្រុមហ៊ុន យុន សៀ ដែលប្រដាប់ដោយកាំបិត ពូថៅ និងញញួរ ជាអ្នកគម្រាមកាប់រូបលោក និងជេរប្រមាថលើលោក។

ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៤
ករណីទី៥០

អ្នកតំណាងសហជីព ៣នាក់ ត្រូវបានចាប់ខ្លួនពីបទញុះញង់[៥០]
ខេត្តកណ្តាល

ការរំលោភបំពានរបស់អាជ្ញាធរ/ ការឃាត់ខ្លួន និងចាប់ខ្លួន

- អ្នកតំណាងសហជីព ៣នាក់ នៃសហព័ន្ធសហជីពសេរីកម្មករខ្មែរ លោក មុខ មាញ់ បៀវ ម៉ានណារិន និងសុខ វិជ្ជារ៉ា ត្រូវបានក្រសួងមហាផ្ទៃកោះហៅ និងចាប់ខ្លួនពីបទញុះញង់កម្មករឲ្យធ្វើកូដកម្ម។
- ការចាប់ខ្លួន ត្រូវបានធ្វើឡើងតាមបណ្តឹងរបស់រោងចក្រ Quint Major Industrial ជាកន្លែងដែលកម្មករបានធ្វើការតវ៉ាឲ្យមានការទទួលកម្មករដែលបានបញ្ឈប់ថ្មីៗចំនួន ២៥នាក់ ឲ្យចូលធ្វើការវិញ។

ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៤
ករណីទី៥១

សកម្មជនសហជីព ៨នាក់ ត្រូវបានចាប់ខ្លួន និងចោទប្រកាន់[៥១]
ស្រុកបាទី ខេត្តតាកែវ

ការរំលោភបំពានរបស់អាជ្ញាធរ/ ការឃាត់ខ្លួន និងចាប់ខ្លួន

- សកម្មជនសហជីពចំនួន ៨នាក់ ដែលជាបុគ្គលិកសហជីព និងសមាជិកសហជីព CCAWDU ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ អំឡុងពេលមានការតវ៉ានៅរោងចក្រ JSD Textile Co Ltd ដោយកម្មករទាមទារឲ្យមានលក្ខខណ្ឌការងារល្អប្រសើរឡើង។
- បន្ទាប់ពីត្រូវបានឃាត់ខ្លួនអស់ ៤៨ ម៉ោង អ្នកទាំងនោះត្រូវបានចោទប្រកាន់ពីបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ (មាត្រា ២៨នៃក្រមព្រហ្មទណ្ឌ) ញុះញង់ (មាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ) គម្រាមកំហែងនឹងបំផ្លិចបំផ្លាញ (មាត្រា ៤២៣ នៃក្រមព្រហ្មទណ្ឌ) និងបង្ខូចសេចក្តីសម្រេចរបស់តុលាការ (មាត្រា ៥២៣ នៃក្រមព្រហ្មទណ្ឌ)។
- អ្នកទាំងប្រាំបី ដែលត្រូវបានចោទប្រកាន់មាន លោក សៀង យុទ្ធ លោក សុត សៀម លោក ភិន សុត លោក កែវ បឿន លោក នូ ស័ក្ក លោក អ៊ុល សំអឿន អ្នកស្រី ជឿម ស្រីពៅ និងលោក សេង សឿន។

ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៤
ករណីទី៥២

សកម្មជនបរិស្ថាន រងការវាយដំ[៥២]
ឃុំមានរិទ្ធិ ស្រុកសណ្តាន់ ខេត្តកំពង់ធំ

អំពើហិង្សា/ ការរំលោភបំពាន

- លោក ឈាង វុទ្ធី សកម្មជនម្នាក់នៅក្នុងបណ្តាញសហគមន៍ព្រៃឡង់ ត្រូវបានវាយដំដោយទាហានម្នាក់នៅក្នុងអង្គភាពស្រាវជ្រាវខេត្តកំពង់ធំ លោក ប៉ែន ប៊ុនគា។

---

[៤៥] សេចក្តីប្រកាសព័ត៌មានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, "អង្គការពន្លកខ្មែរ រងការគម្រាមកំហែងបិទទ្វារនៅខេត្តព្រះវិហារ", ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៤, http://www.cchrcambodia.org/index_old.php?url=media/media.php&p=alert_detail.php&alid=50&id=5

[៤៦] Ben Sokhean, "Authorities Block Journalists From Site of Logging", The Cambodia Daily, 28 April 2014.

- ទាហាននោះ បានជួបលោក ឈាង វុទ្ធី នៅក្នុងភោជនីយដ្ឋានមួយ ហើយព្យាយាមចាក់លោក ១៣ដង មុនពេលត្រូវបានបញ្ឈប់ដោយអ្នកនៅក្បែរនោះ។ មួយឆ្នាំមុន លោក វុទ្ធី បានដាក់ឈ្មោះទាហាននោះនៅក្នុងពាក្យបណ្ដឹងទៅកាន់ក្រសួងមហាផ្ទៃថាមានមន្ត្រីទាហានជាប់ពាក់ព័ន្ធនឹងការកាប់ឈើខុសច្បាប់។

ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៤
ករណីទី៥៣

អ្នកតំណាងជនរងគ្រោះការរំលោភដីធ្លី ត្រូវបានចាប់ខ្លួន[៥៣]
ឃុំស្ទឹងត្រង់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន

ការរំលោភបំពានដោយប្រើអំណាច/ ការឃាត់ខ្លួន និងចាប់ខ្លួន

- អ្នកតំណាងជនរងគ្រោះការរំលោភដីធ្លី ៤នាក់ លោក អោម សុមាត់ លោក អោម សំអុល លោក ពេជ្រ សុធា និងលោក ទូន មាក់ ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទរំលោភដោយខុសច្បាប់លើដីរដ្ឋ និងត្រូវបានឃុំខ្លួននៅពន្ធនាគារខេត្តប៉ៃលិន។
- ការចាប់ខ្លួន ត្រូវបានធ្វើឡើងក្រោយពេលអ្នកតំណាងទាំងបួន ដឹកនាំភូមិចំនួនបួនខុសគ្នាគឺ ភូមិទំនប់ អូរ កាធាងវា អន្លង់រក្សា និងភ្នំ ក្រញូងផាស់ផល ដើម្បីសរសេរលិខិតទៅនាយករដ្ឋមន្ត្រី ប្ដឹងអំពីការបំផ្លិចបំផ្លាញផ្ទះរបស់អ្នកទាំងនោះ ដើម្បីរំលោភយកដីធ្លី។ ទោះបីជាសម្ដេចនាយករដ្ឋមន្ត្រីកំពុងពិនិត្យមើលស្ថានភាពក៏ដោយ ក៏មិនទាន់មានដំណោះស្រាយនៅឡើយ ហើយភ្លាមៗបន្ទាប់ពីនោះ លោកអភិបាលស្រុកបានបន្តការចោទប្រកាន់លើអ្នកទាំងបួន។

ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៤
ករណីទី៥៤

អ្នកតំណាងសហគមន៍ ត្រូវបានគេបំភិតបំភ័យ[៥៤]
ឃុំក្រាំងស្គៀ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង

ការបំភិតបំភ័យ/ ច្បាប់

- លោក ស៊ុំ ខន អ្នកតំណាងសហគមន៍ម្នាក់នៅឃុំក្រាំងស្គៀ បានទទួលរងការគម្រាមកំហែងតាមរយៈទូរស័ព្ទពីមេបញ្ជាការកងទ័ពម្នាក់ បន្ទាប់ពីលោកបានរៀបចំញត្តិស្នើឲ្យមានអន្តរាគមន៍ពីអភិបាលស្រុកនៅក្នុងជម្លោះដីធ្លីរវាងអ្នកភូមិ និងទាហាន ដែលទទួលបានដីពីព្រះរាជក្រឹត្យ។

ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៤
ករណីទី៥៥

ទូរស័ព្ទរបស់ព្រះតេជគុណ លួន សូវ៉ាត ត្រូវបានរឹបអូស[៥៥]
សង្កាត់ប៉ោយប៉ែត ខណ្ឌប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

ការរំលោភបំពានដោយប្រើអំណាច/ ផ្សេងៗ

- ទូរស័ព្ទរបស់ព្រះតេជគុណ លួន សូវ៉ាត ជាសកម្មជនមួយអង្គដែលត្រូវបានស្គាល់ថាជា "ព្រះសង្ឃពហុបច្ចេកវិទ្យា" ត្រូវបានបុគ្គលមិនស្គាល់អត្តសញ្ញាណរឹបអូសតាមបញ្ជារបស់អភិបាលខណ្ឌប៉ោយប៉ែត លោក ញូរ ម៉េងឆរ និងមេនគរបាលខណ្ឌ អ៊ុំ សុផល ដែលអមដំណើរដោយមន្ត្រីនគរបាលខណ្ឌប៉ោយប៉ែត ៣០នាក់។ ទូរស័ព្ទរបស់ព្រះអង្គ ត្រូវបានរឹបអូស បន្ទាប់ពីព្រះអង្គបានថតកម្មករខ្មែរត្រឡប់មកពីប្រទេសថៃ។

[៥៧] Mech Dara, "May 1 Rallies Marred by Police Violence", The Cambodia Daily, 2 May 2014.

[៥៨] Mom Kunthear, "Bus Company Sues Strikers", Phnom Penh Post, 7 May 2014.

[៥៩] សេចក្ដីប្រកាសព័ត៌មានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, "ការគម្រាមកំហែងលើអ្នកសម្របសម្រួលគម្រោងកំណែទម្រង់ដីធ្លីនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា" ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៤,http://www.cchrcambodia.org/index_old.php?url=media/media.php&p=alert_detail.php&alid=52&id=5

ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤
**ករណីទី៥៦**

**អ្នកតំណាងត្រូវបានចោទប្រកាន់ ដោយសារបានរារាំងការឈូសឆាយដីដោយខុសច្បាប់[៥៦]**
**ឃុំកក់ ស្រុកបរកែវ ខេត្តរតនគិរី**

ការរំលោភបំពានដោយប្រើអំណាច/ ការឃាត់ខ្លួន និងចាប់ខ្លួន

- លោក ញឹម សុខ អ្នកតំណាងភូមិ ត្រូវបានចាប់ខ្លួនបន្ទាប់ពីលោក និងអ្នកភូមិ ២០នាក់ទៀត ប្រឈមមុខនឹងគ្រឿងចក្រឈូសឆាយដីរបស់ក្រុមហ៊ុន Swift Rubber ដែលរៀបនឹងឈូសឆាយដីមានជម្លោះ។ អ្នកភូមិ បានប្ដឹងក្រុមហ៊ុននេះ និងបានជូនដំណឹងដល់មន្ត្រីថាមានគ្រឿងចក្រឈូសឆាយបានឈូសឆាយដីរបស់អ្នកទាំងនោះដោយខុសច្បាប់។ លោក ញឹម សុខ ត្រូវបានចោទប្រកាន់ពីបទ "ជ្រៀតជ្រែកដោយខុសច្បាប់ទៅក្នុងការបំពេញមុខងារសាធារណៈ" (មាត្រា ៦០៩ នៃក្រមព្រហ្មទណ្ឌ)។

ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៤
**ករណីទី៥៧**

**អ្នកកាសែត ត្រូវបានគេវាយដំយ៉ាងធ្ងន់ធ្ងរនៅក្នុងការតវ៉ារបស់គណបក្សសង្គ្រោះជាតិ[៥៧]**
**សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ**

អំពើហិង្សា/ ការរំលោភបំពាន

- អ្នកកាសែតវិទ្យុសម្លេងប្រជាធិបតេយ្យ លោក ឡាយ សាម៉ាន ត្រូវបានកងសន្តិសុខ ១០នាក់ទាត់ និងវាយដំដោយដំបង បណ្ដាលឲ្យរងរបួសយ៉ាងធ្ងន់ធ្ងរ និងបាក់ឆ្អឹង បន្ទាប់ពីលោកបានថតរូបជាច្រើននៃការបំបែកការតវ៉ារបស់គណបក្សសង្គ្រោះជាតិ។

ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៤
**ករណីទី៥៨**

**សកម្មជនដីធ្លី ត្រូវបានកោះហៅសាកសួរ[៥៨]**
**ខេត្តកណ្ដាល**

ការបំភិតបំភ័យ/ ច្បាប់

- អ្នកភូមិ ១២នាក់ ត្រូវបានសាលាដំបូងខេត្តកណ្ដាលកោះហៅសាកសួរ ទាក់ទងនឹងការពាក់ព័ន្ធរបស់អ្នកទាំងនោះនៅក្នុងការតវ៉ាប្រឆាំងនឹងក្រុមហ៊ុន ផានអ៊ីមិច ដោយអំពាវនាវដល់អាជ្ញាធរឲ្យជួយអន្តរាគមន៍នៅក្នុងការរំលោភដីធ្លីរបស់ក្រុមហ៊ុនលើដីទំហំ ៦៣ ហិកតា របស់មនុស្សចំនួន ១៨០គ្រួសារ។

ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៤
**ករណីទី៥៩**

**កងសន្តិសុខវាយដំសកម្មជនឲ្យសន្លប់[៥៩]**
**រាជធានីភ្នំពេញ**

ការបំពានលើសេរីភាពក្នុងការជួបជុំ/ អំពើហិង្សា និងការចាប់ខ្លួន

- កងសន្តិសុខខណ្ឌដូនពេញប្រដាប់ដោយជំពាម និងដំបង បានវាយដំទៅលើសកម្មជនបឹងកក់ និងបុរីកីឡាដែលបានធ្វើការតវ៉ាដោយអហិង្សា។
- អ្នកតវ៉ា បានទៅមុខសាលារាជធានី ដើម្បីទាមទារឲ្យគោរពពាក្យសន្យារបស់ខ្លួនក្នុងការដោះស្រាយជម្លោះដីធ្លីរបស់សហគមន៍ទាំងពីរ។
- អំពើហិង្សា បានកើតឡើងនៅពេលដែលកងសន្តិសុខព្យាយាមឃាត់ខ្លួនលោក ច័ន្ទ ពុទ្ធិស័ក ជាមនុស្សម្នាក់ក្នុងចំណោមមនុស្សទាំង២៣នាក់ដែលត្រូវបានចាប់ខ្លួន នឹងជំនុំជម្រះកាលពីខែមករា ឆ្នាំ២០១៤។ ស្ត្រីពីរនាក់ អ្នកស្រី ប្រាក់ ស៊ីផា និងអ្នកស្រី ខឹម ស្រី ត្រូវបានគេវាយឲ្យសន្លប់អំឡុងពេលមានការវាយដំ។

[៥០] Mech Dara, "Another Three Textile Union Reps Arrested", The Cambodia Daily, 12 May 2014.

[៥១] សេចក្ដីប្រកាសព័ត៌មានអ្នកការពារសិទ្ធិមនុស្សរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "ការគម្រាមកំហែងលើអ្នកសម្របសម្រួលគម្រោងកំណែទម្រង់ដីធ្លីនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា", ថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៤, <http://www.cchrcambodia.org/index_old.php?url=media/media.php&p=alert_detail.php&alid=52&id=5>

[៥២] May Titthara, "Activist 'threatened with Knife'", Phnom Penh Post, 26 May 2014.

[៥៣] របាយការណ៍ស៊ើបអង្កេតរបស់អង្គការលីកាដូ ដែលមិនត្រូវបានចេញផ្សាយ៖ BB038LG14។

ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៤
ករណីទី៦០

មនុស្សជំទង់ម្នាក់ ត្រូវបានសម្លាប់ នៅពេលការពារដីអ្នកជិតខាង[60]
ស្រុកគូលេន ខេត្តព្រះវិហារ

អំពើហិង្សា/ ការសម្លាប់

- លោកទ្រី ចំរើន ជាកសិករអាយុ ១៩ឆ្នាំម្នាក់ ត្រូវបានបាញ់សម្លាប់ដោយទាហានម្នាក់ នៅពេលលោកព្យាយាមជួយអ្នកជិតខាងបញ្ឈប់ទាហានពីការកាប់ឈើនៅលើដីរបស់អ្នកទាំងនោះ។
- មុនពេលមានការបាញ់ ទាហានបានប្រកាសថាអ្នកភូមិមិនត្រូវបានអនុញ្ញាតឲ្យធ្វើស្រែចំការលើតំបន់នោះទេ ព្រោះវាជាកម្មសិទ្ធិមន្ត្រីជាន់ខ្ពស់របស់ទាហានទាំងនោះ គឺលោក ស៊ុន ហម។
- នាយទាហាន លោក គឿន ដាស ត្រូវបានចោទប្រកាន់ពីបទមនុស្សឃាត និងប្រើប្រាស់អាវុធដោយគ្មានការអនុញ្ញាត។

ថ្ងៃទី៣ ខែសីហា ឆ្នាំ២០១៤
ករណីទី៦១

ប្រធានសង្ឃត្រូវបានទម្លាក់តំណែង នៅពេលជួយអ្នកភូមិ[61]
ខេត្តស្វាយរៀង

បាត់បង់ការចិញ្ចឹមជីវិត/ ការទម្លាក់តំណែង

- ព្រះតេជគុណ អេង ពុទ្ធី ប្រធានសង្ឃវត្តនៅខេត្តស្វាយរៀង ត្រូវបានគេរាយការណ៍ថាត្រូវបានគេទម្លាក់តំណែង នៅពេលដែលព្រះអង្គជួយអ្នកភូមិដែលបានតវ៉ាជំទាស់នឹងការសាងសង់ព្រែកកាត់តាមដីរបស់អ្នកទាំងនោះ។ ប្រធានការិយាល័យសាសនាស្រុករំដួល លោក តឹក សាន បាននិយាយថាការដកតំណែងនេះ ដោយសារតែព្រះអង្គចំណាយពេលច្រើនពេកនៅក្រៅបរិវេណវត្ត។

ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៤
ករណីទី៦២
(សូមមើលករណីទី ៦៤)

មេដឹកនាំសហគមន៍ឡពាង ត្រូវបានចាប់ខ្លួនអំឡុងពេលដើរក្បួន[62]
ឃុំតាជេស ស្រុកត្រឡាច ខេត្តកំពង់ឆ្នាំង

ការបំពានលើសេរីភាពក្នុងការជួបជុំ/ អំពើហិង្សា និងការចាប់ខ្លួន

- អ្នកភូមិ ៥០នាក់ មកពីសហគមន៍ឡពាង បានចាប់ផ្តើមដើរក្បួនចំងាយ ៦០គ.ម ទៅកាន់រាជធានីភ្នំពេញ ដើម្បីអំពាវនាវឲ្យមានដំណោះស្រាយលើជម្លោះដីធ្លីដ៏រ៉ាំរ៉ៃរបស់អ្នកទាំងនោះជាមួយក្រុមហ៊ុន KDC។ នៅពេលទៅដល់ទីរួមស្រុកកំពង់ត្រឡាច នគរបាល និងកងរាជអាវុធហត្ថប្រមាណ ១០០នាក់ បានបំបែកអ្នកទាំងនោះដោយហិង្សា ដែលបណ្តាលឲ្យអ្នកភូមិ ៨នាក់រងរបួស។
- អ្នកដើរក្បួន ៣នាក់ ក៏ត្រូវបានចាប់ខ្លួនដូចជាលោក សួន ញឿន (ស្វាមីរបស់អ្នកដឹកនាំសហគមន៍ឡពាងដែលលេចធ្លោ អ្នកស្រី អ៊ុំ សុភី) លោក ស្រ៊ុន ថា និងលោកគួច ហុក (អ្នកភូមិដែលមានអាយុ ៦៧ឆ្នាំម្នាក់)។ នៅថ្ងៃទី២៩ ខែសីហា អ្នកទាំងនោះ ត្រូវបានដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ន។

---

[60] របាយការណ៍ស៊ើបអង្កេតរបស់អង្គការលីកាដូ ដែលមិនត្រូវបានចេញផ្សាយ៖ KN023LG14។

[61] របាយការណ៍ស៊ើបអង្កេតរបស់អង្គការលីកាដូ ដែលមិនត្រូវបានចេញផ្សាយ៖ BM037DAP14។

[62] Ben Sokhean, "Villager Charged After Blocking Land Clearance in Ratanakkiri" The Cambodia Daily, 20 June 2014.

[63] របាយការណ៍ស៊ើបអង្កេតរបស់អង្គការលីកាដូ ដែលមិនត្រូវបានចេញផ្សាយ៖ PP062PA14។

| ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៤<br>ករណីទី៦៣ | សកម្មជនដីធ្លី ត្រូវបានតុលាការព្យួរទោស និងពិន័យជាប្រាក់[៦៣]<br>ខេត្តកំពង់ធំ<br>ការរំលោភបំពានដោយប្រើអំណាច/ ការផ្តន្ទាទោសព្រហ្មទណ្ឌ<br>• សកម្មជនប្រាំបួននាក់បានទទួលនូវការព្យួរទោសពន្ធនាគារចំនួន១ឆ្នាំនិងសម្រេចឲ្យសងជាប្រាក់ ១.២៥០ ដុល្លារ ទៅលោក អ៊ុល រដ្ឋា ដែលជាអ្នករកស៊ី ចំពោះដើមជ័ទ្បងមីដែលត្រូវបានគេចោទប្រកាន់ថាត្រូវបានកាប់បំផ្លាញដោយអ្នកទាំងនោះ។ សកម្មជនទាំងនោះ ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពាក់ព័ន្ធនឹងការឃ្លាំមើលការកាប់ឈើខុសច្បាប់នៅក្នុងព្រៃឡង់។ សកម្មជនទាំងនោះរួមមាន លោក ម៉ៅ ធា លោក មាស គៀង លោក មាស វ៉ាន់ លោក ព្រំ ស៊ុយ លោក ហែម ហាយ លោក នួន គីន លោក ដួង ឆាយ លោក សៅ ខន និងលោក ឈាង វុទ្ធី។ |
| ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤<br>ករណីទី៦៤<br>(សូមមើលករណីទី៦២) | នគរបាលបានវាយដំលើសកម្មជនដីធ្លីដែលបានដើរហែក្បួនដោយអហិង្សា[៦៤]<br>ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង<br>ការបំពានលើសេរីភាពក្នុងការជួបជុំ/ អំពើហិង្សា និងការចាប់ខ្លួន<br>• នគរបាល និងកងរាជអាវុធហត្ថ បានវាយដំលើអ្នកដើរក្បួនអហិង្សា ដែលមកពីសហគមន៍ឡពាង ដោយបានដើរក្នុងចំងាយ ៦០ គ.ម ទៅកាន់រាជធានីភ្នំពេញ ដើម្បីស្វែងរកអន្តរាគមន៍ពីសម្តេចនាយករដ្ឋមន្ត្រី នៅក្នុងជម្លោះដីធ្លីដ៏រ៉ាំរ៉ៃរបស់អ្នកទាំងនោះជាមួយនឹងក្រុមហ៊ុន KDC។<br>• នៅពេលអ្នកទាំងនោះដើរបានចំងាយ ៥គ.ម នគរបាល និងកងរាជអាវុធហត្ថ ១០០នាក់ បានបិទផ្លូវ និងវាយដំទៅលើអ្នកដើរក្បួន ទោះបីនៅក្នុងក្បួនមានកូនក្មេង និងមនុស្សចាស់ជាច្រើនក៏ដោយ។ នគរបាល បានបំផ្លាញរទេះដាក់អង្ករ និងឆ្នាំងចានដែលអ្នកដើរក្បួនយកតាមមក។<br>• ស្រ្តីចំនួន ៣នាក់ បានសន្លប់ បន្ទាប់ពីដៃរបស់អ្នកទាំងនោះត្រូវបានចងទៅក្រោយខ្នង ហើយបុរសម្នាក់ទទួលរងរបួសដៃឆ្វេងយ៉ាងធ្ងន់ធ្ងរ។ អ្នកដើរក្បួន ៣នាក់ ត្រូវបានចាប់ខ្លួន រួមមានអ្នកស្រី ស្រ៊ុន ថា គួច ហុក និងលោក សួន ញឿន។<br>• លោក ហ៊ុល វាសនា មេនគរបាលស្រុកកំពង់ត្រឡាច បានបដិសេធថាមិនមានអំពើហិង្សាណាមួយនោះទេ ទោះបីជាមានអ្នករាយការណ៍បានថតបាននូវការវាយដំ និងមានឈាមនៅលើដីក៏ដោយ។<br>• ថ្ងៃបន្ទាប់ ក្បួនបានបន្តដំណើរទៅកាន់រាជធានីភ្នំពេញ ទោះជាត្រូវបានរារាំងជាបណ្តោះអាសន្នឆ្លងកាត់ខណ្ឌឫស្សីកែវក៏ដោយ។ |
| ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៤<br>ករណីទី៦៥ | ការតវ៉ាអហិង្សា ត្រូវបានបំបែកដោយហិង្សា[៦៥]<br>សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ការបំពានលើសេរីភាពក្នុងការជួបជុំ/ អំពើហិង្សា និងការចាប់ខ្លួន<br>• កងកម្លាំងចម្រុះ បានបំបែកយ៉ាងហិង្សាលើអ្នកភូមិខេត្តក្រចេះ ដែលបានដើរក្បួនមកកាន់គេហដ្ឋានសម្តេចនាយករដ្ឋមន្ត្រី ដើម្បីដាក់ញត្តិស្វែងរកការអន្តរាគមន៍លើបញ្ហាជម្លោះដីធ្លីដែលកំពុងកើតមានឡើង។<br>• ទោះបីជាមានការតវ៉ាអហិង្សាក៏ដោយ ក៏កម្លាំងចម្រុះបានវាយដំទៅលើក្រុមមនុស្សដោយប្រើដំបង ខែល និងដំបងឆក់។ អ្នកភូមិ ១២នាក់ បានរងរបួសរួមទាំងកុមារម្នាក់អាយុ ៤ឆ្នាំ និងទារកម្នាក់អាយុ ៦ខែផងដែរ។ |

[៥៨] Ben Sokhean, "Protest Outside Kandal Court as Questioning Starts in Land Case", The Cambodia Daily, 22 July 2014.

[៥៩] Khouth Sophak Chakrya, "District guards back on beat", Phnom Penh Post, 29 July 2014.

[៦០] Phak Seangly, "Land fight leads to death" Phnom Penh Post, 29 July 2014.

[៦១] Meach Dara, "Monk Claims Demotion Over Support for Land Protest" The Cambodia Daily, 4 August 2014.

ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៤
**ករណីទី៦៦**

### មេដឹកនាំសហជីព ត្រូវបានឃាត់ខ្លួន[៦៦]
### ឃុំជ្រក់ម្ទេស ស្រុកបាវិត ខេត្តស្វាយរៀង

ការរំលោភបំពានដោយប្រើអំណាច/ ការឃាត់ខ្លួន និងចាប់ខ្លួន

- លោក ទូន សារ៉ែន ជាអ្នកតំណាងសម្ព័ន្ធសហជីពចលនាកម្មករនៅក្នុងរោងចក្រ You Li ត្រូវបានចាប់ខ្លួនពីបទញុះញង់កម្មករឲ្យបិទផ្លូវជាតិលេខ ១។
- លោក ទូន សារ៉ែន បានដឹកនាំកម្មករ ៨០០នាក់ នៅក្នុងវិស័យឧស្សាហកម្ម អំពាវនាវឲ្យមានការបន្ថែមបន្ទប់ពេទ្យ កង្ហារឲ្យបានគ្រប់គ្រាន់ក្នុងបន្ទប់ធ្វើការងារ និងកែលំអបន្ទប់ទឹក និងប្រាក់ឧបត្ថម្ភ ១០ដុល្លារ ដល់ស្ត្រីដែលបានសម្រាលកូន។ បន្ទាប់ពីត្រូវបានយកទៅ "អប់រំ" ដោយនគរបាល និង សន្យាថាលោកនឹងបញ្ឈប់ការតវ៉ាផ្សេងៗទៀតនាពេលខាងមុខ លោកត្រូវបានដោះលែងដោយមិនមានការចោទប្រកាន់។

ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤
**ករណីទី៦៧**

### អ្នកតំណាងសហគមន៍ ត្រូវបានផ្តន្ទាទោសពន្ធនាគារ ៣ឆ្នាំ[៦៧]
### ឃុំកំពង់ក្រសាំង ស្រុកបូរី ខេត្តតាកែវ

ការរំលោភបំពានដោយប្រើអំណាច/ ការផ្តន្ទាទោសព្រហ្មទណ្ឌ

- អ្នកតំណាងសហគមន៍ ៣នាក់ លោក វី ច័ន្ទ លោក វី មាឃ និងលោក សុន រុំ ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទឈូសឆាយដីព្រៃខុសច្បាប់។ អ្នកទាំងបីមានជាប់ពាក់ព័ន្ធនឹងជម្លោះដីធ្លីសហគមន៍ របស់អ្នកទាំងនោះជាមួយនឹងប្រធានការិយាល័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអ្នកបានរំលោភដី ២០០ ហិកតារបស់ពលរដ្ឋ ៧២ គ្រួសារ។ អ្នកទាំងបី ត្រូវបានផ្តន្ទាទោស ប៉ុន្តែព្យួរទោសចំនួន ៣ឆ្នាំ និងពិន័យជាប្រាក់ ៣លានរៀល (៧៥០ដុល្លារ)។

ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤
**ករណីទី៦៨**

### សកម្មជនបឹងកក់ ៤នាក់ ត្រូវបានចាប់ខ្លួន[៦៨]
### ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

ការរំលោភបំពានដោយប្រើអំណាច/ ការឃាត់ខ្លួន និងចាប់ខ្លួន

- សកម្មជនសហគមន៍មកពីតំបន់បឹងកក់ ៤នាក់ ត្រូវបានចាប់ខ្លួននៅវត្តចាស់ក្នុងខណ្ឌជ្រោយចង្វារ។ សកម្មជនទាំងនោះ បានមកដល់ទីនោះដើម្បីគាំទ្រសហគមន៍ដីធ្លីមកពីខេត្តប៉ៃលិន បន្ទាយមានជ័យ បាត់ដំបង និងស្វាយរៀង ដែលបានរៀបចំដើរក្បួនដាក់ញត្តិទៅកាន់រដ្ឋសភា និងសម្តេចនាយករដ្ឋមន្ត្រីនៅពេលព្រឹក។
- សកម្មជនចំនួន ៤នាក់ ដែលត្រូវបានចាប់ខ្លួនរួមមាន កញ្ញា សុង ស្រីលាភ ទេព វន្នី ខែក ច័ន្ទរស្មី និងគង់ ចន្ថា។ អ្នកទាំងនោះ ត្រូវបានឃាត់ខ្លួននៅប៉ុស្តិ៍នគរបាលខណ្ឌជ្រោយចង្វារ និងដោះលែងនៅមុនពេលថ្ងៃត្រង់ ដោយមនុស្សម្នាក់ក្នុងចំណោមអ្នកទាំងនោះ ត្រូវបញ្ជូនទៅកាន់មន្ទីរពេទ្យកាល់ម៉ែត។ បន្ទាប់ពីចាប់ខ្លួនសកម្មជនទាំងបួននាក់ អាជ្ញាធរបានរារាំងសមាជិកសហគមន៍នៅក្នុងវត្តចាស់ដោយមិនឲ្យចេញទៅក្រៅ។

---

[៦២] សេចក្តីថ្លែងការណ៍អង្គការ លីកាដូ, "អង្គការ លីកាដូ ថ្កោលទោសចំពោះការបង្ក្រាបដោយហិង្សាលើការដើរ ហែក្បួនអហិង្សារបស់អ្នកភូមិ ឡ ពាង" ចេញផ្សាយថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤, http://www.licadho-cambodia.org/pressrelease.php?perm=352

[៦៣] Chhay Channyda, "Activists Sentenced", Phnom Penh Post, 6 August 2014.

ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៤
ករណីទី៦៩

### ការអនុវត្តនីតិវិធីព្រហ្មទណ្ឌដោយមិនត្រឹមត្រូវមកលើព្រះតេជគុណ លួន សុវាត[៦៩]
រាជធានីភ្នំពេញ

ការបំភិតបំភ័យ/ ច្បាប់

- នីតិវិធីជំនុំជម្រះរឿងព្រហ្មទណ្ឌ របស់អ្នកការពារសិទ្ធិមនុស្សល្បីឈ្មោះ ព្រះតេជគុណលួន សុវ៉ាត ត្រូវបានបន្ត បន្ទាប់ពីត្រូវបានពន្យារពេលរយៈពេល ២ឆ្នាំ។ ការចោទប្រកាន់ពីបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ (មាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ) ដែលផ្តើមពីការធ្វើបាតុកម្ម ដោយជនរងគ្រោះពីជម្លោះដីធ្លី ក្នុងឆ្នាំ ២០១២ ប្រជំទាស់នឹងអាជ្ញាធររដ្ឋ។ ប្រសិនបើតុលាការធ្វើការផ្តន្ទាទោសនោះព្រះតេជគុណសុវ៉ាត អាចប្រឈមនឹងការជាប់ពន្ធនាគាររយៈពេល ២ឆ្នាំ និងពិន័យ ជាប្រាក់ចំនួន ១000ដុល្លារអាមេរិក ដែលស្មើនឹងជាង ៤.000.000រៀល។
- ការចោទប្រកាន់ទៅលើព្រះអង្គ ត្រូវបានគេរួមបញ្ចូលជាមួយនឹងសំណុំរឿងពីរផ្សេងទៀតនៅក្នុងឆ្នាំ ២០១៣ ដែលពុំមានការពាក់ព័ន្ធនឹងព្រះអង្គទាល់តែសោះ។ សំណុំរឿងនោះ ក៏ធ្វើការចោទប្រកាន់ទៅលើលោក សួន សេរីរដ្ឋា ដែលជាអ្នកនយោបាយដ៏ចម្រូងចម្រាស ដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិក។ ដីកាកោះហៅដំបូងរបស់តុលាការទៅលើ ព្រះតេជគុណសុវ៉ាត ក៏បានចោទប្រកាន់ពីបទរួមគំនិតក្បត់ផងដែរ។ តែទោះជាយ៉ាងណាក៏ដោយ ដីកាកោះហៅជាបន្តបន្ទាប់ បានធ្វើការចោទប្រកាន់ព្រះអង្គតែពីបទញុះញង់ប៉ុណ្ណោះ។
- បន្ទាប់ពីបានបង្ហាញខ្លួននៅសវនាការ ជាមួយនឹងសហជនជាប់ចោទរបស់ព្រះអង្គ។ ប្រធាននៃក្រុមប្រឹក្សាជំនុំជម្រះ បានប្រកាសថាសំណុំរឿងដែលមានដាច់ដោយឡែកមួយរបស់ព្រះតេជគុណសុវ៉ាត ដែលមិនត្រូវបានដឹងទៅដល់ភាគីទាំងអស់ដែលពាក់ព័ន្ធ ការពិតវាត្រូវបានចេញជាងពីរឆ្នាំកន្លងមកហើយ កាលពីថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១២។ ស្ថានភាពនៃសំណុំរឿង និងលក្ខណៈនៃការចោទប្រកាន់មកលើព្រះតេជគុណសុវ៉ាត នៅតែមានភាពមិនច្បាស់លាស់ ដូចជា មេធាវីការពារក្តីមិនទាន់ត្រូវបានអនុញ្ញាតឲ្យពិនិត្យទៅលើសំណុំរឿងថ្មីដែលបានផ្តល់ឱ្យ។

ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៤
ករណីទី៧០

### អ្នកស្រាវជ្រាវពីការរំលោភដីធ្លី ត្រូវបានឃាត់ខ្លួនអស់មួយយប់[៧០]
ក្រុងសំរោង ស្រុកសំរោង ខេត្តឧត្តរមានជ័យ

ការរំលោភបំពានដោយប្រើអំណាច/ ការឃាត់ខ្លួន និងចាប់ខ្លួន

- អ្នកស្រាវជ្រាវពីរនាក់ របស់អង្គការសមធម៌កម្ពុជា លោក សុខ លីដា និង ម៉េត ហ្វូគូសាវ៉ា បានត្រូវបាននគរបាលអន្តោប្រវេសន៍ឃុំខ្លួនពេញមួយយប់ នៅក្នុងខេត្តឧត្តរមានជ័យ បន្ទាប់ពីអ្នកទាំងពីរបានទៅសួរសុខទុក្ខក្រុមគ្រួសារដែលបានបណ្តេញចេញ ដោយក្រុមហ៊ុនស្ករសថៃ MitrPhol ដែលជាក្រុមហ៊ុនផ្គត់ផ្គង់ស្ករសចម្បងរបស់កូកាកូឡា។ នៅក្នុងឆ្នាំ ២00៨ វាលស្រែដែលជាកម្មសិទ្ធិរបស់ពលរដ្ឋប្រមាណ ១00 គ្រួសារ នៅក្នុងភូមិបុស្ស ត្រូវបានរឹបអូសយក ដើម្បីដាំដំណាំអំពៅ។
- ខណៈពេលដែល អ្នកទាំងពីរ កំពុងធ្វើដំណើរ រថយន្តនគរបាលចំនួន៤ បានចូលទៅកៀក ហើយបានសុំឱ្យអ្នកទាំងពីរ ឲ្យធ្វើដំណើរជាមួយនគរបាលទាំងនោះទៅកាន់ស្នងការនគរបាលខេត្តឧត្តរមានជ័យ។ ពួកគាត់បានបដិសេធ ដោយសារការព្រួយបារម្ភអំពីសុវត្ថិភាព ដោយធ្វើដំណើរដោ យម៉ូតូនៅពេលយប់។ មួយរំពេចក្រោយមក ស្នងការរង បានមកដល់ ហើយស្នើឲ្យហ្វូគូសាវ៉ា ប ង្ហាញនូវលិខិតឆ្លងដែនរបស់នាង ដែលនៅពេលនោះ នាងមិនបានយកមកជា ប់ខ្លួននោះទេ។

[៦៨] សេចក្តីថ្លែងការណ៍អង្គការ លីកាដូ, "អង្គការ លីកាដូ ថ្កោលទោសចំពោះការបង្ក្រាបដោយហិង្សាលើការដើរ ហែក្បួនអហិង្សារបស់អ្នកភូមិ ឡ ពាង" ចេញផ្សាយថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤, http://www.licadho-cambodia.org/pressrelease.php?perm=352; May Titthara, "Peaceful marchers beaten", Phnom Penh Post, 13 August 2014, http://www.phnompenhpost.com/national/peaceful-marchers-beaten

[៦៩] Pech Sotheary, "Capital clash sees 10 injured", Phnom Penh Post, 19 August 2014.

[៧០] Sek Odom, "Union Official Arrested for 'Inciting' Striking Workers", The Cambodia Daily, 19 August 2014.

- នៅម៉ោង ៨៖៣០ល្ងាច អ្នកទាំងពីរបានត្រូវចាប់ខ្លួន ដោយមិនមានដីកា និងមិនបានផ្តល់មូលហេតុសមរម្យសម្រាប់ការឃុំខ្លួន។ បន្ទាប់មក ពួកគាត់ត្រូវបានសាកសួរជាង ៣ម៉ោង អំពីសកម្មភាពស្រាវជ្រាវរបស់អ្នកទាំងពីរ។ នៅពេលនោះដែរ លោក សុខ លីដា បានត្រូវដោះលែង ក៏ប៉ុន្តែលោកបានជ្រើសរើសនៅទីនោះជាមួយហ្វូគូសាវ៉ា។ ហ្វូគូសាវ៉ា បានបង្ហាញនូវលិខិតឆ្លងដែនរបស់នាងដែលបានស្កេន ប៉ុន្តែភ្លាមៗនោះ នាងត្រូវបានប្រាប់ថា វាមិនចាំបាច់ទេ ក្នុងការបង្ហាញនូវឯកសា រទាំងនេះទៅពួកគេ។ នៅព្រឹកថ្ងៃបន្ទាប់ ពួកគាត់ទាំងពីរនាក់ ត្រូវបានបញ្ជូនទៅកាន់នាយកដ្ឋានអន្តោប្រវេសន៍ នៅឯរាជធានីភ្នំពេញ និងត្រូវបានដោះលែងនៅពេលរសៀល បន្ទាប់ពីហ្វូគូសាវ៉ា បានចុះហត្ថលេខាលើឯកសារមួយ ដោយយល់ព្រមមិនដាក់ពាក្យបណ្តឹងទៅលើការឃុំខ្លួនរបស់នាង។
- អង្គការសមធម៌កម្ពុជា បានជួយក្រុមគ្រួសារជនរងគ្រោះនៅខេត្តឧត្តរមានជ័យ ដាក់ពាក្យបណ្តឹងទៅគណៈកម្មាធិការសិទ្ធិមនុស្សនៃប្រទេសថៃនៅក្នុងឆ្នាំ២០១៣ ដែលមុនមួយខែនៃការប្រកាសថា ក្រុមហ៊ុន MitrPhol បានយកដីប្រជាពលរដ្ឋដោយខុសច្បាប់។

ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៤
**ករណីទី៧១**

### សកម្មជនសហជីព ត្រូវបានចាប់ខ្លួន និងឃាត់ខ្លួនដោយមិនមានដីកា[៧១]
### ស្រុកកំចាយមា ខេត្តព្រៃវែង

ការរំលោភបំពានដោយប្រើអំណាច/ ការឃាត់ខ្លួន និងចាប់ខ្លួន

- អ្នកតំណាងពីររូបរបស់ CCAWDU លោក សុខ សៀម និង ឃុន សុខុម បានត្រូវចាប់ខ្លួន និងឃុំខ្លួន ខណៈពេលដែលពួកគេបានដឹកនាំការតវ៉ានៅទល់មុខរោងចក្រកំចាយមា។ ការតវ៉ានេះជាផ្នែកមួយនៃការធ្វើបាតុកម្មរយៈពេលមួយសប្តាហ៍ ដែលទាមទារលក្ខខណ្ឌការងារ និងប្រាក់បន្ថែមលើកទឹកចិត្តប្រសើរជាងមុន។ ពួកគេត្រូវបានចាប់ខ្លួន ដោយគ្មានដីកា និងបានបញ្ជូនទៅការិយាល័យស្រុកកំចាយមា ដើម្បីសួរចម្លើយដោយអាជ្ញាធរ។ ពួកគេត្រូវបានដោះលែងវិញនៅពេលរសៀល បន្ទាប់ពីមនុស្សរាប់ពាន់នាក់បានធ្វើបាតុកម្មនៅមុខការិយាល័យស្រុកនោះ។

ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៤
**ករណីទី៧២**

### បុគ្គលិកអង្គការ សមធម៌កម្ពុជា ២នាក់ ត្រូវបានឃាត់ខ្លួន[៧២]
### ឃុំសំរោង ស្រុកសំរោង ខេត្តឧត្តរមានជ័យ

ការរំលោភបំពានដោយប្រើអំណាច/ ការឃាត់ខ្លួន និងឃុំខ្លួន

- នគរបាលបានបំបែកនូវការប្រជុំមួយនៅឯផ្ទះឯកជនរវាងបុគ្គលិក ៤នាក់នៃអង្គការសមធម៌កម្ពុជា និង ២០គ្រួសារ ដែលត្រូវបានបណ្តេញចេញដោយដីសម្បទានសេដ្ឋកិច្ចចំការអំពៅមួយ។
- បុគ្គលិកអង្គការសមធម៌កំពុងធ្វើការសម្ភាសន៍បានពាក់កណ្តាល ទៅលើពលរដ្ឋ ២០គ្រួសារ នៅពេលដែលនគរបាលមូលដ្ឋាន និងកងរាជអាវុធហត្ថបានមកដល់ និងបានបង្ខំឲ្យបុគ្គលិកអង្គការសមធម៌ចាកចេញ។ នៅពេលនោះដែរ នគរបាល បាននិយាយថា អង្គការសមធម៌ត្រូវមានការអនុញ្ញាតពីអាជ្ញាធរខេត្ត ដើម្បីធ្វើការសម្ភាសន៍នៅក្នុងតំបន់នេះ។ ទោះជាយ៉ាងណា ស្នងការនគរបាលខេត្ត លោក ម៉េន ម៉ាលី បានទទួលស្គាល់ជាបន្តបន្ទាប់ថា គ្មានច្បាប់ណាដែលតម្រូវឲ្យសុំការអនុញ្ញាតក៏ដោយ ប៉ុន្តែលោកនៅតែអះអាងថា ការសុំអនុញ្ញាតនៅតែត្រូវការជាចាំបាច់ ដោយសារ "តំបន់នេះគឺស្ថិតនៅក្រោមការគ្រប់គ្រងនៃអាជ្ញាធរមូលដ្ឋាន (លោក)"។

---

[៦៧] របាយការណ៍ស៊ើបអង្កេតរបស់អង្គការលីកាដូ ដែលមិនត្រូវបានចេញផ្សាយ៖ PP115LG14.

[៦៨] អត្ថបទខ្លីអង្គការ លីកាដូ, "សកម្មជនសហគមន៍បឹងកក់ចំនួនបួននាក់ ត្រូវបានចាប់ខ្លួន" ចេញផ្សាយថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤, http://www.licadho-cambodia.org/flashnews.php?perm=78

ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៤
**ករណីទី៧៣**

### នគរបាល វាយដំលើបុគ្គលិកអង្គការ សមធម៌កម្ពុជា[៧៣]
### ឃុំសំរោង ស្រុកសំរោង ខេត្តឧត្តរមានជ័យ

អំពើហិង្សា/ ការរំលោភបំពាន

- នគរបាលនៅខេត្តឧត្តរមានជ័យ បានប្រើហិង្សាលើបុគ្គលិកអង្គការសមធម៌ ដោយបានដាល់បុគ្គលិកទាំងនោះចំពោះ បន្ទាប់ពីអ្នកទាំងនោះបានបដិសេធមិនអនុញ្ញាតឲ្យមន្ត្រីឆែកឆេរឡានរបស់អ្នកទាំងនោះដោយគ្មានដីកា និងដោយគ្មានការថត។
- នគរបាលបានបញ្ឈប់ឡាន នៅពេលដែលពួកគាត់កំពុងដឹកជញ្ជូនអ្នកភូមិត្រលប់ទៅកាន់សហគមន៍របស់ពួកគេវិញ បន្ទាប់ពីមានការសម្ភាសន៍ជាមួយនឹងបុគ្គលិកអង្គការសមធម៌ នៅឯការិយាល័យរបស់អង្គការអាដហុក។ បន្ទាប់ពីការឆែកឆេរដោយខុសច្បាប់ និងការវាយដំ នគរបាលបានរឹបអូសយកឡាន និងបានលុបរូបភាពពីម៉ាស៊ីនថត។

ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៤
**ករណីទី៧៤**

### អ្នកតវ៉ាដីធ្លី ត្រូវបានបំបែកដោយហិង្សា[៧៤]
### សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ការបំពានលើសេរីភាពក្នុងការជួបជុំ/ អំពើហិង្សា និងការចាប់ខ្លួន

- កងសន្តិសុខក្នុងរាជធានីភ្នំពេញបានបំបែកដោយហិង្សាទៅលើអ្នកភូមិចំនួន ៨០ នាក់ មកពីខេត្តព្រះវិហារ ដែលបានមកដល់រាជធានីភ្នំពេញ ដើម្បីស្នើសុំជំនួយពីរដ្ឋាភិបាល ក្នុងការដោះស្រាយជម្លោះដីធ្លីរបស់ពួកគេ ខណៈពេលដែលនគរបាល និងមន្ត្រីនគរបាលបានឈរហាមអ្នកទាំងនោះមិនឲ្យទៅជិតគេហដ្ឋានឯកជនរបស់សម្តេចនាយករដ្ឋមន្ត្រី។
- អំពើហិង្សានេះ បានបង្កឲ្យមានមនុស្ស ១៨នាក់រងរបួស ដែលក្នុងចំណោមនោះ មានមនុស្សជាច្រើនបានរងរបួសក្បាល។ នៅក្នុងចំណោមអ្នករងរបួសទាំងនេះ ក៏មាន លោក អ៊ុក ពេជ្រសំណាង ដែលត្រូវបានគេចាប់ខ្លួន និងចោទប្រកាន់អំពីការជាប់ពាក់ព័ន្ធនឹងការតវ៉ានេះផងដែរ។

ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤
**ករណីទី៧៥**

### សកម្មជនជាព្រះសង្ឃ ត្រូវបានគេដកតំណែងជាព្រះចៅអធិការវត្ត[៧៥]
### ស្រុកបាណន់ ខេត្តបាត់ដំបង

ការបាត់បង់ការចិញ្ចឹមជីវិត/ ការដកតំណែង

- ប្រធានសង្ឃនៃវត្តភ្នំក្បស ព្រះតេជគុណ គឹម សំអឿន ត្រូវបានដកចេញពីតំណែងរបស់ព្រះអង្គ បន្ទាប់ពីព្រះអង្គមានការពាក់ព័ន្ធនៅក្នុងការតវ៉ាសិទ្ធិដីធ្លីមួយ។ ជាពិសេសនោះ ព្រះអង្គបានអនុញ្ញាតឲ្យសមាជិកនៃបណ្តាញព្រះសង្ឃឯករាជ្យ ដើម្បីយុត្តិធម៌សង្គម ចំនួន ១១នាក់ ស្នាក់នៅក្នុងវត្ត។

ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៤
**ករណីទី៧៦**
(សូមមើលករណីទី៧៧)

### សកម្មជនបឹងកក់ ១០នាក់ ត្រូវបានចាប់ដាក់ក្នុងពន្ធនាគារ[៧៦]
### សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ការរំលោភបំពានដោយប្រើអំណាច/ ការឃាត់ខ្លួន និងចាប់ខ្លួន

- អ្នកការពារសិទ្ធិមនុស្សចំនួន ១០នាក់ មកពីសហគមន៍បឹងកក់ រួមជាមួយនឹងព្រះសង្ឃចំនួន ១អង្គ ត្រូវបានចាប់ខ្លួន និងផ្តន្ទាទោសដាក់ពន្ធនាគារ ចំនួន ១ឆ្នាំ នៅក្នុងនីតិវិធីតុលាការដែលមានលក្ខណៈមិនយុត្តិធម៌ បន្ទាប់ពីមានការពាក់ព័ន្ធនឹងការតវ៉ាពីរ។

---

[៦៩] ការផ្សាយព័ត៌មានផ្ទាល់របស់អង្គការ លីកាដូ, "សវនាការលើសំណុំរឿងរបស់ព្រះអង្គ លួន សុវាត ឬ "ព្រះសង្ឃពហុប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មាន"", ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៤, http://stream.licadho-cambodia.org/monk_venerable_sovath_trial/; LICADHO Statement, សេចក្តីថ្លែងការណ៍អង្គការ លីកាដូ, "ការចោទប្រកាន់មិនត្រឹមត្រូវមកលើព្រះតេជគុណ លួន សុវ៉ាត ត្រូវតែលុបចោល", ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៤, http://www.licadho-cambodia.org/pressrelease.php?perm=362

[៧០] សេចក្តីថ្លែងការណ៍ អង្គការ លីកាដូ, "ការឃុំខ្លួនបុគ្គលិករបស់អង្គការ សមធមិកម្ពុជាដោយខុសច្បាប់" ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤, http://www.licadho-cambodia.org/pressrelease.php?perm=358 ; Zsombor Peter & Mech Dara, "Researchers Detained After Visit to Resettlement Community", The Cambodia Daily, September 11th, 2014.

[៧១] Ben Sokhean, "Police Release Unionists After Workers Surround District Office" The Cambodia Daily, 17 September 2014.

- ព្រឹត្តិការណ៍ទី១ សកម្មជនបឹងកក់យូរឆ្នាំចំនួន ៧នាក់ (លោកយាយង៉ែត យុន អ្នកស្រីទេព វន្នី កញ្ញាសុង ស្រីលាភ អ្នកស្រី គង់ ចន្ថា អ្នកស្រី ផាន់ ឈុនរ៉េត អ្នកស្រី ប៉ូ ឆរី និងអ្នកស្រីនង ស្រេង) បានត្រូវចាប់ខ្លួន ខណៈពេលដែលការតវ៉ាសុំឲ្យអាជ្ញាធរដោះស្រាយបញ្ហាគ្រោះទឹកជំនន់ធ្ងន់ធ្ងរ ដែលបានកំពុងកើតឡើងនៅក្នុងសហគមន៍របស់អ្នកទាំងនោះ ដែលបណ្តាលមកពីការលុបបឹងកក់របស់អ្នកអភិវឌ្ឍន៍មកពីគណបក្សកាន់អំណាច។ នៅថ្ងៃបន្ទាប់ អ្នកទាំងនោះ ត្រូវបានផ្តន្ទាទោសពីបទរារាំងចរាចរណ៍សាធារណៈ (មាត្រា ៧៨ នៃច្បាប់ចរាចរណ៍ផ្លូវគោក) នឹងបានទទួលការផ្តន្ទាទោសដាក់ពន្ធនាគារកម្រិតទោសអតិបរមាចំនួន ១ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥០០ដុល្លារអាមេរិក។
- នៅក្នុងព្រឹត្តិការណ៍ទី២ សកម្មជនបឹងកក់ចំនួន ៣នាក់ផ្សេងទៀត (អ្នកស្រី ហេង ពេជ្រ អ្នកស្រី អ៊ឹម ស្រីទូច និងអ្នកស្រីភ្លួង សុភាព) ព្រមទាំងព្រះតេជគុណ សឿង ហាយ ត្រូវបានចាប់ខ្លួននៅក្រៅសាលាដំបូងរាជធានីភ្នំពេញ នៅខណៈពេលដែលកំពុងតវ៉ាសុំឲ្យមានការដោះលែងស្ត្រីបឹងកក់ ៧នាក់ខាងលើ។ គ្រាន់តែ ២៤ម៉ោង ក្រោយការចាប់ខ្លួន អ្នកទាំងនោះត្រូវបានផ្តន្ទាំទោសពីបទរារាំងមន្ត្រីរាជការសាធារណៈដោយមានស្ថានទម្ងន់ទោស (មាត្រា ៥០៤ នៃក្រមព្រហ្មទណ្ឌ) និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារកម្រិតទោសអតិបរមា ១ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥០០ ដុល្លារអាមេរិក។
- សវនាការបានប្រព្រឹត្តឡើងដោយប្រញាប់ប្រញាល់ និងផ្តោតតែទៅលើវត្តមានរបស់ជនជាប់ចោទនៅកន្លែងតវ៉ា ជាជាងការស្វែងរកភស្តុតាង ដែលពាក់ព័ន្ធនឹងសកម្មភាពរបស់អ្នកទាំងនោះទៅនឹងបទល្មើសដែលបានចោទប្រកាន់។
  សាលាឧទ្ធរណ៍បានសម្រេចតំកល់សាលក្រមសាលាដំបូងរាជធានីភ្នំពេញ ដែលបានផ្តន្ទាទោសមិនត្រឹមត្រូវទៅលើអ្នកទាំងនោះ ទោះបីជាមានការកាត់បន្ថយទោសពន្ធនាគារ និងពិន័យមួយចំនួនក៏ដោយ។ បន្ទាប់ពី៥ខែ នៅក្នុងពន្ធនាគារ អ្នកទាំងអស់ត្រូវបានដោះលែង ក្រោយពីមានការលើកលែងទោសពីព្រះមហាក្សត្រ។

ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤
ករណីទី៧៧
(សូមមើលករណីទី៧៦)

អ្នកតវ៉ា ត្រូវបានឃាត់ខ្លួនដោយមិនត្រឹមត្រូវ[៧៧]
រាជធានីភ្នំពេញ
ការរំលោភបំពានដោយប្រើអំណាច/ ការឃាត់ខ្លួន និងចាប់ខ្លួន

- ក្រុមសកម្មជនដីធ្លី និងព្រះសង្ឃជាង ២៥០អង្គ/នាក់ បានប៉ះទង្គិចគ្នាជាមួយនឹងកងសន្តិសុខជាង ១០០នាក់ និងត្រូវបានគម្រាមកំហែងដោយប្រើអំពើហិង្សា នៅពេលដែលអ្នកទាំងនោះបានដើរហែរក្បួនដោយសន្តិវិធី សុំឲ្យដោះលែងសកម្មជនបឹងកក់ចំនួន ១០នាក់ និងព្រះសង្ឃចំនួន ៣អង្គ ដែលបានចាប់ខ្លួនកាលពីប៉ុន្មានសប្តាហ៍មុន។
- អ្នកចូលរួមចំនួនពីររូប ដែលជាអ្នកស្ម័គ្រចិត្តមកពីសមាគមធាងត្នោត (STT) និងអ្នកបើកបររ៉ឺម៉ក់កង់បីម្នាក់ ត្រូវបានចាប់ខ្លួន ខណៈពេលដែលមានការតវ៉ានៅក្បែររដ្ឋសភាជាតិ និងបានឃុំខ្លួនពួកគេមួយព្រឹក ដោយអាជ្ញាធរខណ្ឌចំការមន នៅវត្តទួលទំពូង ហើយអាជ្ញាធរបានធ្វើការដកហូតប្រដាប់បំពងសម្លេងមួយគ្រឿង។

[៧២] សេចក្តីថ្លែងការណ៍អង្គការ លីកាដូ, "ការបន្តទង្វើរខុសច្បាប់របស់អាជ្ញាធរខេត្តឧត្តរមានជ័យមកលើបុគ្គលិករបស់អង្គការសមធម៌កម្ពុជា", ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤, http://www.licadho-cambodia.org/pressrelease.php?perm=360; Aun Aun Pheap, "Oddar Meanchey Police Break Up Meeting Between NGO, Evictees" The Cambodia Daily, 10 October 2014.

[៧៣] អត្ថបទខ្លីអង្គការ លីកាដូ, "អ្នកធ្វើការផ្នែកសិទ្ធិមនុស្សត្រូវបាននគរបាលខេត្តឧត្តរមានជ័យវាយឲ្យរបួសនៅពេលធ្វើការចងក្រងឯកសារអំពីការរំលោភដីធ្លី", ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៤,http://www.licadho-cambodia.org/flashnews.php?perm=84

www.licadho-cambodia.org